ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ មិនអាចបំភ្លេចទិវាជាតិនៃការចងចាំ២០ ឧសភា

◆ ការផ្លាស់ប្ដូរពី «ទិវាចងកំហឹង» ទៅជា «ទិវាជាតិនៃការចងចាំ»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៥ ខែឧសភា ឆ្នាំ២០២០

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៤៥ ខែឧសភា ឆ្នាំ២០២០

# មាតិកា

## សំបុត្រ

◆ មិនអាចបំភ្លេច ................................១

## ផ្នែកឯកសារ

◆ គុយ សាវ៉ាន គណៈយោធាស្រុក ........... ៦

## ផ្នែកប្រវត្តិសាស្ត្រ និង ការស្រាវជ្រាវ

◆ ខ្ញុំនៅតែចងចាំ ................................ ១០
◆ គាំ កែ អតីតប្រធានភូមិ ................... ១៤
◆ បូជាភ្លើង ......................................១៦
◆ មានជីវិតរស់នៅតែម្នាក់ឯងប៉ុណ្ណោះ ........ ២៦
◆ សម្រេចបួសជាសង្ឃព្រោះគេចពី .......... ២៨
◆ សំឡេងដែលខ្ញុំនៅតែចងចាំគឺម្ដាយ ........ ៣១

## ផ្នែកច្បាប់

◆ សាលក្រមសំណុំរឿង០០២/០២ ............ ៣៤

## ផ្នែកវេទិកាសាធារណៈ

◆ ការផ្លាស់ប្ដូរពី «ទិវាចងកំហឹង» ..............៤០

## ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ «ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោម របបកម្ពុជាប្រជាធិបតេយ្យ
◆ ហ៊ុយ ម៉ាន់ ៖ ពលទាហាន.................. ៤៣
◆ កូវ ជ័រ ៖ ពលទាហាន ...................... ៤៥
◆ កង ណាន ៖ ពលទាហាន ................. ៤៧
◆ ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា ..................៤៩
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់.............. ៥៥



ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក ផាទ្រីក ម័រហ្វី ចូលរួមពិធីបង្សុកូលនៅស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៅវត្តស្វាយពេជ្រ ក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។
(អ៊ុន សុដាវី/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឆាំង យុ, ហេឌី ហ្វ្រាយ, ប៉ាង ពីវ័ន្ត, វេនី ខកហ្គៀល, កៅ សំរិទ្ធ, វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ចុនា,ដារ៉ាវរដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** អ៊ុន សុដាវី
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ចុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# មិនអាចបំភ្លេច
# ទិវាជាតិនៃការចងចាំ២០ ឧសភា

**អ៊ុន សុជាទី**



ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅក្នុងវត្តស្វូនពេជ្រ ក្នុងទីក្រុងភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក ផាទ្រីក ម័រហ្វី អុជធូបនៅស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះនៃរបបខ្មែរក្រហម នៅវត្តស្វូនពេជ្រក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (ស៊ន ប៊ុនស៊ីម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចងចាំពីអំពើប្រល័យពូជសាសន៍ គឺមិនមែនជារឿងដែលងាយនឹងកន្លងហួស,បំភ្លេចចោល ឬជាការអត់ឱនឲ្យនោះទេ។ មិនថាអ្នកគឺជាអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍, ជាសាច់ញាតិរបស់ជនរងគ្រោះ ឬអ្នករស់រានមានជីវិត, ឬក៏ជាចៅទួតនៃជំនាន់ក្រោយ យ៉ាងណាក៏ដោយ ការចងចាំពីភាពសាហាវឃោរឃៅដ៏ធំធេងនៃរបបខ្មែរក្រហមនៅតែឆ្លងកាត់កាលៈទេសៈ, ពេលវេលា និងការព្យាយាម។ អ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមភាគច្រើនបានព្យាយាមលាក់ទុកអតីតកាលរបស់ខ្លួន។ មានតែការរំឭកថាអតីតកាលរបស់អ្នក



*ទីក្រុងភ្នំពេញ ឆ្នាំ១៩៨១។*
*(ដេវីដ ហក/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។*



*ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក ផាទ្រីក ម័រហ៊ី និង នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ចូលរួមពិធីបង្សុកូលនៅក្នុងវត្តស្ទួនពោធិ៍ក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (សន ប៊ុនស៊ីម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

រស់រានមានជីវិត គឺតែងតែនៅជាអត្តសញ្ញាណបច្ចុប្បន្នរបស់គាត់ទាំងអស់គ្នា នោះទើបថាក្មេងៗជាច្រើនដែលកើតក្រោយរបបខ្មែរក្រហមបានស្ទះស្ទើងយល់ ថាតើអំពើឃោរឃៅបែបនេះអាចកើតឡើងបានដោយរបៀបណា ឬប្រហែលជាយុវវ័យជាច្រើនឆ្ងល់ ថាតើអំពើឃោរឃៅបែបនេះ ពិតជាបានកើតឡើងមែនដែរ ឬយ៉ាងដូចម្តេច។ ការចងចាំអំពីអំពើប្រល័យពូជសាសន៍ គឺតែងតែជាផ្នែកមួយនៃអត្តសញ្ញាណរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន និងសម្រាប់មនុស្សជំនាន់ក្រោយតទៅអនាគតកាល។

ថ្ងៃឈប់សម្រាកក្នុងប្រទេសកម្ពុជានៅថ្ងៃទី ២០ ខែឧសភា គឺពិតជាមានសារសំខាន់ណាស់។ ប្រសិនបើថ្ងៃទី២០ ខែឧសភា មិនមែនជាថ្ងៃឈប់សម្រាករបស់ជាតិ ថ្ងៃនេះ គឺជាថ្ងៃនៃការចងចាំ និងការប្តេជ្ញាចិត្តរបស់បុគ្គលម្នាក់ៗ។ ថ្ងៃទី២០ ខែឧសភានេះ តំណាងឲ្យឱកាសមួយដើម្បីចងចាំថាអតីតកាលមួយ ឬគ្រួសារមួយ, សហគមន៍មួយ ឬប្រវត្តិសាស្ត្រនៃប្រទេសមួយ អាចជាឱកាសមួយសម្រាប់ការរៀនសូត្រនិងបង្រៀនទៅដល់ក្មេងៗជំនាន់ក្រោយ។

នៅក្នុងឆ្នាំ១៩៨៤ ថ្ងៃទី២០ ខែឧសភា ត្រូវបានកំណត់ថាជាថ្ងៃនៃ «ទិវាចងកំហឹង» ។ ថ្ងៃទី២០ ខែឧសភា ត្រូវបានកំណត់មួយផ្នែកទៀតថាជានិមិត្តរូបនៃការប្រឆាំងទៅនឹងអង្គការសហប្រជាជាតិ។ រវាងឆ្នាំ១៩៨២ ដល់ឆ្នាំ ១៩៨៣ ដែលមានប្រជាជនកម្ពុជាជាង ១លាននាក់បានផ្តិតមេដៃ និងចុះហត្ថលេខានៅលើញត្តិដើម្បីផ្ញើជូនទៅអង្គការសហប្រជាជាតិតាមរយៈរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ គោលបំណងនៃការដាក់ញត្តិទៅកាន់អង្គការសហប្រជាជាតិគឺជាការតវ៉ាដល់អង្គការសហប្រជាជាតិ ដែលបានបន្តទទួលស្គាល់របបខ្មែរក្រហមថាជាអ្នកតំណាងស្របច្បាប់របស់ប្រជាជនកម្ពុជានៅឯមហាសន្និបាតអង្គការសហប្រជាជាតិ។ សម្តេច ហេង សំរិន បានព្យាយាមដណ្តើមយកអសនៈរបស់ប្រទេសកម្ពុជានៅក្នុងអង្គការសហប្រជាជាតិពីខ្មែរក្រហម ហើយប្រគល់ទៅឲ្យប្រជាជនខ្មែរវិញ។ ប៉ុន្តែជាចុងក្រោយ សកម្មភាពនេះត្រូវបានរារាំង។ នៅក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចតាមរយៈអនុក្រឹត្យលេខ១៩អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៨ កែប្រែឈ្មោះ «ទិវាចងកំហឹង» ទៅជា «ទិវាជាតិនៃការចងចាំ» ដោយកំណត់យកថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំៗចាប់តាំងពីឆ្នាំ ២០១៨ មក ថ្ងៃទី២០ ខែ





ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា លោក ដាទ្រីក ម័រហ្វី ចូលរួមពិធីបង្សុកូលនៅក្នុងវត្តស្ទូនពេជ្រក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឧសភា គឺជា ថ្ងៃបុណ្យជាតិជាផ្លូវការមួយនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានដាក់ឲ្យប្រជាជនកម្ពុជាទូទាំងប្រទេសឈប់សម្រាកពីការងារ ដើម្បីចូលរួមការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមនៅតាមបូជនីយដ្ឋាននានាទូទាំងប្រទេស។ ថ្ងៃទី២០ ខែឧសភា គឺជាថ្ងៃសំខាន់មិនត្រឹមតែជាថ្ងៃសម្រាកពីការងារតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឱកាសមួយសម្រាប់ការស្វែងយល់ និងឧទ្ទិសកុសល។ គ្រូបង្រៀន សិស្សានុសិស្ស មន្ត្រីរាជការ ព្រះសង្ឃ បព្វជិត ទូន ហាគីម និងសាធារណជនអាចជួបជុំគ្នាធ្វើពិធីបង្សុកូលឧទ្ទិសកុសលជូនអ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនៅតាមបូជនីយដ្ឋានដែលនៅក្បែរកន្លែងរស់នៅរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះសោត «ទិវាជាតិនៃការចងចាំ» ថ្ងៃទី២០ ឧសភា បានផ្តល់ឲ្យជាសំណាងសម្ហូហភាព និងផ្លូវចិត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ នៅក្នុងឆ្នាំ២០១៨ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានទទួលស្គាល់ថ្ងៃដែលរាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២០ ខែឧសភានេះធ្វើជាថ្ងៃបុណ្យជាតិជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១។

ទោះបីជាយ៉ាងនេះក៏ដោយ ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២០ នេះ និងឆ្នាំបន្តបន្ទាប់ទៅថ្ងៃអនាគត គឺលែងជាថ្ងៃឈប់សម្រាកសាធារណៈទៀតហើយនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាមានការផ្លាស់ប្តូរនេះ ខ្ញុំសង្ឃឹមថាយើងនៅតែអាចបន្តរំឭកដល់ថ្ងៃទី ២០ ខែឧសភានេះបានដដែល។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, លោកឯកអគ្គរដ្ឋទូតអាមេរិក ដាទ្រីក ម័រហ្វី និងបុគ្គលិករបស់ស្ថានទូតអាមេរិកប្រចាំប្រទេសកម្ពុជា បានមកប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលនៅក្នុងវត្តស្ទូនពេជ្រ ដើម្បីរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិត។ វត្តស្ទូនពេជ្រមានទីតាំងស្ថិតនៅភូមិស្ទូនពេជ្រ ដែលមានចម្ងាយប្រហែលពាគីឡូម៉ែត្រពីសាលាក្តីខ្មែរក្រហម។

យោងតាមរបាយការណ៍ស្តីអំពីការចុះសិក្សាស្រាវជ្រាវអំពើឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត នៅខេត្តកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខ្មែរក្រហមបានយកវត្តស្ទូនពេជ្រធ្វើជាគុក និងជាកន្លែងសម្លាប់មនុស្សនៅអំឡុងឆ្នាំ១៩៧៦។ គុកនេះ គឺជាគុកដែលធំជាងគេនៅ



*ប្រជាជនចូលរួមបង្សុកូលនៅក្នុងវត្តស្ទឹងមានជ័យ ពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (អ៊ុន សុដារី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្នុងស្រុកអង្គស្នួល។ ប្រជាជនចន្លោះពី ៤០០ទៅ ៧០០ នាក់ ត្រូវបានប៉ាន់ស្មានថាបានស្លាប់នៅក្នុងវត្តនេះ។ រណ្តៅសម្លាប់មនុស្ស គឺស្ថិតនៅជុំវិញបរិវេណវត្ត ប្រឡាយខាងមុខវត្តថែងព្រះវិហារ ក្នុងស្រះក្បែរព្រះវិហារ និងខាងលិចសាលារៀន។ ប្រជាជនដែលត្រូវបានខ្មែរក្រហមចាប់ខ្លួនយកមកទីនេះ គឺជាអ្នកដែលខ្មែរក្រហមបានចោទប្រកាន់ថា «ខុសសីលធម៌, ជាប់និន្នាការប៉ូលីស, ទាហាន, គិញ, គយ ឬជនបង្កប់សូវៀត និងអាមេរិក»។ ជនរងគ្រោះមានចម្រុះជនជាតិ ចិន, ចាម, ខ្មែរ, ក្មេង, ចាស់, ប្រុស, ស្រីដែលដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា។ ខ្មែរក្រហមសម្លាប់ដោយមិនរើសអើងនោះទេ។ ខ្មែរក្រហមសម្លាប់ទាំងក្មេងទាំងចាស់ និងទាំងប្រុសទាំងស្រី។ នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ មានការវាយសម្លាប់អ្នកទោសជាច្រើនព្រោះខ្មែរក្រហមបានចោទប្រកាន់អ្នកទោសទាំងអស់ថាជាខ្មែរ«ស»។ សព្វថ្ងៃនេះ យើងឃើញមានការកសាងស្តូបសម្រាប់តម្កល់អដ្ឋិធាតុរបស់ជនរងគ្រោះនៅក្នុងវត្តស្ទឹងមានជ័យ។

នៅក្នុងពិធីសូត្រមន្តបង្សុកូលឧទ្ទិសដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលត្រូវបានប្រារព្ធធ្វើនៅវត្តស្ទឹងមានជ័យ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ លោកឯកអគ្គរដ្ឋទូតអាមេរិក ដាទ្រិក ម័រហ្វី បានមានប្រសាសន៍ថា «ខ្ញុំពិតជារំភើបណាស់ ដែលបានមកចូលរួមប្រារព្ធកម្មវិធីនៅក្នុងវត្តស្ទឹងមានជ័យ។ ខ្ញុំរីករាយដែលទីតាំងនេះមានការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ថែមទាំងមានការចូលរួមថែរក្សាពីលោកយាយលោកតា និងកូនចៅជំនាន់ក្រោយទៀត»។ លោកឯកអគ្គរដ្ឋទូតអាមេរិក ដាទ្រិក ម័រហ្វី បានសួរទៅកាន់អ្នកចូលរួមថា តើអ្នកទាំងអស់គ្នានៅចងចាំពីរបបខ្មែរក្រហមដែរឬទេ? តើមាននរណាខ្លះបាត់បង់សាច់ញាតិនៅទីនេះ? លោកក៏បានបន្ថែមទៀតដែរថា «ថ្ងៃទី២០ ឧសភា គឺជាថ្ងៃដ៏សំខាន់ណាស់ក្នុងការចងចាំពីអំពើប្រល័យពូជសាសន៍ ហើយសម្រាប់ការថែរក្សាការចងចាំនេះ គឺជាកិច្ចការរបស់លោកដែលជួយគាំទ្រដែរ។ សហរដ្ឋអាមេរិក នឹងបន្តជួយគាំទ្រដល់ការងារដែលទាក់ទងនឹងការផ្សះផ្សា និងសន្តិភាព។ ការសិក្សាប្រវត្តិសាស្ត្រសំខាន់ណាស់ ព្រោះនៅមានបុគ្គលមួយចំនួនមិនទាន់ជឿលើការកើតឡើងនៃរបបខ្មែរក្រហមនៅឡើយ។ នៅក្នុងប្រទេសកម្ពុជាមាន

ក្មេងៗជាច្រើនដែលកើតក្រោយរបបខ្មែរក្រហម ដូច្នេះ វាពិតជាសំខាន់ណាស់ នៅពេលដែលយើងមានសៀវភៅប្រវត្តិសាស្ត្រសម្រាប់បង្រៀនដល់ក្មេងៗទាំងនោះ»។

ព្រះសង្ឃ អាចារ្យ និងលោកតាលោកយាយមួយក្រុមតូចបានចូលរួមសូត្រមន្តបង្សុកូលតាមប្រពៃណីខ្មែរនៅពីខាងមុខបូជនីយដ្ឋាននៅក្នុងវត្តស្វនពេជ្រ ដើម្បីឧទ្ទិសកុសលដល់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងវត្តនេះ។ ចាស់ៗមួយក្រុមតូចបានចែករំលែករឿងរ៉ាវដែលខ្លួនបានជួបប្រទះនៅក្នុងរបបខ្មែរក្រហមនៅពីខាងមុខស្តូបរំឭកវិញ្ញាណក្ខន្ធ។ ជួនពេលខ្លះគាត់និយាយដោយទឹកមុខបារម្ភ និងសោកស្តាយ ប៉ុន្តែពេលខ្លះគាត់ក៏បង្ហាញនូវទឹកមុខរីករាយដែរ។ ងឹម លី ភេទប្រុស អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅក្បែរវត្តស្វនពេជ្របាននិយាយថា៖

ការរស់នៅក្នុងរបបខ្មែរក្រហមគឺជាការរស់នៅដោយភិតភ័យដែលមិនដឹងថាថ្ងៃណាត្រូវខ្មែរក្រហមយកទៅសម្លាប់ឡើយ។ ខ្ញុំរីករាយណាស់នៅពេលដែលមានការប្រារព្ធពិធីបង្សុកូលឧទ្ទិសដល់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ព្រោះខ្ញុំជឿថាការធ្វើបុណ្យបែបនេះអាចនឹងបានដល់អ្នកដែលបានស្លាប់ទៅ។ ចំពោះខ្ញុំ ការរំឭកឡើងវិញពីរឿងរ៉ាវដ៏ជូរចត់នៅក្នុងរបបខ្មែរក្រហមមិនបានធ្វើឲ្យខ្ញុំឈឺចាប់ទៀតទេ ប៉ុន្តែវាអាចជួយឲ្យខ្ញុំហាក់បីដូចជាមានក្តីសង្ឃឹមឡើងវិញនៅពេលដែលមានអ្នកខ្វល់ខ្វាយ និងយកចិត្តទុកដាក់ពីរឿងរ៉ាវដែលបានកន្លងផុតទៅ។ ថ្ងៃទី២០ ខែឧសភា គឺជាថ្ងៃមួយដែលអាចជួយដល់ការចងចាំយ៉ាងទូលំទូលាយដល់ក្មេងៗជំនាន់ក្រោយ។ ទោះបីជាថ្ងៃ២០ឧសភា ត្រូវបានលុបចេញពីថ្ងៃឈប់សម្រាកនៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែវាមិនបានធ្វើឲ្យប៉ះពាល់ដល់ការចងចាំរបស់ខ្ញុំឡើយ។ ថ្ងៃនេះគឺជាថ្ងៃមួយដែលប្រជាជន និងក្មេងៗជំនាន់ក្រោយរៀនសូត្រអំពីប្រវត្តិសាស្ត្រដើម្បីទប់ស្កាត់ការកើតឡើងវិញនៃរបបខ្មែរក្រហមម្តងទៀត ថែមទាំងកុំឲ្យមានការចាញ់បោកនយោបាយដូចកាលពីអតីតកាល។

មាន យ៉យ ភេទស្រី អាយុ៦៣ ឆ្នាំ រៀបរាប់ថា៖ នៅវត្តស្វនពេជ្រនេះ មានការធ្វើពិធីបង្សុកូលឧទ្ទិសដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមជារៀងរាល់ឆ្នាំ។ ក្នុងមួយឆ្នាំវត្តស្វនពេជ្រធ្វើពិធីនេះចំនួនពីរដង គឺនៅថ្ងៃចូលឆ្នាំ បុណ្យភ្ជុំ និងថ្ងៃទី២០ ខែឧសភា ទិវាជាតិនៃការចងចាំនេះ។ ខ្ញុំត្រេកអរណាស់ ដែលមានអ្នកមកចូលរួមធ្វើបុណ្យជាមួយប្រជាជននៅទីនេះ ដល់អ្នកដែលបានស្លាប់ទៅនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំក៏មានសាច់ញាតិបានស្លាប់ក្នុងវត្តស្វនពេជ្រនេះដែរ។ ខ្ញុំស្ងប់ចិត្តណាស់នៅពេលដែលបានធ្វើពិធីបុណ្យដូច្នេះ។ សម្រាប់ខ្ញុំ នេះគឺជាមេរៀនប្រវត្តិសាស្ត្រមួយដែលជួយអាចជួយឲ្យក្មេងៗដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងជៀសវាងដើរទៅរកផ្លូវមិនល្អដូចក្រុមខ្មែរក្រហមទៀត។ មិនតែប៉ុណ្ណោះ ក្មេងៗជំនាន់ក្រោយក៏អាចជួយឲ្យប្រទេសស្ងប់សុខបានដែរ។



ប្រជាជនចូលរួមបង្សុកូលនៅក្នុងវត្តស្វនពេជ្រ ក្នុងទីក្រុងភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។ (អ៊ុន សុជាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចងចាំពីអំពើប្រល័យពូជសាសន៍ គឺមិនងាយស្រួលនោះទេក្នុងការចងចាំ ហើយវាក៏មិនងាយស្រួលក្នុងការបំភ្លេចចោលដែរ។ មិនថាថ្ងៃទី ២០ ខែឧសភា គឺជាថ្ងៃឈប់សម្រាកសាធារណៈ ឬក៏មិនមែនក៏ដោយ វានៅតែមិនអាចផ្លាស់ប្តូរភាពសំខាន់នៃប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់ជនរងគ្រោះនិងអ្នកដែលនៅរស់រានមានជីវិត, មនុស្សជាទីស្រឡាញ់ និងមនុស្សជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម។ ថ្ងៃទី២០ ឧសភានេះ គឺត្រូវតែជាថ្ងៃផ្ទាល់ខ្លួន និងជាថ្ងៃរួមសម្រាប់ការចងចាំមួយរបស់ជាតិ។ ដូច្នេះហើយមេរៀននៃប្រវត្តិសាស្ត្រនេះនឹងមិនត្រូវបានបំភ្លេចឡើយសម្រាប់ប្រជាជនកម្ពុជា និងពិភពលោក។

# គុយ សាវ៉ាន គណៈយោធាស្រុកកំពង់ត្រាបែក

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00២៥៥

*ដារ៉ារដ្ឋ មេត្តា*



*យោធាខ្មែរក្រហមកំពុងធ្វើដំណើរទៅសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំមានឈ្មោះ គុយ យ៉ុន នៅពេលចូលធ្វើបដិវត្តន៍ក្នុងឆ្នាំ១៩៦៩ ខ្ញុំបានប្តូរទៅឈ្មោះ គុយ សាវ៉ាន វិញ។ ឪពុកខ្ញុំឈ្មោះ គុយ យ៉ាន់ បានស្លាប់នៅក្នុងឆ្នាំ១៩៦៨ និងម្តាយខ្ញុំឈ្មោះ ព្រុំ ប៉ិច។ ឪពុកម្តាយរបស់ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំកើតនៅភូមិព្រៃស្វាំង ឃុំពញាលឿង ស្រុកព្រះស្តេច ខេត្តព្រៃវែង។ នៅពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ឪពុកម្តាយខ្ញុំបានផ្លាស់ទៅរស់នៅភូមិស្វាយព្រីម ក្នុងឃុំពញាលឿងដដែល ព្រោះកាលនោះភូមិកំណើតរបស់ខ្ញុំមានការរាត្តបាតពីសំណាក់កងទ័ពវៀតណាម។ រហូតដល់ខ្ញុំមានអាយុ១១ឆ្នាំ ទើបខ្ញុំវិលត្រឡប់មករស់នៅក្នុងភូមិស្វាំងវិញ។ ក្រោយមក ម្តាយរបស់ខ្ញុំបាននាំខ្ញុំមកបួសរៀននៅវត្តថ្មី ស្ថិតនៅឃុំពញាលឿង ដែលនៅពេលនោះខ្ញុំអាយុ១៦ឆ្នាំ។ ខ្ញុំបានបួសជានេនរយៈពេលមួយឆ្នាំ និងបួសជាភិក្ខុរយៈពេលពីរឆ្នាំ។ បន្ទាប់មកខ្ញុំបានទៅរៀនគម្ពីរព្រះត្រៃបិដក នៅវត្តឃ្លាំង ស្ថិតនៅឃុំឈើកាច់ ស្រុកបាភ្នំ។

នៅឆ្នាំ១៩៦៧ ខ្ញុំបានប្រឡងជាប់សញ្ញាបត្រភាសាបាលីរង នៅក្រុងព្រៃវែង។ នៅឆ្នាំ១៩៦៨ ខ្ញុំបានសឹកមក

នៅផ្ទះវិញ ដោយសារពេលនោះជីវភាពគ្រួសារមានការខ្វះខាតៗ អ្នកភូមិនៅជិតវត្តទួលក្រសាំង ដែលធ្លាប់ស្គាល់ខ្ញុំកាលខ្ញុំនៅបួសជាព្រះសង្ឃ បានឧបត្ថម្ភដី គោក្របី ទុកឲ្យខ្ញុំភ្ជួររាស់ធ្វើស្រែចម្ការៗ ខ្ញុំបានដាំពោត សណ្តែក និងល្ងៗ នៅចុងឆ្នាំ១៩៦៨ ឪពុកមាររបស់ខ្ញុំឈ្មោះ គុយ សាន់ បានទិញអ៊ួនទុកឲ្យខ្ញុំនេសាទត្រីវិញៗ នៅពេលខ្ញុំនេសាទត្រី ខ្ញុំបានទទួលការអប់រំនយោបាយបណ្តើរៗពី បងធុច (លេខាតំបន់២៣) និង បងភន (នៅអង្គភាពកសិកម្មតំបន់២៤)ៗ

ខ្ញុំបានចូលបដិវត្តន៍នៅខែកុម្ភៈ ឆ្នាំ១៩៦៩ នៅភូមិព្រៃស្វាំង ដោយមានបងភនជាអ្នកនាំចូល និងមានបងធុចគឺជាអ្នកទទួលស្គាល់ៗ ក្រោយចូលបដិវត្តន៍ខ្ញុំបានធ្វើសកម្មភាព ចលនាយុវជន-យុវនារី បីភូមិគឺ ១) ភូមិក្រសាំងទង ២) ភូមិស្វាំង និង ៣) ភូមិទឹកជូរ ដោយខ្ញុំមានតួនាទីជាអនុប្រធានសាខាយុវជន ៗ នៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៧០ ខ្ញុំបានចូលអង្គការសម្ព័ន្ធយុវកក «សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា គឺជាដៃស្តាំរបស់បក្សកុម្មុយនីស្តកម្ពុជា» ដោយមានសមមិត្ត ខាំ សុខ ជាអ្នកឧទ្ទេស និង សមមិត្ត ម៉ុង ជាអ្នកទទួលស្គាល់ៗ ខ្ញុំបានចូលបក្សនៅថ្ងៃ២២ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅអង្គភាពស្រុកកំពង់ត្របែក ដោយមានសមមិត្ត សុខ សានគឺជាអ្នកឧទ្ទេសនាមទី១ សមមិត្ត ចាន់ ថន គឺជាអ្នកឧទ្ទេសនាមទី២ និងសមមិត្ត ជ័យ សារិន ជាអ្នកទទួលស្គាល់ៗ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧១ ខ្ញុំបានចូលជាបេក្ខជនពេញសិទ្ធិៗ

ក្រោយពីចូលបដិវត្តន៍ខ្ញុំបានទទួលតំណែងជាបន្តបន្ទាប់រហូតដល់ខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំមានតួនាទីជាលេខា យ ក្នុងគណៈយោធាស្រុកកំពង់ត្របែកៗ

ពេលនោះខ្ញុំមានប្រពន្ធឈ្មោះ ឡុង ខឿន អាយុ ២៣ ឆ្នាំៗ យើងមិនទាន់មានកូនទេៗ ប្រពន្ធរបស់ខ្ញុំកើតនៅភូមិគ្រស់ ឃុំជ័យកំពក ស្រុកកោះជ័យ មាននាទីបុគ្គលិកកាត់ដេរ នៅក្នុងអង្គភាពសេដ្ឋកិច្ចស្រុកកំពង់ត្របែកៗ

ខ្ញុំមានបងប្អូនទាំងអស់៨នាក់ ក្នុងនោះស្រី៤នាក់ៗ គ្រួសារខ្ញុំគឺជាវណ្ណៈកសិករ ដូច្នេះយើងបានចូលបដិវត្តន៍ទាំងអស់គ្នាលើកលែងតែប្អូនស្រីពៅរបស់ខ្ញុំអាយុ១៤ឆ្នាំរស់នៅជា មួយម្តាយបន្ទាប់ពីឪពុករបស់ខ្ញុំបានស្លាប់ទៅៗ បងប្រុសរបស់ខ្ញុំឈ្មោះ គុយ យុន គឺជាលេខាឃុំរាធរ ស្រុកកោះជ័យ និងប្អូន គុយ នាន ធ្វើការនៅអង្គភាពជាមួយគាត់ៗ ប្អូនគុយ ឈន និង គុយ ណាត គឺជាបុគ្គលិកវប្បធម៌ ក្នុងភូមិព្រៃស្វាំងៗ ចំណែកប្អូន គុយ នៅ គឺជាពេទ្យនៅឃុំពញាលៀងខ និង គុយ ហាន ពេទ្យតំបន់២៤ៗ

កាលនោះខ្ញុំមានមិត្តភក្តិដែលជិតស្និទ្ធ នៅក្រោយឆ្នាំ១៩៧០ គឺមានសមមិត្ត សុខ សាន គឺជាប្រធានសន្តិសុខស្រុកកំពង់ត្របែក, សមមិត្ត ម៉ី គឺជាប្រធានវប្បធម៌ស្រុកកំពង់ត្របែក និងសមមិត្ត អៀង ប៉ក់ គឺជាប្រធានឡូត៍នេសាទ តំបន់២៤ៗ

ខ្ញុំបានធ្វើសកម្មភាពតាមការចាត់តាំងរបស់ វិនៗ នៅខែកក្កដា ឆ្នាំ១៩៧៦ មានការប្រជុំនៅក្រោមផ្ទះ វិន ដែលមានគ្នា៤នាក់ចូលរួម គឺមាន វិន, សមមិត្ត ម៉ី (ប្រធានមន្ទីរស្រុកកំពង់ត្របែក), តូច សារឹម (ប្រធានយោធាយរបស់ស្រុកកំពង់ត្របែក) និងខ្ញុំៗ ការប្រជុំនោះគឺរៀបចំផែនការដែលមានឈ្មោះថា «ចលនាសេរីនិយម» ដែលយកសមាជិកភាពអ្នកជាប់និន្នាការនយោបាយសង្គមចាស់ ដូចជា មេភូមិ មេកង ប៉ូលិស ទាហាន សមាសភាពពាលាអាវ៉ាសែ និងសមាសភាពស្វាក់ស្មើរ សម្ងំសុខ ដើម្បីធ្វើជាខ្នងបង្អែកៗ ខ្ញុំក្តាប់មិនបានដើមកំណើតដំបូងនៃចលនានេះកើតចេញពីណាមកទេៗ តាមការអប់រំពីឈ្មោះ វិន ក្បាលម៉ាស៊ីនដឹកនាំក្នុងចលនានេះមានឈ្មោះ ចក្រី, សុផាន, សុជាតិ, ឈូក ហៅម៉ែន និង គាត់ (វិន) ហើយមានប្រទេសវៀតណាម និងប្រទេសសូវៀតជាអ្នកគាំទ្រទាំងខាងសម្ភារៈ ឈ្មោះ បៃម៉ាប់ គឺជាគណៈទាក់ទងវៀតណាមបានផ្តល់ឲ្យនូវ អាអ៊ែ១៥ (AR-15) ចំនួន៧៥ដើម, សេកាសេ (CKC) ចំនួន៤០ដើម, អាកា (AK) ចំនួន៦០ដើម, អឹម៣០ (M-30) ចំនួន៤ដើម, គ្រាប់បែកត្បាល់៦០មីលីម៉ែត្រ ចំនួន៣ដើម, បេ៤០ (B-40) ចំនួន២ដើម, អឹម៧៩ (M-79) ចំនួន៦ដើម, កា៤៥, បេអា ចំនួន១២ដើម



យុទ្ធនារីខ្មែរក្រហមនៅភូមិភាគបូព៌ាកំពុងដញ្ជូនស្រូវជាមួយកងចល័តពីសមរភូមិមុខទៅទុកនៅសមរភូមិក្រោយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងថ្នាំពេទ្យចំនួនពាធុង។ សម្ភារទាំងអស់នេះបានទទួលនៅក្នុងខែតុលា ឆ្នាំ១៩៧៥ គឺយោធាស្រុកកំពង់ត្របែកតូច សារីម ជាអ្នកទទួលយកពីឈ្មោះប៉ែម៉ាប់ នៅផ្សារពាមបន្ទាយ។ ក្រោយមកសម្ភារទាំងនេះត្រូវបានដឹកយកទៅដាក់នៅក្នុងឃ្លាំងកអណ្តើក ស្ថិតនៅក្នុងឃុំប្រសាទ ស្រុកកំពង់ត្របែក។

ខ្ញុំត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦ មូលហេតុដោយសារខ្ញុំទទួលបានការអប់រំក្បត់ និងទទួលការចាត់តាំងក្បត់ពីឈ្មោះ វិន (លេខាស្រុកកំពង់ត្របែក)។ វិន បានអប់រំខ្ញុំឲ្យអនុវត្តជុយពីមាគ៌ារបស់បក្សចាប់ពីឆ្នាំ១៩៧៣មក។ ផែនការនេះគឺមានទិសដៅវាយរំលំរដ្ឋអំណាចបដិវត្តន៍ដើម្បីដណ្តើមរដ្ឋអំណាចយកមគ្រប់គ្រង និងចាត់ចែងតាមគោលជំហរសេរីនិយម។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ ខ្មែរ ក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ គុយ យ៉ុន ហៅ គុយ សាវ៉ាន ពិតប្រាកដយ៉ាងណានោះទេ។

# វិចិត្រសាលសិល្បៈ
# សហសម័យវិទ្យាស្ថានស្លឹករឹត









វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថាន ស្លឹករឹត ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្ដុះបណ្ដាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលដែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីសិល្បៈ និងវប្បធម៌ តាមរយៈការតាំងពិព័រណ៍ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្ដល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់ កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍មកទស្សនានៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) និងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត, សូមទាក់ទងមកកាន់ **ស៊ាង ចិន្តា** អ្នកសម្របសម្រួល តាមរយៈ ទូរសព្ទលេខ ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!

# ខ្ញុំនៅតែចងចាំ
## «៤៥ឆ្នាំក្រោយបែកពីឪពុករបស់ខ្ញុំ»

អ៊ុន សុដាវី



ខាត់ ទឹម កំពុងផ្តល់បទសម្ភាសន៍ដល់ អ៊ុន សុដាវី បុគ្គលិកទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅផ្ទះរបស់គាត់នៅក្នុងឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ (អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រំឭកដល់រឿងរបបខ្មែរក្រហម ទឹម ប្រាប់ថា អ្វីដែលគាត់មិនអាចបំភ្លេចបានគឺបណ្តាំឪពុករបស់គាត់នៅថ្ងៃដែលគាត់បាននិយាយលាគ្នាជាលើកចុងក្រោយ។ ទឹម និយាយទាំងអួលដើមកថា នៅថ្ងៃដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ គាត់និងប្រពន្ធបានធ្វើដំណើរទៅព្រែកឈ្នៅដើម្បីថ្វាយបង្គំលាឪពុករបស់គាត់។ ឪពុករបស់គាត់បានសម្រក់ទឹកភ្នែកហើយនិយាយថា យើងនឹងបែកគ្នាចាប់ពីថ្ងៃនេះហើយ។ ប៉ុន្តែប្រសិនបើយើងមានភ័ព្វសំណាងយើងនឹងជួបគ្នាវិញ។ ទឹម មិនដែលបានជួបមុខឪពុករបស់គាត់ឡើយ រហូតមកដល់ពេលនេះ។

សព្វថ្ងៃនេះ ខាត់ ទឹម មានអាយុ៦៧ឆ្នាំ គឺមេភូមិរស់នៅក្នុងភូមិញរ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានរៀបរាប់ពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមថា៖ ខ្ញុំមានស្រុកកំណើតនៅភូមិស្វាយចេក ឃុំគោករការ ស្រុកជង្កោ ខេត្តកណ្តាល។ ខ្ញុំមានបងប្អូន៥នាក់ ស្រី៤នាក់និងប្រុស១នាក់។ ម្តាយឪពុករបស់ខ្ញុំគឺជាកសិករ។ គាត់ធ្វើស្រែ និងលក់ដូរបន្តិចបន្តួចដើម្បីចិញ្ចឹមកូនៗ ក្នុងឆ្នាំ១៩៦០ ខ្ញុំមានអាយុ៧ឆ្នាំប៉ុណ្ណោះ ម្តាយរបស់ខ្ញុំបានឈឺស្លាប់។ ដូច្នេះខ្ញុំត្រូវរស់នៅជាមួយឪពុករបស់ខ្ញុំ។ លុះដល់ពេលដែលឪពុករបស់ខ្ញុំរៀបការប្រពន្ធថ្មី ខ្ញុំសម្រេចចិត្តចេញពីគាត់ទៅរស់នៅជាមួយ បងស្រីទីពីររបស់ខ្ញុំវិញ។ នៅពេលខ្ញុំអាយុបាន១០ឆ្នាំ ខ្ញុំបានទៅរស់នៅវត្តកប់ស្រូវ ព្រោះជីវភាពគ្រួសាររបស់បងស្រីខ្ញុំលំបាកខ្លាំងពេក ហើយម្យ៉ាងទៀតខ្ញុំចង់រៀនអក្សរ។ ក្មេងៗនៅក្នុងភូមិខ្ញុំតែងតែនិយាយចំអក និងហៅខ្ញុំថា អាក្មេងវត្ត។ រាល់ថ្ងៃខ្ញុំខិតខំរៀនសូត្រ និងបម្រើព្រះសង្ឃ។ ខ្ញុំតែងតែដងទឹកដាក់ពាង ដាំទឹកតែ និងធ្វើកិច្ចការផ្សេងៗទៀតដែលព្រះសង្ឃប្រើ។ ដោយឃើញខ្ញុំខស្បរាហ៍ព្យាយាម នៅក្នុងឆ្នាំ១៩៧០ ព្រះចៅអធិការវត្តបានបំបួសខ្ញុំជាព្រះសង្ឃ។ ខ្ញុំបួសបានពីរឆ្នាំ ខ្មែរក្រហមបានចូលមកដល់ភូមិ ហើយភាពវឹកវរក៏បានកើតឡើង។ ខ្ញុំក៏បានសឹក និងបានមករស់នៅជាមួយបងស្រីរបស់ខ្ញុំម្នាក់ទៀត នៅម្តុំផ្សារសែនសុខ។ ជារឿយៗ ខ្ញុំបានទៅសួរសុខទុក្ខឪពុករបស់ខ្ញុំ។ នៅឆ្នាំ១៩៧៣ យោធាខ្មែរក្រហម បានចូលមករស់នៅជាមួយប្រជាជនកាន់តែច្រើន ប៉ុន្តែមិនបានធ្វើបាប

ប្រជាជនទេ។ ខ្ញុំបានស្គាល់យោធាខ្មែរក្រហមម្នាក់។ យោធានោះបានប្រាប់ខ្ញុំថា ប្រសិនបើយើងគ្មានប្រពន្ធ អង្គការនឹងឲ្យយើងធ្វើការងារធ្ងន់នៅក្នុងកងចល័ត។ ប៉ុន្តែប្រសិនបើយើងមានប្រពន្ធ អង្គការនឹងឲ្យយើងធ្វើស្រែចម្ការ និងអាចរស់នៅជួបជុំគ្រួសារ។ ខ្ញុំបានសម្រេចចិត្តរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ សេក ភួង នៅក្នុងឆ្នាំ១៩៧៤។ បន្ទាប់ពីរៀបការរួច ខ្ញុំបានផ្លាស់មករស់នៅជាមួយប្រពន្ធ និងឪពុកក្មេកនៅឯពោធិ៍ចិនតុងវិញ។ ឪពុកក្មេករបស់ខ្ញុំប្រកបមុខរបរនេសាទត្រីពីបឹងដំរីដែលស្ថិតនៅខាងលិចគោកគៀងយកទៅលក់នៅឯផ្សារដើហុយ។ ប្រពន្ធរបស់ខ្ញុំ គឺជាអ្នកលក់ត្រី។ ពេលគាត់ទៅលក់ត្រីនៅផ្សារ ខ្ញុំតែងតែជួយឈរមើលពីខាងក្រោយខ្នងរបស់គាត់ ព្រោះយើងខ្លាចអ្នកទិញបន្លំ។ រហូតដល់ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងទីក្រុងភ្នំពេញត្រូវខ្មែរក្រហមជម្លៀសចេញទាំងអស់។ នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញដំបូង ខ្ញុំតែងតែដើរទៅតាមយោធាខ្មែរក្រហមមួយក្រុមដែលដើរប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជននៅតាមផ្ទះ និងនៅក្នុងផ្សារពោធិ៍ចិនតុង។ បន្ទាប់មក យោធាខ្មែរក្រហមបានចូលមកក្នុងផ្ទះរបស់ខ្ញុំ ហើយបញ្ជាឲ្យយើងចាកចេញពីផ្ទះទៅកាន់ទិសខាងជើង។ ក្រុមគ្រួសាររបស់ខ្ញុំបានចាកចេញពីផ្ទះនៅក្នុងខែមេសា ឆ្នាំ១៩៧៥។ យោធាខ្មែរក្រហមទាំងនោះបានប្រាប់ឲ្យយើងចាកចេញពីផ្ទះមួយរយៈពេលសិន ព្រោះយន្តហោះរបស់អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។ ខ្ញុំបានគិតថាខ្មែរក្រហមនឹងមិនឲ្យប្រជាជនរស់នៅក្នុងទីក្រុងទៀតទេ។ មុននឹងចាកចេញ ខ្ញុំនិងប្រពន្ធបានទៅថ្វាយបង្គំលាឪពុករបស់ខ្ញុំដែលរស់នៅម្តុំព្រែកព្នៅ។ ឪពុករបស់ខ្ញុំបានស្ទុះមកចាប់ឱបខ្ញុំ រួចហើយក៏យំ។

បន្ទាប់ពីលាឪពុករួច ខ្ញុំជាមួយប្រពន្ធ និងក្រុមគ្រួសាររបស់ឪពុកក្មេកខ្ញុំបានចាកចេញ ដោយយើងយកបានអង្ករខ្លះដាក់នៅលើកង់បណ្តើរចេញទៅ។ នៅតាមផ្លូវ យើងបានចែករបស់របរគ្នាយួរ ព្រោះខ្លាចខ្មែរក្រហមរឹបអូស។ យើងធ្វើដំណើរដោយថ្មើរជើង ចំណែកកង់យើងត្រូវបណ្តើរ។ យើងមានខោអាវម្នាក់តែមួយកំប្លេប៉ុណ្ណោះ។ យើងដេកនៅតាមផ្លូវជាច្រើនថ្ងៃ ទំរាំមកដល់កំពង់ចម្លងព្រែកក្តាម។ បន្ទាប់មកយើងបន្តដំណើរមកស្នាក់នៅភូមិរកាកោង និងនៅព្រែកពោធិ៍មួយរយៈ ហើយចុងក្រោយទើបទៅដល់ខេត្តព្រៃវែង។ ខ្មែរក្រហមចោទថាខ្ញុំខុសសីលធម៌ ព្រោះខ្ញុំដេកក្បែរប្រពន្ធរបស់ខ្ញុំ។



សាលាឃុំញូរ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។
(អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហមយកខ្ញុំទៅអប់រំនៅក្នុងព្រៃក្បែរៗនោះ ដោយនិយាយថា ខ្ញុំមិនត្រូវធ្វើឲ្យនារីស្រើបស្រាលឡើយ។ សាច់ញាតិរបស់ខ្ញុំ រួមមាន គ្រួសារឪពុកក្មេក គ្រួសាររបស់បងបង្កើត និងគ្រួសារ ខ្ញុំបានជិះទូកឈើក្នុងចម្ងាយផ្លូវ៣០ម៉ែត្រ បន្តទៅស្វាយពល ហើយចាប់តាំងពីពេលនោះមកខ្ញុំលែងស្គាល់ទីតាំងដែលខ្ញុំស្នាក់



ខាត់ ខឹម ចិញ្ចឹមក្របីដើម្បីភ្ជួររាស់ក្នុងរដូវធ្វើស្រែ និងសម្រាប់លក់ឲ្យឈ្មួយយកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ (អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្តោះអាសន្នហើយ។ យោធាខ្មែរក្រហមដែលយាមនៅតាមផ្លូវបានដេញឲ្យយើងបន្តធ្វើដំណើរទៅមុខ។ មកដល់ភូមិមួយមានកើតជំងឺអាសន្នរោគ និងបានឆ្លងរាលដាលបណ្តាលឲ្យប្រជាជនក្អួតចង្អោរ ដូច្នេះយោធាខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងចូលទៅក្នុងភូមិនោះទេ។ យោធាខ្មែរក្រហមដែកឆែរយើងតាមផ្លូវរហូត។ នៅវេលាម៉ោង៧យប់ ថ្ងៃមួយពេលមេឃកំពុងភ្លៀងធ្លាក់ខ្លាំង ខ្ញុំនិងសាច់ញាតិ ព្រមទាំងប្រជាជនជាច្រើនគ្រួសារទៀតបានធ្វើដំណើរកាត់តាមភូមិព្រៃឈរ។ ខ្ញុំឃើញស្ត្រីម្នាក់បីកូនដើរក្រោមដំណក់ទឹកភ្លៀង។ ខ្ញុំបានដើរចូលទៅផ្ទះប្រជាជនមូលដ្ឋានរួចហើយស្រែកសុំម្ចាស់ផ្ទះជ្រកភ្លៀង ប៉ុន្តែម្ចាស់ផ្ទះបានបដិសេធ។ ម្ចាស់ផ្ទះថាយើងគឺជាប្រជាជនថ្មី អាចនឹងនាំបញ្ហាដល់គាត់។ ខ្ញុំអង្វរថាបើមិនឲ្យមនុស្សធំជ្រក សុំឲ្យក្មេងជ្រកផង ប៉ុន្តែម្ចាស់ផ្ទះនោះនៅតែមិនព្រម។ យើងបានបន្តដំណើរទៅមុខទៀតដោយប្រជាជនខ្លះទូល ខ្លះរែកអីវ៉ាន់សំពីងសំពោង។ យើងបានដើររហូតដល់ខេត្តស្វាយរៀង និងបានស្នាក់នៅវត្តស្វាយតាយានមួយយប់។ យោធាខ្មែរក្រហមបានចាប់ផ្តើមហៅខ្ញុំ និងប្រជាជនជម្លៀសទៅសួរប្រវត្តិរូបម្តងម្នាក់ៗ។ យោធាខ្មែរក្រហមម្នាក់សួរមកកាន់ខ្ញុំថា តើមិត្តធ្វើទាហានពាក់ស័ក្តិប៉ុន្មាន? ខ្ញុំបានប្រាប់យោធានោះថា ខ្ញុំមិនដែលធ្វើទាហានទេ ខ្ញុំធ្វើតែស្រែប៉ុណ្ណោះ។ យោធានោះសួរទៀតថា តើមិត្តចេះធ្វើស្រែទេ? ខ្ញុំឆ្លើយថា ខ្ញុំចេះ។ យោធាខ្មែរក្រហមបានសួរបន្តថា តើមិត្តរៀនថ្នាក់ទីប៉ុន្មាន? ខ្ញុំថារៀនមិនបានជ្រៅជ្រះទេ គឺរៀននៅវត្ត។ ចំណែកប្រជាជនខ្លះ នៅពេលយោធាសួរពីការរៀនសូត្របានបង្ហាញសញ្ញាបត្ររបស់ខ្លួន យោធាទាំងនោះយកសញ្ញាបត្រទៅហែកចោលអស់ បន្ទាប់មកបញ្ជូនអ្នកទាំងនោះទៅរៀនសូត្រ។ ភាគច្រើនយោធាខ្មែរក្រហមសួរប្រវត្តិរូបតែប្រុសៗប៉ុណ្ណោះ។ បន្ទាប់ពីយោធាខ្មែរក្រហមសួរប្រវត្តិរូបរួច ខ្ញុំត្រូវបានបញ្ជូនឲ្យទៅរស់នៅភូមិញរស្រុកកំពង់រោទ៍។

ប្រជាជនជម្លៀសបានសង់ខ្ទមស្នាក់នៅបណ្តោះអាសន្ន។ ប្រជាជនខ្លះបានស្នាក់នៅក្នុងខ្ទមដែលមានស្រាប់ និងខ្លះទៀតសុំប្រជាជនមូលដ្ឋានស្នាក់អាស្រ័យ។ ខ្ញុំបានសង់ខ្ទមស្នាក់នៅដោយខ្លួនឯង។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងភ្ជួរ ចំណែកប្រពន្ធរបស់ខ្ញុំធ្វើជាអ្នកបុកអង្ករ និងស្ទូងស្រូវ។ ល្ងាចថ្ងៃមួយបន្ទាប់ពីហូបបបរពេលល្ងាចរួច ខ្ញុំក៏រៀបចំចូលដេក។ នៅពេលនោះ ខ្មែរក្រហមម្នាក់បានយកបបរមកឲ្យខ្ញុំមួយចានទៀតដើម្បីហូបបន្ថែម។ ខ្ញុំត្រេកអរយ៉ាងខ្លាំង និងអរគុណខ្មែរក្រហមនោះ។ ភ្លាមនោះខ្ញុំបាននិយាយរឿងនេះប្រាប់ពូរបស់ខ្ញុំ ហើយពូរបស់ខ្ញុំបានប្រាប់ថា ខ្មែរក្រហមនោះមានបំណងប្រើខ្ញុំហើយ។ មួយរយៈខ្លីក្រោយមក ប្រធានកងមកប្រាប់ខ្ញុំឲ្យចេញទៅភ្ជួរស្រែនៅវេលាម៉ោង១២យប់ រហូតដល់ថ្ងៃរះ។ បបរនោះវាប្រែជាលែងឆ្ងាញ់សម្រាប់ខ្ញុំហើយ ព្រោះខ្ញុំត្រូវធ្វើការរហូតដល់ភ្លឺ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនហ៊ានខ្ជិលច្រអូសឡើយ។ រៀងរាល់ព្រឹក ខ្ញុំតែងតែសួរទៅប្រធានកងភ្ជួរឈ្មោះ រឹម ថា តើខ្ញុំត្រូវធ្វើអ្វីខ្លះថ្ងៃនេះ? ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំខិតខំធ្វើការមិនដែលបានទៅលេងប្រពន្ធឡើយ។ ខ្ញុំតែងតែនឹកគិតទៅដល់បងស្រី និងឪពុកដែលបាត់ដំណឹង។ រៀងរាល់យប់ ខ្ញុំតែងតែភ័យខ្លាច។ ខ្ញុំឃើញកងឈ្លបខ្មែរក្រហមចាប់ចងអតីតទាហាន លន់ នល់ យកមកដាក់នៅក្នុង

វត្តញរ ដែលជាកន្លែងសម្រាប់កងក្តួរស្នាក់នៅ។ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីសម្ងំដេក និងបិតត្រចៀកឲ្យជិតនោះទេ។ ក្រៅពីភ្ជួរស្រែ ខ្ញុំឃ្វាលក្របី និងរែកកណ្តាប់ស្រូវឲ្យកងស្ទូង។ ថ្ងៃខ្លះ ខ្ញុំបានលួចរត់ទៅផ្ទះជួបប្រពន្ធរបស់ខ្ញុំនៅពេលយប់។ ខ្ញុំតែងតែស្តៀកសំពត់ប្រពន្ធរបស់ខ្ញុំ ព្រោះខោអាវរបស់ខ្ញុំទទឹកស្ទើររាល់ថ្ងៃ។ ប្រពន្ធរបស់ខ្ញុំតែងតែលួចលាក់អង្ករទុកឲ្យខ្ញុំដាំបាយហូបមុននឹងទៅធ្វើការងារ។ ប្រពន្ធរបស់ខ្ញុំមិនដែលខ្លាចសេចក្តីស្លាប់ឡើយ។ ថ្ងៃមួយប្រធានកងចាត់តាំងឲ្យប្រពន្ធរបស់ខ្ញុំទៅប្រមូលអាចម៍ក្របី៥០គីឡូ ដូច្នេះខ្ញុំបានចេញទៅជួយគាត់ទាំងយប់ព្រោះខ្ញុំខ្លាចប្រពន្ធរបស់ខ្ញុំមិនអាចធ្វើតាមផែនការបាន។ នៅវេលាម៉ោង១០យប់ យើងទាំងពីរនាក់បានដើរចេញពីភូមិដើម្បីប្រមូលអាចម៍ក្របី។

នៅឆ្នាំ១៩៧៨ ប្រពន្ធខ្ញុំកើតបានកូនស្រីម្នាក់ដ៏ស្រស់ស្អាត។ ខ្ញុំទៅមើលថែគាត់បានតែបីថ្ងៃប៉ុណ្ណោះ។ ខ្ញុំសុំមេកងនៅមើលថែគាត់ថែមមួយយប់ទៀត ប៉ុន្តែមេកងមិនព្រម។ មេកងបានហៅខ្ញុំត្រឡប់មកភ្ជួរស្រែវិញ។ ប្រពន្ធរបស់ខ្ញុំយំយ៉ាងខ្លាំង ពេលខ្ញុំចាកចេញ។ មុនពេលចេញទៅ ខ្ញុំបានផ្តាំប្អូនថ្លៃរបស់ខ្ញុំឲ្យជួយមើលថែប្រពន្ធខ្ញុំផង។ ខ្ញុំត្រូវភ្ជួរឲ្យហើយតាមផែនការកំណត់ ទើបប្រធានអនុញ្ញាតឲ្យខ្ញុំត្រឡប់មកផ្ទះវិញ។ នៅវេលាម៉ោងប្រហែល ១២ អធ្រាត ខែចេត្រ បុរសម្នាក់បានមកហៅខ្ញុំឲ្យចេញទៅ។ ប្រពន្ធរបស់ខ្ញុំផ្តាំឲ្យខ្ញុំយកភួយទៅជាមួយដើម្បីទុកដណ្តប់ ប៉ុន្តែខ្ញុំប្រាប់គាត់វិញថា អូនទុកភួយដណ្តប់ជាមួយកូនទៅព្រោះបងនឹងត្រូវអង្គការយកទៅសម្លាប់ហើយ។ ខ្ញុំយកតែកន្សែងមួយប៉ុណ្ណោះ។ ពេលដើរចេញទៅតាមផ្លូវ ខ្ញុំធ្វើពុតជាឈឺដោយក្អករហូត។ លុះខ្មែរក្រហមព្រួកមិនឈប់ក៏អនុញ្ញាតឲ្យខ្ញុំត្រឡប់មកផ្ទះវិញ។

នៅខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចូលមកខេត្តស្វាយរៀង និងកៀរប្រុសៗមួយចំនួនទៅហាត់ក្បួនទ័ពនៅវៀតណាម។ ចំណែកខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីភូមិ។ ប្រជាជនខ្លះត្រូវបានខ្មែរក្រហមសម្លាប់ចោលព្រោះមានសាច់ញាតិរត់ភៀសខ្លួនទៅប្រទេសវៀតណាម។ ប្រជាជនខ្លះត្រូវចាប់ខ្លួន។ ខ្ញុំបានសម្រេចចិត្តចូលធ្វើជាកងទ័ព និងភៀសខ្លួនទៅវៀតណាម។ ខ្ញុំទុកប្រពន្ធ និងកូននៅប្រទេសកម្ពុជា ព្រោះវៀតណាមប្រមូលតែប្រុសៗប៉ុណ្ណោះ។ ខ្ញុំប្រាប់ប្រពន្ធថា បើខ្ញុំមិនទៅក៏ស្លាប់ ដូច្នេះខ្ញុំត្រូវតែទៅ។ ក្រោយមក ប្រពន្ធខ្ញុំ និងកូនរបស់ខ្ញុំក៏ភៀសខ្លួនទៅវៀតណាមដែរ។ ខ្ញុំបានហាត់ក្បួនទ័ពនៅព្រៃនគរ។ ខ្ញុំនៅកងវរលេខ១១។ បន្ទាប់មក ខ្ញុំបានមកវាយយោធាខ្មែរក្រហមប្រហែលកន្លះខែនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំមកជាមួយកងទ័ពចំនួន ៨៧ នាក់ ដែលសុទ្ធសឹងជាកងទ័ពខ្មែរដែលទើបហាត់រៀនយុទ្ធសាស្ត្រយោធាថ្មីៗ។ បន្ទាប់មក ខ្ញុំក៏ត្រឡប់ទៅរស់នៅប្រទេសវៀតណាមវិញ។ ខ្ញុំតែងតែផ្ញើសំបុត្រតាមរយៈអ្នកស្គាល់ទៅឲ្យប្រពន្ធរបស់ខ្ញុំ ហើយប្រពន្ធរបស់ខ្ញុំក៏បានមកលេងខ្ញុំ។ យើងសប្បាយរីករាយខ្លាំងណាស់ ប៉ុន្តែមួយថ្ងៃក្រោយមក វៀតណាមបានឲ្យប្រពន្ធខ្ញុំឲ្យត្រឡប់មកវិញ ព្រោះមិនអនុញ្ញាតឲ្យនៅជាមួយកងទ័ពឡើយ។ រហូតដល់កងទ័ពស្ម័គ្រចិត្តវៀតណាមវាយបែកភ្នំពេញ ទើបខ្ញុំ និងប្រពន្ធកូន ត្រឡប់មកនៅព្រំដែនវិញ ។

នៅឆ្នាំ១៩៨០ ប្រពន្ធរបស់ខ្ញុំបានឈឺស្លាប់។ ខ្ញុំរស់នៅតែពីរនាក់កូនស្រីរបស់ខ្ញុំប៉ុណ្ណោះ។ ក្រោយមក ខ្ញុំបានជួបម្តាយចុងរបស់ខ្ញុំ។ ម្តាយចុងរបស់ខ្ញុំប្រាប់ថា ឪពុករបស់ខ្ញុំបានស្លាប់បាត់ហើយ គឺស្លាប់នៅខេត្តពោធិ៍សាត់ក្នុងឆ្នាំ១៩៧៨។ ម្តាយចុងរបស់ខ្ញុំបានប្រាប់ខ្ញុំឲ្យទៅយកធាតុឪពុក ប៉ុន្តែនៅពេលនោះខ្ញុំមិនអាចទៅបានទេ ព្រោះស្រុកមិនទាន់មានសន្តិភាព។ ក្រោយមកម្តាយចុងរបស់ខ្ញុំក៏ស្លាប់ទៀត ដូច្នេះ ខ្ញុំមិនដឹងថាផ្នូររបស់ឪពុកខ្ញុំនៅទីណាឡើយ។ ថ្ងៃមួយ ឪពុករបស់ខ្ញុំបានមកពន្យល់សប្តិប្រាប់ខ្ញុំថាមានកូនប្រុសតែមួយ ប៉ុន្តែមិនអាចយកគាត់មកនៅជាមួយបាន។ ខ្ញុំនៅតែមានការសោកស្តាយ និងគិតថាមិនបានតបស្នងសងគុណឪពុកវិញ។ ខ្ញុំបានត្រឹមតែអុជធូបបន់ស្រន់សុំខមាទោសគាត់។ អ្វីៗហាក់បីដូចជាការយល់សប្តិនៅពេលដែលខ្ញុំដឹងដំណឹងថាឪពុករបស់ខ្ញុំស្លាប់។ ខ្ញុំនៅតែចងចាំមិនភ្លេចនៅថ្ងៃចុងក្រោយដែលយើងបាននិយាយលាគ្នា។

# គាំ កែ អតីតប្រធានភូមិ នៅស្រុកកំចាយមារ

អ៊ុន សុជាទី



លោក នួវ ដុំ មេឃុំទឹកថ្លា ក្នុងស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ផ្តល់ព័ត៌មានទាក់ទងនឹងប្រជាជនដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមនៅក្នុងឃុំរបស់លោក និងប្រជាជនដែលមានបញ្ហាសុខភាពប្រាប់ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ុន សុជាទី ។
(លី កុកឆាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

គាំ កែ មិនអាចដើររួចអស់រយៈពេលប្រហែលពីរខែកន្លងមកហើយ ព្រោះគាត់ឈឺក្បាលជង្គង់។ កែ និយាយប្រាប់ខ្ញុំថា ជំងឺរបស់គាត់គឺជាជំងឺដែលជាទូទៅកើតឡើងចំពោះមនុស្សចាស់ជរា។ កែ ជ្រើសរើសយកវិធីសាស្ត្រព្យាបាលជំងឺរបស់គាត់តាមរយៈមន្ទីរពេទ្យរដ្ឋដែលស្ថិតនៅក្បែរផ្ទះ។ គាត់ពិតជារីករាយ ប្រសិនបើមានការពិនិត្យសុខភាពជូនគាត់។ សព្វថ្ងៃ កែ មានអាយុ៨៣ឆ្នាំ រស់នៅភូមិដូនដោក ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ជាមួយកូនៗដែលប្រកបមុខរបរធ្វើស្រែចម្ការ។ ទោះបីគាត់មានវ័យចំណាស់ ប៉ុន្តែគាត់នៅចងចាំរឿងរ៉ាវបានខ្លះពេលដែលគាត់ឆ្លងកាត់របបខ្មែរក្រហម។

កែ រំឭកថា នៅក្នុងរបបខ្មែរក្រហមគ្មាននរណាម្នាក់ខ្វាយខ្វល់ពីអនាម័យ និងសុខភាពឡើយ។ ដូច្នេះទោះបីជាបច្ចុប្បន្ននេះជំងឺក្លូរ៉ូណាកំពុងតែរាតត្បាតក្តី ក៏គាត់មិនសូវព្រួយបារម្ភខ្លាំងដែរ ព្រោះគាត់យល់ឃើញថាប្រព័ន្ធសុខាភិបាលសព្វថ្ងៃប្រសើរជាងនៅសម័យខ្មែរក្រហម និងមានការយកចិត្តទុកដាក់។

កែ កើតនៅក្នុងគ្រួសារកសិករដែលមានម្តាយឪពុកប្រកបរបរធ្វើស្រែចម្ការ ដើម្បីចិញ្ចឹមជីវិត។ នៅក្នុងរបបលន់ នល់ កែ បានរៀនសូត្រតិចតួចណាស់នៅសាលាវត្ត

ទួលសង្កែ។ កែ រៀនអក្សរជាមួយព្រះសង្ឃដែលបួសនៅក្នុងវត្តទួលសង្កែ ព្រោះក្នុងពេលនោះគ្មានសាលារៀន និងគ្រូបង្រៀននៅក្នុងភូមិឡើយ។ មិនយូរប៉ុន្មាន កែ បានសម្រេចចិត្តបួសជាព្រះសង្ឃ និងបានស្នាក់នៅក្នុងវត្តទួលសង្កែអស់រយៈពេល៥វស្សា។

ខ្មែរក្រហមបានចូលមកដល់ភូមិរបស់ កែ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ហើយគាត់ក៏បានសឹកនៅពេលនោះដែរ។ នៅអំឡុងឆ្នាំ១៩៧២ កែ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធានភូមិ ហើយនៅក្នុងភូមិរបស់គាត់ក៏មានប្រជាជនថ្មីចូលមករស់នៅដែរ។ នៅចុងឆ្នាំ១៩៧៣ ខ្មែរក្រហមបានប្រមូលភូមិនីមួយៗបញ្ចូលគ្នា ដើម្បីបង្កើតទៅជាសហករណ៍។ សហករណ៍រួមបានចាប់ផ្តើមដំណើរការពីឆ្នាំ១៩៧៤ ហើយនៅក្នុងសហករណ៍ក៏មិនសូវខ្វះខាតអាហារដែរ។ ទោះបី កែ ធ្វើជាមេភូមិ ប៉ុន្តែគាត់ត្រូវធ្វើការដូចប្រជាជនដែរ។ ចន្លោះពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ កែ ដឹកត្រយូងចេក ផ្លែចេក និងបន្លែបង្ការផ្សេងៗ ទៅផ្គត់ផ្គង់សហករណ៍ និងចែកទៅប្រជាជនដែលកំពុងតែជីកប្រឡាយ។ កែ បានបរទេះសេះពីស្រុកកំចាយមារ ខេត្តព្រៃវែង ទៅដឹកបន្លែនៅស្រុកអូររាំងឪ ដែលស្ថិតក្នុងខេត្តកំពង់ចាម។ កែ ត្រូវចំណាយពេលពេញមួយថ្ងៃក្នុងការដឹកជញ្ជូនបន្លែទាំងអស់នោះ ហើយពេលខ្លះគាត់ដេកនៅតាមផ្លូវចំនួនមួយយប់នៅពេលដែលស្ថានភាពផ្លូវធ្វើដំណើរលំបាកខ្លាំង។ កែ បរទេះសេះចេញពីស្រុកកំចាយមារតាំងពីព្រលឹមម៉ោងប្រហែល៤ទៀបភ្លឺ និងទៅដល់កំពង់ចាមម៉ោងប្រហែល៨ព្រឹក ហើយត្រឡប់មកដល់កំចាយមារវិញនៅម៉ោងប្រហែលជា៥រសៀល។ កែ ធ្វើកិច្ចការនេះរៀងរាល់ថ្ងៃ។

នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចពេញលេញក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំង កែ ឲ្យទៅធ្វើស្រែវិញ ដោយមិនឲ្យគាត់ធ្វើជាមេភូមិដូចមុនឡើយ។ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីចូលមករស់នៅក្នុងកាន់តែច្រើនៗ កែ បានធ្វើការ និងរស់នៅទីនោះជាមួយប្រជាជនថ្មីទាំងនោះ។ រហូតដល់ឆ្នាំ១៩៧៨ មេដឹកនាំខ្មែរក្រហមបានចាប់ សោ ភឹម គឺជាលេខាភូមិភាគបូព៌ា ដោយចោទថាក្បត់ និងចូលដៃជាមួយវៀតណាម។ បន្ទាប់មក យោធាខ្មែរក្រហមបានចាប់ផ្តើមកៀរប្រជាជនចេញពីភូមិ។ ប្រជាជននៅក្នុងភូមិបាននាំគ្នាប្រឆាំង ដោយប្រជាជនខ្លះកាន់កាំបិត ពូថៅ ដំបងព្រោះមិនចង់ចាកចេញពីភូមិឡើយ។ ប៉ុន្តែយោធាខ្មែរក្រហមមកពីភូមិនិរតីនៅតែបង្ខំឲ្យប្រជាជនចាកចេញ។ យោធាខ្មែរក្រហមទាំងនោះ បានបាញ់គ្រាប់បេ៤០ ដាក់ប្រជាជនដែលបះបោរប្រឆាំងទាំងនោះ។ ពេលនោះ កែ ដែលនៅឈរផ្អែកសសរផ្ទះ ក៏ត្រូវអំបែងគ្រាប់ចំខ្នងប្រមុះ និងក្បែរភ្នែកខាងស្តាំ។ ប្រជាជនជាច្រើនត្រូវបានសម្លាប់នៅពេលនោះ។ នៅវេលាម៉ោងប្រហែល៩ព្រឹក ក្នុងខែកក្កដា ឆ្នាំ១៩៧៨ កែ និងប្រជាជនដែលនៅរស់ជីវិត ត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីភូមិ ក្នុងគោលបំណងយកទៅសម្លាប់ចោល ប៉ុន្តែគណៈស្រុកបានទៅយក កែ ត្រឡប់មកវិញ។ កែ ត្រូវបានបញ្ជូនឲ្យទៅរស់នៅឃុំត្បែង។ នៅទីនោះខ្មែរក្រហមចាត់តាំងឲ្យគាត់ធ្វើស្រែចម្ការគ្មានពេលទំនេរឡើយ។ ចំណែករបបអាហារ គាត់ហូបតែបបររាវប៉ុណ្ណោះ។ រយៈពេលប្រហែល២ខែក្រោយមក កងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកដល់ ដូច្នេះយោធាខ្មែរក្រហមក៏ចាប់ផ្តើមកៀរអ្នកស្រុកចេញពីភូមិម្តងទៀត។ កែ និងក្រុមគ្រួសារត្រូវបានយោធាខ្មែរក្រហមកៀរទៅដល់ទន្លេបិត។ នៅពេលដែលខ្មែរក្រហមរត់បែកខ្ញែកគ្នាអស់ កែ បាននាំគ្រួសារត្រឡប់មករស់នៅក្នុងស្រុកកំចាយមាររហូតមក។

បច្ចុប្បន្ន កែ បានទៅប្រឹក្សាជាមួយគ្រូពេទ្យដើម្បីរកវិធីព្យាបាលជំងឺឈឺក្បាលជន្លង់របស់គាត់ដែលបានកើតឡើងជាប្រចាំ។ គ្រូពេទ្យបានជ្រើសយកវិធីចាក់ថ្នាំលើក្បាលជន្លង់របស់ កែ នៅពេលដែលគាត់ឈឺចុកចាប់ខ្លាំង។ កែ អាចដើរបានខ្លះ ដោយគាត់ត្រូវកាន់ឈើច្រត់ដើម្បីទប់ខ្លួន។



លោកវេជ្ជបណ្ឌិត ដេម៉ូសធីន រ៉េយស៍ ទីប្រឹក្សាគម្រោង ប្រមូល និងចងក្រងការចងចាំបទពិសោធន៍ក្នុងរបបខ្មែរក្រហមរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងវាស់សម្ពាធឈាមប្រជាជននៅក្នុងខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

*រេហ្គី ប្រ្យាយ*

(តពីលេខមុន)




*បន្ទប់តាំងពិព័រណ៍នៅសារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ៍នៃប្រទេសប៉ូឡូញ។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

### តើមានមនុស្សប៉ុន្មាននាក់ដែលមកពីស្រុកកំណើតរបស់អ្នកបានរួចជីវិតបន្ទាប់ពីសង្គ្រាម?

*នេះគឺជាសំណួរដែលមិនអាចឆ្លើយបាន។ អ្នកដែលបានរួចជីវិតបានទៅរស់នៅកន្លែងផ្សេងៗពីគ្នា។ មិនមានមនុស្សច្រើនប៉ុន្មានទេដែលវិលត្រឡប់មកស្រុកកំណើតវិញ។ យើងមានគ្នាប្រុសស្រី និងកុមារចំនួន ៣០០៧នាក់ត្រូវបានទាហានណាហ្ស៊ីយកទៅផ្ទុកនៅ ក្នុងទូរថភ្លើងនៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៤៤។ នៅពេលដែលក្រុមស្ត្រីរបស់យើងត្រូវបានគេរាប់ចំនួនបន្ទាប់ពីការជ្រើសរើសនៅយប់ដែលយើងបានទៅដល់អូសឈ្វិចនៅថ្ងៃទី១៧ ខែឧសភា យើងមានគ្នាចំនួន ៤៨៦នាក់។ តួរលេខអាចនឹងស្រដៀងគ្នាជាមួយខាងបុរសដែរ។ ប្រសិនបើយើងសន្មតថាតួរលេខទាំងនេះពិតជាដូចគ្នាជាមួយនឹង*

រថភ្លើង៥ផ្សេងទៀត គឺអាចមានន័យថា ៣ភាគ៥នៃគ្រួសារទាំងនោះបានរួចផុតជីវិតពីការជ្រើសរើសដំបូងៗ ប៉ុន្តែតើមានចំនួនប៉ុន្មានអ្នកដែលបានស្លាប់បន្ទាប់ពីនោះ គឺគ្មាននរណាម្នាក់អាចដឹងបានឡើយៗ

នៅក្នុងចំណោមសមាជិកគ្រួសារចំនួន ៣១នាក់របស់ខ្ញុំដែលរស់នៅស៊ីហ្គេត មានចំនួន ១០នាក់ តែប៉ុណ្ណោះដែលរស់រានមានជីវិតៗ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ អ្នកមួយចំនួនដែលចង់វិលត្រឡប់មកវិញបានជួបប្រទះការលំបាកយ៉ាងខ្លាំង ពីព្រោះមិនមានបណ្ដាញដឹកជញ្ជូនណាដែលមានដំណើរការល្អនោះទេៗ ដូច្នេះមនុស្សភាគច្រើនធ្វើដំណើរដោយថ្មើរជើង សុំជិះរថយន្តឬហក់ឡើងជិះរថភ្លើងណាដែលខ្លួនបានជួបប្រទះៗ

សានយី ដែលជាប្អូនប្រុសពៅរបស់ឪពុកខ្ញុំបានរួចជីវិតៗ គាត់ធ្វើការនៅកន្លែងដុតនំប៉័ងនៅក្នុងជំរំអូសឈ្វិច ដូច្នេះហើយគាត់មាននំប៉័ងសម្រាប់បរិភោគបានគ្រប់គ្រាន់ៗ គាត់សង្ឃឹមថានឹងអាចរកឃើញប្រពន្ធរបស់គាត់ឈ្មោះថា ហេឡេនៗ នៅពេលដែលសង្គ្រាមបានបញ្ចប់គាត់បានចេញដំណើរទៅស៊ីហ្គេតដោយថ្មើរជើងៗ បន្ទាប់មកហេតុការណ៍ដែលស្មានរួចក៏បានកើតឡើងៗ នៅពេលដែលគាត់ទៅដល់ទីក្រុងប្រាក និងកំពុងដើរនៅតាមផ្លូវគាត់បានជួប ហេឡេនៗ ហេឡេន ក៏ត្រូវបានរំដោះចេញពីជំរំពលកម្មដូចគ្នាដែរ ហើយក៏កំពុងតែធ្វើដំណើរទៅស៊ីហ្គេតដើម្បីស្វែងរកសានយីៗ

នេះគឺជាការជួបជុំមួយក្នុងចំណោមការជួបជុំដែលរីករាយដ៏ទៃទៀត ពីព្រោះមានមនុស្សជាច្រើនដែលមិនអាចរកឃើញសូម្បីតែមនុស្សម្នាក់ផងនៅពេលដែលពួកគេត្រឡប់ទៅស៊ីហ្គេតវិញៗ ក្នុងករណីជាច្រើន សូម្បីតែផ្ទះរបស់ពួកគេក៏មិននៅសេសសល់ដែរៗ សានយី និង ហេឡេន មានសំណាងល្អម្ដងទៀត ពីព្រោះផ្ទះរបស់ពួកគេគឺស្ថិតនៅដូចដើមៗ ពួកគេអាចចាប់ផ្ដើមជីវិតសារជាថ្មីម្ដងទៀតនៅទីនោះៗ ប៉ុន្តែពួកគេមិនបានរស់នៅទីនោះយូរទេៗ ស៊ីហ្គេត ត្រូវបានរំដោះដោយទាហានរុស្ស៊ីនៅរដូវស្លឹកឈើជ្រុះ ក្នុងឆ្នាំ១៩៤៤ហើយប្រជាជនត្រូវរស់នៅក្រោមរបបកុម្មុយនីស្តដ៏តឹងរ៉ឹងៗ សានយី និង ហេឡេនបានចាកចេញពីរូម៉ានីយ៉ាងឆាប់រហ័ស ហើយចុងក្រោយពួកគេក៏បានតាំងទីលំនៅក្នុងទីក្រុង ឡូសអាន់ជើឡែសៗ

## តើអ្នករីករាយទេនៅពេលដែលត្រូវបានរំដោះ?

យើងត្រូវបានគេរំដោះខណៈពេលដែលភ្លើងសង្គ្រាមកំពុងតែឆេះឆួលយ៉ាងខ្លាំងៗ កងទ័ពអង់គ្លេសនៅតាមផ្លូវរបស់ពួកគេទៅទីក្រុងបែរឡាំង បានរំដោះយើងចេញពីជំរំបឺជិន-បែលសិន នៅថ្ងៃទី១៥ ខែ មេសា ក្នុងឆ្នាំ ១៩៤៤ៗ អ្នកប្រហែលជាគិតថា ខ្ញុំរីករាយណាស់ ប៉ុន្តែនៅពេលនោះ ខ្ញុំមានសុខភាពខ្សោយ ហើយមិនបានចាប់អារម្មណ៍អំពីអ្វីទាំងអស់ៗ ខ្ញុំស្ទើរតែមិនមានអារម្មណ៍សប្បាយរីករាយៗ គំនិតតែមួយគត់របស់ខ្ញុំគឺនៅថ្ងៃបន្ទាប់ខ្ញុំនឹងទៅជំរំបុរស ហើយចាប់ផ្ដើមស្វែងរកឪពុករបស់ខ្ញុំៗ អស់រយៈពេលជាច្រើនថ្ងៃបានកន្លងផុតទៅទើបខ្ញុំអាចអបអរនឹងសេរីភាពបានៗ

ខ្ញុំពិតជារីករាយណាស់ប៉ុន្តែការអបអរនេះត្រូវការកម្លាំងកាយ ហើយខ្ញុំត្រូវការពេលវេលាដើម្បីឲ្យមានកម្លាំងឡើងវិញៗ

ខ្ញុំមានអារម្មណ៍សប្បាយរីករាយដំបូង គឺនៅពេលដែលយើងទៅដល់ប្រទេសស៊ុយអែតៗ នៅពេលនោះខ្ញុំនិងប្អូនស្រី បានដើរឆ្លងកាត់ស្ពានវ៉ាស៊ីប្រុន ដែលជាស្ពានមួយនៅក្នុងទីក្រុងស្តុកខុលៗ នៅពេលដែលខ្ញុំងាកមើលទៅខាងក្រោយខ្នងរបស់ខ្ញុំ គឺមិនមានកងការពារណាហ្វូទៀតនោះទេៗ ខ្ញុំក៏មិនឮសំឡេងឆ្កែព្រុសដែរ ហើយជំនួសទៅវិញអ្វីដែលខ្ញុំឃើញ គឺក្រុមគ្រួសារស៊ុយអែតមួយដែលពោរពេញទៅដោយសេចក្ដីសុខ ហើយកំពុងតែជិះកង់យ៉ាងសប្បាយរីករាយនៅក្រោមពន្លឺព្រះអាទិត្យនារសៀលថ្ងៃអាទិត្យៗ លីវី និងខ្ញុំគិតដូចគ្នាៗ យើងមើលមុខគ្នាទៅវិញទៅមកហើយក៏ចាប់ផ្ដើមរាំនៅកណ្ដាលស្ពានៗ

## ហេតុអ្វីបានជាអ្នកសម្រេចចិត្តជ្រើសរើសយកប្រទេសស៊ុយអែត?

ជាធម្មតាខ្ញុំតែងតែនិយាយថាប្រទេសស៊ុយអែតជ្រើសរើសយកខ្ញុំ។ នៅពេលដែលសង្គ្រាមជិតបញ្ចប់ អាល្លឺម៉ង់បានយល់ថាការបរាជ័យជិតមកដល់ ដូច្នេះអ្វីៗគ្រប់យ៉ាង និងមនុស្សគ្រប់រូបដែលអាចធ្វើជាសាក្សីនៃឧក្រិដ្ឋកម្មរបស់ពួកគេត្រូវបានបំផ្លាញ។ ទាហានអាល្លឺម៉ង់ត្រូវតែសម្លាប់អ្នកនៅក្នុងជំរំទាំងអស់។ នៅពេលនោះប្អូនស្រី និង ខ្ញុំកំពុងតែនៅក្នុងជំរំពលកម្មនៅជិតទីក្រុងហែមបឺក។

ថ្ងៃមួយនៅដើមខែមេសា យើងដែលមានគ្នាចំនួន ២០០នាក់ បានទទួលបញ្ជាឲ្យប្រមូលផ្តុំគ្នានៅក្នុងបន្ទប់មួយនៅក្នុងជំរំ។ ប៉ុន្តែនេះគឺគ្មានអ្វីដែលគួរឲ្យកត់សម្គាល់ទេ ប្រសិនបើយើងប្រៀបធៀបជាមួយនឹងអ្វីដែលបានកើតឡើងបន្ទាប់។ កងការពារនារីណាហ្ស៊ីចិត្តអាក្រក់ដែលយើងហៅថា «អាណា ធាត់» បានបញ្ជាឲ្យយើងស្រាតសម្លៀកបំពាក់។ «កន្លែងដែលពួកឯងទៅគឺមិនត្រូវការសម្លៀកបំពាក់ទេ» នាងនិយាយបន្ថែម។ យើងបានដោះសម្លៀកបំពាក់ចេញនិងអង្គុយនៅទីនោះ ដោយរាងកាយញ័រពីព្រោះភាពរងារ និងភាពភ័យខ្លាច។ បន្ទាប់មកមេបញ្ជាការជំរំបានដើរកាត់ និងសម្លឹងមើលមកយើងដោយភាពងឿងឆ្ងល់ ហើយបានសួរថា ហេតុអ្វីបានជាយើងអង្គុយនៅទីនេះដោយអាក្រាតកាយ។ នៅពេលដែលគាត់ឮថាយើងបានធ្វើតាមបញ្ជារបស់ «អាណា» គាត់បានមើលទៅនាងដោយមិនពេញចិត្ត ហើយបន្ទាប់មកក៏ឲ្យយើងប្រាប់ប្រញាប់ស្លៀកសម្លៀកបំពាក់វិញ។ យើងអាចដកដង្ហើមវិញបានស្រួលបន្តិច ប៉ុន្តែនៅតែមិនដឹងថាមានរឿងអ្វីបានកើតឡើង។ យើងនៅតែមានអារម្មណ៍ភ័យខ្លាច។ បន្ទាប់ពីស្លៀកពាក់រួចយើងត្រូវបានគេនាំទៅស្ថានីយរថភ្លើង ទៅដល់ទីនោះខ្ញុំមានញ្ញាណទី៧ ពីព្រោះសារជាថ្មីម្តងទៀតយើងត្រូវបានគេយកទៅដាក់នៅក្នុងទូរថភ្លើងជាមួយនឹងធុងទឹកពីរ និងធុងមួយទៀតសម្រាប់ឲ្យយើងធ្វើជាបង្គន់ និងគ្មានអាហារនោះទេ។ តើយើងទៅទីណា? ទៅជំរំអូស ឈ្វិចវិញ? នៅពេលនោះជំរំអូសឈ្វិចត្រូវបានរំដោះរួចទៅហើយ ប៉ុន្តែយើងមិនបានដឹងអំពីរឿងនោះទេ។

រថភ្លើងបានធ្វើដំណើរដោយល្បឿនយឺតក្នុងរយៈពេលបីយប់បីថ្ងៃ វាបានបោះពួយទៅមុខ ហើយឈប់រង់ចាំនៅផ្លូវមួយចំហៀងទៀតនៅពេលណាដែលរថភ្លើងទាហានបានឆ្លងកាត់ បន្ទាប់មកទើបធ្វើដំណើរបន្តទៀត។ យប់មួយ នៅពេលដែលយើងកំពុងឈរស្ងៀម យើងបានឮសំឡេងបើកទ្វារ និងសូរសំឡេងកាំភ្លើង។ ពេលនោះយើងជឿជាក់ថាពេលវេលាចុងក្រោយរបស់យើងបានមកដល់ពិតប្រាកដណាស់។ យើងទាំងអស់គ្នានឹងត្រូវបានគេប្រហារជីវិត។ ខ្ញុំរង់ចាំសូរសំឡេងបាញ់បន្ទាប់ដោយភ័យខ្លួនយ៉ាងខ្លាំង។ មិនយូរមិនឆាប់ទ្វាររថភ្លើងរបស់យើងនឹងត្រូវបានបើក ហើយវានឹងដល់វេនរបស់យើងជាមិនខាន។

ប្រៀបបានដូចជារូបចម្លាក់មួយ ខ្ញុំច្របាច់ដៃរបស់លីវី ហើយនៅស្ងៀមធ្មឹងដោយសឹងតែមិនហ៊ានដកដង្ហើមផង។ ប៉ុន្តែមិនមានរឿងអ្វីបានកើតឡើងបន្ទាប់នោះទេ។ មួយនាទីកន្លងផុតទៅ ពីរនាទី បីនាទី បួននាទីបន្ទាប់មកទើបខ្ញុំចាប់ផ្តើមដកដង្ហើមម្តងទៀត។ ខ្ញុំមិនដែលបានដឹងថាអ្នកណាត្រូវបានបាញ់សម្លាប់ ហើយព្រោះតែហេតុអ្វីនោះទេ ប៉ុន្តែបន្ទាប់ពីប៉ុន្មានម៉ោងក្រោយមក រថភ្លើងក៏ចាប់ផ្តើមធ្វើដំណើរម្តងទៀត ក្រោយមកយើងក៏ត្រូវបានគេយកទៅទម្លាក់ចោលនៅវាលមួយដែលព័ទ្ធជុំវិញដោយរបងបន្លាលួស។ មានមនុស្សស្រីម្នាក់ឈរក្បែររបង ខ្ញុំក៏បានសួរនាងថាតើយើងបានមកដល់ទីណា។ នាងបានឆ្លើយប្រាប់ថា «បែលជិន-បឺសិន» ហើយក៏បន្ថែមទៀតថា «មានការងារត្រូវធ្វើ គ្មានទំប៉ុងគ្មានដែស្រងពុល»។ ខ្ញុំធូរចិត្តបន្តិចហើយក៏បានគិតថា «ខ្ញុំនៅមានកម្លាំងធ្វើការបាន ខ្ញុំប្រហែលជាអាចទ្រាំទ្របានមួយរយៈពេលទោះបីជាគ្មានទំប៉ុងក៏ដោយ អ្វីដែលសំខាន់គឺមិនមានបន្ទប់ដែស្រងពុលទេ។ បន្ទាប់មកទើបខ្ញុំដឹងថាពេលនោះគឺថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៤៥។



*ទីតាំងជំរំរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ៍នៃប្រទេសប៉ូឡូញ។ (សូរិចិត្រ មេត្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)*

យើងត្រូវបានគេដាក់ឲ្យស្នាក់នៅក្នុងជំរំស្អាតមួយ។ បន្ទាប់ពីបានរំដោះ ទើបខ្ញុំយល់ថាតើយើងមានសំណាងល្អយ៉ាងណានៅពេលដែលខ្ញុំបានឃើញអំពីស្ថានភាពអាក្រក់របស់ជំរំផ្សេងទៀត។ ជនជាតិជ្វីហ្វមួយក្រុមត្រូវបានយកទៅឃុំឃាំងនៅទីនោះមុនយើង ដើម្បីរង់ចាំការផ្លាស់ប្តូរជាមួយនឹងអ្នកទោសអាល្លឺម៉ង់។ យើងបានជួបជាមួយពួកគេនៅពេលដែលយើងបានមកដល់ជំរំ ហើយពួកគេកំពុងតែដើរសំដៅទៅរថភ្លើង។

មិនត្រឹមតែនំប៉័ងនោះទេដែលមិនមាន សូម្បីតែទឹកក៏មិនមានផឹកដែរ។ យើងមានតែកាហ្វេដែលជួយឲ្យយើងបន្តរស់រានមានជីវិតបាន។ ទឹកពណ៌ខ្មៅនោះត្រូវបានផ្តល់ឲ្យក្នុងរយៈពេលពីរដងក្នុងមួយថ្ងៃ។ យើងដេកនៅលើគ្រែតូចរបស់យើងដោយកាន់តែមានសុខភាពខ្សោយទៅៗ និងគ្មានចាប់អារម្មណ៍អំពីអ្វីទាំងអស់ ហើយរង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ។ មិនយូរប៉ុន្មានក៏មានសំឡេងអ្វីអរចេញមកពីខាងក្រៅ។ ទាហានអង់គ្លេសដែលកំពុងធ្វើដំណើរទៅទីក្រុង បែរឡាំង បានរកឃើញជំរំរបស់យើង ហើយក៏សម្រេចចិត្តចូលមករំដោះយើង។ នៅពេលនោះគឺថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤៥។

ខ្ញុំមានការចងចាំស្រពេចស្រពិលអំពីអ្វីដែលបានកើតឡើងបន្ទាប់។ អ្វីដែលខ្ញុំចាំបានគឺ ខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង។ ខ្ញុំកើតជំងឺគ្រុនពោះវៀន ពីព្រោះតែខ្ញុំបានរត់ទៅគ្រប់កន្លែងដែលមានរបងបន្លាលួសហ៊ុមព័ទ្ធដើម្បីរកមើលឪពុករបស់ខ្ញុំ។ លីវី បានមើលថែខ្ញុំ ហើយខ្ញុំត្រូវអរគុណប្អូនដែលបានជួយជីវិតរបស់ខ្ញុំ។ ប៉ុន្មានខែកន្លងផុតទៅគណៈប្រតិភូរបស់ប្រទេស ស៊ុយអែត បានមកជំរំបែលជិន-បឺសិន ជាមួយនឹងបេសកកម្មក្នុងការនាំជនរងគ្រោះចំនួន១ម៉ឺននាក់ទៅប្រទេសស៊ុយអែតក្នុងរយៈពេល៦ខែ

ដើម្បីព្យាបាលជំងឺ។ លើវីនិងខ្ញុំ គឺនៅក្នុងចំណោមមនុស្សទាំងអស់នោះ។ បន្ទាប់ពីធ្វើដំណើរតាមរថភ្លើងនិងធ្វើការសម្លាប់មេរោគនៅទីក្រុងលូបេក យើងត្រូវបានដាក់នៅលើទូកសង្គ្រោះបន្ទាន់ ដើម្បីបន្តដំណើរទៅទីក្រុងម៉ាលម៉ូក្នុងប្រទេសស៊ុយអែត។ ការធ្វើដំណើរមួយនោះ និងអារម្មណ៍នៃសេរីភាពមួយនោះ ខ្ញុំគ្មានថ្ងៃអាចបំភ្លេចបាននោះទេ។

## តើអ្នកត្រូវបានទទួលនៅប្រទេសស៊ុយអែតយ៉ាងដូចម្តេច?

ទូកដែលនាំយើងទៅដល់ប្រទេសស៊ុយអែតមានឈ្មោះថា "រ៉ូនស្កាវ៉ាន់" ហើយគឺជាទូកដឹកទំនិញដែលបានកែប្រែឲ្យទៅជាទូកសង្គ្រោះបន្ទាន់។ នោះគឺជាបទពិសោធន៍ថ្មីមួយសម្រាប់ខ្ញុំ ពីព្រោះខ្ញុំមិនដែលបានធ្វើដំណើរតាមទូកនោះទេ ហើយក៏មិនដែលបានឃើញសមុទ្រដែរ។ ពេលនោះខ្ញុំត្រូវបានអនុញ្ញាតឲ្យឡើងទៅជាន់លើដើម្បីស្រូបខ្យល់អាកាសសមុទ្រ ហើយខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំងជាមួយទេសភាពសមុទ្រដ៏សែនធំទូលាយនោះ។ ខ្ញុំរីករាយនឹងការធ្វើដំណើរមួយនេះ។ យើងទាំងអស់គ្នាមានក្តីរំពឹងទុកមួយយ៉ាងខ្លាំង។ អ្នកធ្វើដំណើរមកជាមួយដទៃទៀត ព្រមទាំងខ្ញុំមានអារម្មណ៍ថា យើងត្រូវបានជ្រើសរើសសម្រាប់ជីវិតថ្មីមួយដែលយើងនឹងត្រូវបានចាត់ទុកថាជាភ្ញៀវពិសេស ហើយគេនឹងបំពេញគ្រប់តម្រូវការទាំងអស់របស់យើង។ គ្រែរបស់យើងនៅលើទូកនោះក្រាលដោយកម្រាលពណ៌ស ហើយតែងតែបន្លឺសំឡេងរាល់ពេលដែលខ្ញុំធ្វើចលនា។ វាធ្វើឲ្យខ្ញុំមានអារម្មណ៍ពិសេសប្រៀបបានដូចជាខ្លួនឯងគឺជាស្ករសណ្តែកដីមួយគ្រាប់ដែលខ្ចប់ដោយថង់ពណ៌ប្រាក់។ បីយប់បីថ្ងៃបានរំលងផុតទៅយ៉ាងឆាប់រហ័ស យើងទាំងអស់គ្នាមានអារម្មណ៍សប្បាយរីករាយនៅពេលដែលបានទៅដល់ទីក្រុង ម៉ាលម៉ូ។ យើងបានជួបជាមួយ ឡូតូ ដែលជាសមាជិករបស់កងកម្លាំងនារីប្រដាប់អាវុធនៃប្រទេស ស៊ុយអែត ដែលបានយកទឹកកាកាវ និងសាំងវិចឲ្យយើងបរិភោគ។ យើងគិតថា ខ្លួនឯងបានមកដល់ឋានសួគ៌ហើយ មិនដែលឆ្អែតជាមួយនឹងសាំវិចព្រមទាំងទឹកកាកាវ ដែលល្អវិសេសនោះទេ។ ចាប់តាំងពីពេលនោះមក ទឹកកាកាវប្រៀបបានដូចជានិមិត្តសញ្ញាដែលបញ្ជាក់អំពីអំពើល្អរបស់ប្រទេសស៊ុយអែត។ ពីកំពង់ផែមក យើងធ្វើដំណើរតាមរថអគ្គិសនីទៅសាលារៀនលីនៀអឹស គឺជាកន្លែងដែលគេបានទទួលយើងឲ្យស្នាក់នៅ។ អ្វីដែលខ្ញុំចងចាំជាងគេ គឺមុខម្ហូបនៅទីនោះ។ អាហារដ៏ឆ្ងាញ់គឺសាច់គោដុំជាមួយនឹងរំដេង និងអាហារចម្អែក ក៏ប៉ុន្តែមានរស់ជាតិឆ្ងាញ់ដូចគ្នាហៅថា បង្អែមសង់ខ្យារពណ៌ខ្មៅជាមួយនឹងលីនង៉ិនបឺរី។ យើងបរិភោគហើយបរិភោគទៀត តែយើងមិនដែលឆ្អែតទាល់តែសោះ។ អាហារ គឺជាពន្លឺមួយនៅក្នុងជីវិតរបស់យើង ហើយ យើងរីករាយនឹងវាយ៉ាងខ្លាំង។ គេផ្តល់អាហារឲ្យយើងមួយថ្ងៃប្រាំដង ប៉ុន្តែយើងតែងតែខ្លាចថាវានឹងមិនគ្រប់គ្រាន់នោះទេ។ គ្នាយើងមួយចំនួនធំបានលួចយកអាហារពីសាលបរិភោគអាហារ ហើយលាក់ទុកនៅក្រោមខ្នើយដេក។ ទោះបីជាគេអនុញ្ញាតឲ្យយើងបរិភោគសាំងវិចក្នុងចន្លោះពេលអាហារ ឬពាក្យធានាយ៉ាងអត់ធ្មត់ពីក្រុមការងារថា នឹងតែងតែមានអាហារគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏មិនអាចបញ្ឈប់យើងបានដែរ។ ក្នុងករណីនេះខ្ញុំអាចប្រាប់អ្នកបានថាសេចក្តីស្រេកឃ្លានបានប៉ះពាល់យើងអស់មួយជីវិត។ អ្នករស់រានមានជីវិតមួយចំនួនមានជំងឺមិនឃ្លានអាហារ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏គ្នាយើងមួយចំនួនធំ គឺតែងតែទិញអាហារយ៉ាងច្រើនលើសលប់ដាក់នៅក្នុងទូរទឹកកក។

អ្នកនៅតំបន់នោះបានឈរផ្តុំគ្នានៅក្រៅរបងសាលារៀនដើម្បីរង់ចាំមើលអ្នកដែលរួចរានមានជីវិតពីជំរំបែលជិន-បឺសិន ប៉ុន្តែយើងបានហាមឃាត់មិនឲ្យទៅជិតអ្នកទាំងនោះទេ។ យើងត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកពីគេ ដើម្បីការពាររោគឆ្លងអស់រយៈពេលប្រាំមួយសប្តាហ៍ បន្ទាប់មកទើបត្រូវបានអនុញ្ញាតឲ្យមានទំនាក់

ទំនងជាមួយជនជាតិស៊ុយអែតនៅខាងក្រៅៗ ជនជាតិស៊ុយអែតទាំងនោះ មានចិត្តល្អ និងមានការជឿងឆ្ងល់ច្រើនៗ អ្នកខ្លះឲ្យកាដូយើងបន្តិចបន្តួច ប៉ុន្តែគេមិនចង់ដឹងរឿងរបស់យើងទេ។ យើងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅៗ នៅពេលនោះ គឺមិនទាន់ជាពេលវេលាសមស្របមួយសម្រាប់មនុស្ស ដើម្បីបង្ហាញអំពីការប្រកាន់ពូជសាសន៍របស់ខ្លួន ការរៀនសូត្រតាមណាហ្ស៊ី ឬក៏ការប្រឆាំងនឹងជនជាតិជ្វីហ្វនោះទេ។ ទាំងអស់នេះត្រូវបានគេបំភ្លេចចោលៗ រហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៨០ ទើបណាហ្ស៊ីនិយមបានរីករាលដាលម្តងទៀតៗ នៅពេលដែលខ្ញុំគិតអំពីសព្វថ្ងៃនេះ ខ្ញុំនៅតែអាចឃើញគំរូនេះដដែលៗ មនុស្សមានចិត្តអាណិតអាសូរ ចង់ជួយ ចង់ចែករំលែកភាពរីបូណ៌ ប៉ុន្តែនៅពេលណាដែលមានសំណួរទាក់ទងអំពីការលះបង់ ឬក៏លះបង់ពេលវេលារបស់នរណាម្នាក់ ការជួយគ្នាទៅវិញទៅមកបានក្លាយទៅជារឿងមួយដែលពិបាកធ្វើទៅវិញៗ

យើងមានអារម្មណ៍ស្វាគមន៍នៅក្នុងប្រទេសស៊ុយអែតៗ ប៉ុន្តែបន្ទាប់ពីសេចក្តីរីករាយបានបញ្ចប់ទៅហើយ យើងបានជួបប្រទះការលំបាកជាលើកដំបូងលើវី និងខ្ញុំបានចាប់ផ្តើមគិតអំពីការចាកចេញពីប្រទេសមួយនេះ ។ ប៉ុន្តែយើងចាប់ផ្តើមទម្លាប់ខ្លួនជាមួយនឹងប្រទេសស៊ុយអែតទៅហើយ ដូចគ្នាទៅនឹងប្រទេសស៊ុយអែតដែលកំពុងតែចាប់ផ្តើមទទួលស្គាល់យើងៗ យើងដឹងថាគ្មានឋានសួគ៌ពិតនៅលើពិភពលោកនេះទេៗ នៅប្រទេសស៊ុយអែត ក៏ដូចជាប្រទេសដទៃទៀតដែរ មានរឿងខ្លះល្អ ឯរឿងខ្លះទៀតអាក្រក់ៗ ប៉ុន្តែបច្ចុប្បន្ននេះខ្ញុំមានអារម្មណ៍ថាកក់ក្តៅដូចជានៅក្នុងផ្ទះរបស់ខ្លួនៗ

## តើមានការលំបាកក្នុងការសម្របខ្លួនទៅនឹងជីវិតនៅប្រទេសស៊ុយអែតដែរឬទេ?

សំណួរមួយដែលខ្ញុំត្រូវបានសួរជាច្រើនឆ្នាំគឺ តើវាចំណាយអស់រយៈពេលយូរដែរឬទេដើម្បីរៀនអំពីរបៀបរបស់ប្រទេសស៊ុយអែត?ៗ ការសន្និដ្ឋានរបស់ខ្ញុំគឺមិនមានអ្វីដែលហៅថាគុណតម្លៃរបស់ប្រទេសស៊ុយអែតទេៗ នៅប្រទេសស៊ុយអែតខ្ញុំបានឃើញអំពីគុណតម្លៃដែលខ្ញុំបានដឹងពីស្រុកកំណើតរបស់ខ្ញុំ និងពីប្រទេសប្រជាធិបតេយ្យដទៃទៀតៗ គោលការណ៍ចម្បងនោះ គឺមិនឲ្យមានឃាតកម្មមិនឲ្យមានការលួច មិនត្រូវធ្វើអ្វីទៅលើអ្នកដទៃនូវអ្វីដែលអ្នកមិនចង់ឲ្យអ្នកដទៃធ្វើមកលើអ្នក ហើយគោលការណ៍ទាំងនេះអាចរកឃើញនៅក្នុងពាក្យខុសៗគ្នា និងភាសាខុសៗគ្នានៅគ្រប់សាសនា ទាំងអស់ក្នុងពិភពលោកៗ

សញ្ញាណនៃ«គុណតម្លៃ» គឺទូលំទូលាយណាស់ ហើយជាញឹកញាប់ត្រូវបានយល់ច្រឡំជាមួយ «វប្បធម៌»ៗ ខ្ញុំមកពីវប្បធម៌ដែលពោរពេញទៅដោយភាពអាម៉ាស់ ហើយនៅក្នុងឆ្នាំ១៩៨៥ ខ្ញុំបានជួបនឹងប្រទេសស៊ុយអែតដែលកសាងឡើងនៅលើវប្បធម៌ដែលមានពិរុទ្ធភាពមួយៗ ខ្ញុំយល់ដឹងច្រើននៅពេលមានសកម្មភាពមួយចំនួនត្រូវបានគេបញ្ចេញមតិដោយពាក្យថា «យើងមិនធ្វើបែបនេះនៅក្នុងប្រទេសស៊ុយអែតទេ»ៗ ផ្កាដែលដុះតាមរបងរបស់អ្នកជិតខាងគឺមិនត្រូវបេះទេ នៅពេលណាដែលយើងត្រូវបានគេអញ្ជើញឲ្យទៅញ៉ាំអាហារពេលល្ងាច គឺយើងមិនអាចទៅយឺតបានទេ មិនអាចចូលផ្ទះ ដោយមិនដោះស្បែកជើងទេ ហើយនៅមានជាច្រើនបន្តទៀតៗ នៅពេលដែលបានមកដល់ប្រទេសស៊ុយអែតលើកដំបូង មានរឿងច្រើនណាស់ដែលខ្ញុំពុំបានដឹង ព្រមទាំងទាល់គំនិតៗ ប៉ុន្តែនេះគឺជាផ្នែកមួយនៃវប្បធម៌ប្រទេសស៊ុយអែត ហើយគឺមិនមែនជាគុណតម្លៃរបស់ប្រទេសស៊ុយអែតនោះទេៗ

អ្វីដែលខ្ញុំពិបាកយល់ជាងគេនោះគឺ នៅពេលដែល «បាទ/ចាស» មានន័យថាប្រហែលជាហើយ «ប្រហែលជា» មានន័យថា «ទេ»ៗ ខ្ញុំចងចាំអំពីកំហុសដំបូងរបស់ខ្ញុំ ហើយនោះគឺជាបទល្មើសទៅលើវប្បធម៌ជាជាងការរំលោភបំពានទៅលើគុណតម្លៃៗ ទម្លាប់នៅលើតុអាហារក៏ខុសគ្នាពីអ្វីដែលខ្ញុំបានដឹងៗ



*ផែនទីនៃជំរំហ្គេតូៗ ប្រជាជនបានយកផ្កាមកដាក់នៅកន្លែងផែនទីតំណាងជំរំហ្គេតូ នេះដើម្បីឧទ្ទិសដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតៗ តាមបញ្ជារបស់យោធាអាល្លឺម៉ង់ ហ្គេតូ ត្រូវបានផ្តាច់ចេញពីទីក្រុងផ្សេងៗទៀតនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៤០ៗ ជំរំហ្គេតូ ហ៊ុំព័ទ្ធដោយរបង និងមានផ្ទៃក្រឡាទំហំ៣០៧ហិកតាៗ ជំរំនេះចាប់ដំណើរការនៅខែមករា ឆ្នាំ១៩៤២ៗ ជំរំហ្គេតូ ត្រូវបានបែងចែកជាពីរគឺ ជំរំហ្គេតូតូច និងជំរំហ្គេតូធំៗ មានជនជាតិជ្វីសនៅក្រុងវីរសប្រមាណ៣៦០០០០ និងមកពីទីកន្លែងផ្សេងទៀតនៅក្នុងទីក្រុង ត្រូវបានដាក់ឲ្យនៅក្នុងជំរំហ្គេតូៗ ជនជាតិជ្វីសប្រមាណ ១០០០០០នាក់បានស្លាប់នៅក្នុងជំរំនេះដោយសារអត់ឃ្លានៗ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ថ្ងៃមួយខ្ញុំត្រូវបានគេអញ្ជើញឲ្យទៅញ៉ាំអាហារពេលល្ងាចៗ ខ្ញុំបានចេញពីផ្ទះមុនពេលកំណត់ ហើយបានដើរទៅដើរមកនៅមុខផ្ទះរបស់គេរហូតទាល់តែកណ្តឹងរបស់វិហារឲ្យសញ្ញាថាម៉ោង៦ៗ

ខ្ញុំមិនហ៊ានចូលទៅមុនម៉ោងនោះទេៗ នៅពេលដែលម្ចាស់ផ្ទះបានឲ្យចានអាហារមកខ្ញុំ ខ្ញុំយកតែបន្តិចបន្តួចតែប៉ុណ្ណោះ ដើម្បីបង្ហាញអំពីអាកប្បកិរិយាល្អ ព្រោះខ្ញុំយល់ថាជាធម្មតាម្ចាស់ផ្ទះគួរតែទទូចឲ្យអាហារមកខ្ញុំជាច្រើនដងហើយពេលខ្លះទៀតក៏គួរតែបង្ខំដែរៗ ប៉ុន្តែនៅប្រទេសស៊ុយអែតគេមិនបង្ខំភ្ញៀវឲ្យហូបអាហារទេៗ ដូច្នេះ ហើយខ្ញុំក៏ចាកចេញពីតុអាហារទាំងពោះមិនទាន់ឆ្អែតៗ

នៅប្រទេសស៊ុយអែត ខ្ញុំបានរៀនពីការឆ្លើយតបជាមួយនឹងពាក្យថា «អរគុណ» ដោយអៀនខ្មាសនៅពេលដែលគេអោយអ្វីមួយៗ គឺត្រូវតែជា «បាស» ឬ «អត់ទេ»ៗ

នៅពេលដែលខ្ញុំមានភ្ញៀវ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលខ្ញុំឮគេប្រើពាក្យថា «មានមនុស្សចម្លែកចូលមកក្នុងផ្ទះ»ៗ ហេតុអ្វីបានជាជនជាតិស៊ុយអែតហៅមិត្តរបស់ខ្លួនថាជាមនុស្សចម្លែក? តើនេះឬគឺជាគុណតម្លៃរបស់ប្រទេសស៊ុយអែត?

ក្នុងរដូវក្តៅមួយ ខ្ញុំបានធ្វើការនៅលើនាវាទេសចរណ៍មួយដែលធ្វើដំណើរទៅតាមប្រជុំកោះៗ ភារកិច្ចរបស់ខ្ញុំគឺសម្អាតបន្ទប់របស់នាយនាវា និងបម្រើអាហារនៅក្នុងភោជនីយដ្ឋានរបស់នាវាៗ ខ្ញុំបានខំប្រឹងធ្វើការឲ្យបានល្អបំផុតតាមដែលខ្ញុំអាចធ្វើទៅបានៗ ប៉ុន្តែនៅពេលចុងខែ ខ្ញុំមិនបានទទួលប្រាក់ឈ្នួលរបស់ខ្ញុំទេ ហើយបែរជាទទួលនូវពាក្យពន្យល់មួយថា ខ្ញុំគឺជាអ្នកសម្អាតដែលធ្វេសប្រហែសៗ នេះគឺជាការពិត ហើយខ្ញុំមានការអៀនខ្មាសយ៉ាងខ្លាំង ប៉ុន្តែប្រសិនបើពេលនោះខ្ញុំត្រូវបានគេរិះគន់ខ្ញុំប្រហែលជាព្យាយាមខ្លាំងជាងនេះៗ នៅពេលដែលខ្ញុំលើកឡើងអំពីចំណុចនេះ ចៅហ្វាយរបស់ខ្ញុំបាននិយាយថានៅ ប្រទេសស៊ុយអែត យើងមិនរិះគន់បុគ្គលិកនោះទេៗ អ្នកដែលមិនបានបំពេញការងាររបស់ខ្លួនឲ្យបានល្អត្រឹមត្រូវគឺមិនទទួលបានប្រាក់ខែទេៗ

ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនដើម្បីរៀនរស់នៅក្នុងវប្បធម៌របស់ប្រទេសស៊ុយអែត ប៉ុន្តែខ្ញុំបានយកគុណតម្លៃមូលដ្ឋានមួយមកជាមួយខ្ញុំៗ ជាច្រើនឆ្នាំមកនេះ មានការហូរចូលនៃជនអន្តោប្រវេសន៍ជាច្រើន ហើយយើងក៏អាចតាមដានការផ្លាស់ប្តូរវប្បធម៌តាមរយៈនេះបានដែរៗ ប្រទេសស៊ុយអែតបានបើកនិង

ផ្តល់ឱកាសឲ្យជនអន្តោប្រវេសន៍ ហើយអ្នកទាំងនោះបានសម្របខ្លួនទៅតាមមជ្ឈដ្ឋានថ្មីមួយនោះដែរ។ ជនអន្តោប្រវេសន៍ទាំងនោះបានទទួលយកវប្បធម៌របស់ប្រទេសស៊ុយអែត ក្នុងខណៈពេលដែលប្រទេសស៊ុយអែតកាន់តែរីកចម្រើនដោយសារតែការចូលរួមអភិវឌ្ឍន៍របស់ជនបរទេសទាំងអស់នោះ។

នេះគឺមិនមែនជាគុណតម្លៃរបស់ជនជាតិស៊ុយអែតទេដែលធ្វើឲ្យវិធីនៃការធ្វើសមាហរណកម្ម ទទួលបានជោគជ័យ ប៉ុន្តែគឺជាសំណួរដែលចោទទៅលើគោលបំណងល្អរបស់មនុស្សទៅវិញទេ។ ទាំងនេះមិនអាចកើតឡើងបានដោយឆាប់រហ័សទេ ជាពិសេសនៅពេលដែលដំណើរការរបស់អាជ្ញាធរមានភាពយឺតយ៉ាវនៅឡើយ។ ដូច្នេះហើយទើបមានសារសំខាន់ខ្លាំងណាស់ ក្នុងការកាត់បន្ថយរយៈពេលរង់ចាំ និងបង្កើនឱកាសសម្រាប់ប្រជាជនស៊ុយអែត និងជនអន្តោប្រវេសន៍វ័យក្មេងជួបជុំគ្នា និងទទួលស្គាល់គ្នាទៅវិញទៅមកនៅក្រោមកាលៈទេសៈមួយដែលសប្បាយរីករាយ។

ការខិតខំប្រឹងប្រែងនីមួយៗជាធម្មតា តែងតែផ្តល់ផលប្រយោជន៍ដ៏ល្អប្រសើរមួយ។ ប្រទេសស៊ុយអែតក៏អាចក្លាយទៅជាទីកន្លែងមួយដែលប្រមូលផ្តុំដោយជាតិសាសន៍ជាច្រើន ប្រសិនបើរដ្ឋាភិបាលបង្កើតកិច្ចខិតខំប្រឹងប្រែងដែលអាចប្រមូលផ្តុំជនអន្តោប្រវេសន៍ និងជនជាតិស៊ុយអែតតាមរយៈសកម្មភាពកម្សាន្តជាច្រើន។

## តើអ្នកដោះស្រាយជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តបានដោយរបៀបណា?

ខ្ញុំសំណាងល្អដែលអាចមកប្រទេសស៊ុយអែតនៅរដូវក្តៅក្នុងឆ្នាំ១៩៨៥។ ប៉ុន្តែវានៅតែជាពេលវេលាមួយដែលលំបាក។ ខ្ញុំឈឺចាប់ដោយសារតែបានបាត់បង់គ្រួសារមួយទាំងមូលលើកលែងតែប្អូនស្រីរបស់ខ្ញុំ។ ខ្ញុំបានទទួលរងទារុណកម្មផ្លូវចិត្ត ពីព្រោះខ្ញុំគិតអំពីឪពុកម្តាយរបស់ខ្ញុំដែលត្រូវបានគេសម្លាប់ក្នុងអំឡុងពេលដែលខ្ញុំរួចជីវិត។

## តើមានប៉ុន្មាននាក់ដែលអាចរស់រានមានជីវិតនៅក្នុងចំណោមសមាជិកគ្រួសារទាំង ៥៦នាក់ របស់ខ្ញុំ?

ពាក្យថា «ការប៉ះទង្គិចផ្លូវចិត្ត» ត្រូវបានគេស្គាល់មិនច្បាស់លាស់ទេ ហើយគ្មាននរណាម្នាក់បានដឹងអំពីដំណើរការនៃ «ការប៉ះទង្គិចផ្លូវចិត្ត» នោះដែរ។ ការយល់ដឹងថាមនុស្សម្នាក់អាចរងទុក្ខពីការប៉ះទង្គិចផ្លូវចិត្តបានយូរអង្វែងត្រូវបានគេចាប់អារម្មណ៍នៅពេលដែលអ្នករស់រានមានជីវិត កាន់តែច្រើនបានចាប់ផ្តើមត្អូញត្អែរអំពីបញ្ហាសុខភាព។ ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី១ ទាហានមួយចំនួនបានរងទុក្ខដោយសារតែអ្វីៗដែលខ្លួនបានជួបប្រទះនៅក្នុងសង្គ្រាម។ ប៉ុន្តែអស់រយៈពេលជាយូរ ការរងទុក្ខនេះមិនត្រូវបានចាត់ទុកថាជាជំងឺផ្លូវចិត្តនោះទេ។ វាត្រូវបានគេហៅថា «ភាពភ្ញាក់ផ្អើល» ហើយទាហានត្រូវបានបញ្ជូនទៅសមរភូមិដូចធម្មតាវិញ។ នៅពេលដែលរោគសញ្ញាទាំងនោះវិលត្រឡប់មកវិញ ទាហានទាំងនោះត្រូវបានចោទប្រកាន់ថាធ្វើពុតជាឈឺ។

## តើអ្វីដែលជំរុញឱ្យអ្នកចាប់ផ្តើមបង្រៀន?

ទីបំផុតខ្ញុំបានយល់ថា ខ្ញុំរស់រានមានជីវិតពីព្រោះតែខ្ញុំដឹងថាត្រូវតែមាននរណាម្នាក់មានជីវិតដើម្បីប្រាប់អំពីរឿងរ៉ាវដែលបានកើតឡើងនៅហូឡូខស្ត៍។ ប្រសិនបើគ្មាននរណាម្នាក់និយាយអំពីអ្វីដែលបានកើតឡើងនៅហូឡូខស្ត៍ទេនោះ អ្វីៗនឹងត្រូវបានបំភ្លេចចោល ហើយអ្វីដែលត្រូវបានបំភ្លេចចោល ហើយនោះអាចនឹងកើតឡើងម្តងទៀតបានយ៉ាងងាយស្រួល។ ប្រសិនបើហូឡូខស្ត៍សាបរលាបបាត់ដោយគ្មាននរណាម្នាក់ចងចាំជនជាតិជ្វីហ្វចំនួន៦លាននាក់ និងកុម្មុយនីស្តជាច្រើននាក់ព្រមទាំងអ្នកដែលស្រឡាញ់ភេទដូចគ្នា មនុស្សពិការ ជនជាតិរ៉ូម៉ាំង និងអ្នកដទៃទៀតដែលត្រូវបានចាត់ទុកថាមិនមានតម្លៃស្មើនឹងមនុស្សនោះ នឹងបាត់បង់ជីវិតដោយគ្មាននរណាម្នាក់ចងចាំអំពីពួកគេឡើយ។ លើកទី១ដែលខ្ញុំ

ដឹង គឺនៅពេលដែលមានគ្រូម្នាក់បានហៅខ្ញុំឲ្យទៅនិយាយនៅសាលារបស់គាត់។

នៅពេលដែលខ្ញុំចូលនិវត្តន៍ នៅដើមឆ្នាំ១៩៨០ ខ្ញុំបានចាប់ផ្តើមសរសេរសៀវភៅអំពីអ្វីដែលបានកើតឡើង។ សៀវភៅដំបូងគឺ ដំណើរទៅអូសឈ្វិច ៖ បំណែកនៃជីវិត (បកប្រែជាភាសាអង់គ្លេសដោយ មៃយែល មេយឺ) ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានបង្រៀនអស់រយៈពេលជាច្រើនឆ្នាំ ហើយខ្ញុំធ្វើដូច្នេះដោយសារតែមូលហេតុពីរ គឺ បែបនេះឈ្មោះ ហ្វ្រីដា ឃ្លៃន ស្មាក់ (Frida Klein Szmuk) និងអ៊ីហ្គាណាត់ ស្មាក់ (Ignatz Szmuk) នឹងនៅតែមានក្នុងការចងចាំ ហើយដូច្នេះអ្នកជំនាន់ក្រោយអាចយកមេរៀនរបស់ហូឡូខសត៍ដាក់ក្នុងដួងចិត្តរបស់ខ្លួនទើបអ្នកទាំងនោះនឹងមិនមានបទពិសោធន៍ដូចអ្វីដែលខ្ញុំបានឆ្លងកាត់។

ក្មេងជំទង់ជារឿយៗមានការលំបាកនៅពេលដែលជួបសំណួរអំពីអត្ថន័យនៃជីវិតរបស់ខ្លួន។ អ្នកខ្លះជួបរឿងបែបនេះដោយពេលខ្លះសូម្បីតែមិនធ្លាប់បានឆ្លងកាត់សង្គ្រាម និងការធ្វើបាបយាយីក៏ដោយ។ ខ្ញុំសូមបកស្រាយពាក្យអ្នកនិពន្ធជនជាតិសូម៉ាលីម្នាក់ដែលមានឈ្មោះថា ណូរូឌីន ហ្វារ៉ា។ គាត់បាននិយាយថាអត្ថន័យនៃជីវិត គឺធ្វើអំពើល្អ និងជួយអ្នកជិតខាង ព្រោះវាក៏ធ្វើឲ្យអ្នកមានអារម្មណ៍ល្អដូចគ្នាដែរ។ សម្រាប់ខ្ញុំៗជឿថា អត្ថន័យនៃជីវិត គឺជីវិតនោះឯង។

## តើអ្នកមានអារម្មណ៍ថាជាជនជាតិស៊ុយអែតដែរឬទេ?

សំណួរដែលសួរថា តើខ្ញុំមានអារម្មណ៍ថាជាជនស៊ុយអែតដែរឬទេ គឺពិតជាស្មុគស្មាញណាស់។ វាលើកឡើងនូវសំណួរជាច្រើនទៀតថា តើខ្ញុំជាអ្នកណា? តើកន្លែងណាដែលខ្ញុំមានអារម្មណ៍ថាគឺជាផ្ទះ? តើខ្ញុំគួរតែនៅកន្លែងណា? តើវាគឺជាកន្លែងដែលខ្ញុំកើត ឬក៏ជាកន្លែងដែលខ្ញុំធំធាត់? តើវាគឺជាកន្លែងដែលខ្ញុំមានគ្រួសារ ការងារ ឬតើវាទាក់ទងនឹងសញ្ជាតិ ជាតិសាសន៍ ឬក៏សាសនាដែលខ្ញុំគោរព? ដើម្បីឈានទៅដល់ការឆ្លើយសំណួរទាំងនេះគឺត្រូវការពេលវេលាជាច្រើន។

ខ្ញុំកើតនៅក្នុងប្រទេស រូម៉ានី ក្នុងគ្រួសារជនជាតិជ្វីហ្វមួយដែលនិយាយភាសាហុងគ្រី។ ជាកូនក្មេងម្នាក់ វាគឺជារឿងធម្មតានោះទេដែលក្មេងៗដទៃទៀតនិយាយភាសាផ្សេងពីខ្លួន បរិភោគម្ហូបអាហារផ្សេង ហើយស្លៀកសម្លៀកបំពាក់ផ្សេងៗ។ យើងលេងជាមួយគ្នាហើយយោគយល់គ្នាទៅវិញទៅមក។ នៅពេលដែលខ្ញុំទៅសាលារៀនទើបខ្ញុំដឹងថា ក្រុមខ្លះត្រូវបានចាត់ទុកថាល្អជាងក្រុមដទៃទៀត។ យើងត្រូវបានគេដាក់ទោសដោយសារតែយើងនិយាយភាសាផ្សេងទៀតក្រៅពីរូម៉ានី។ ថ្ងៃដំបូងនៅសាលារៀន ខ្ញុំត្រូវបានគ្រូវាយដែលធ្វើឲ្យមានស្នាមក្រហមលើបាតដៃរបស់ខ្ញុំ ព្រោះតែខ្ញុំនិយាយភាសាផ្សេងទៀត។ ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់មក ខ្ញុំបានជៀសផុតពីការត្រូវវាយពាត់បានច្រើនក៏ពិតមែនប៉ុន្តែជារឿយៗប្រាក់ប្រចាំសប្តាហ៍របស់ខ្ញុំត្រូវបានបាត់បង់ ពីព្រោះខ្ញុំត្រូវបង់ប្រាក់នៅពេលណាដែលខ្ញុំត្រូវចាប់បានថានិយាយភាសាហុងគ្រី។ យើងត្រូវបានពិន័យ ១ឡេអ៊ូ ក្នុងមួយពាក្យ។ គោលបំណងរបស់ប្រទេសរូម៉ានី គឺប្រើខ្សែតីដើម្បីធ្វើឲ្យក្រុមជនជាតិភាគតិចទាំងអស់ក្លាយទៅជាជនជាតិរូម៉ានីពេញលេញ។ នៅក្នុងផ្នែកខ្លះវិធីនេះទទួលបានជោគជ័យ។ នៅពេលហុងគ្រីបានចូលមកគ្រងស៊ីលវ៉ានីក្នុងឆ្នាំ១៩៤២ ខ្ញុំគឺជាអ្នកជាតិនិយមរូម៉ានីពេញទំហឹងបាត់ទៅហើយ។ ពេលនោះប្រទេសហុងគ្រី ចង់ឲ្យយើងប្រែទៅជាអ្នកជាតិនិយមហុងគ្រីវិញ ពួកគេថែមទាំងបានប្រើឧបករណ៍ដូចគ្នាទៀតផងហើយនោះគឺ ខ្សែតី។

នៅពេលដែលខ្ញុំបានមកដល់ប្រទេសស៊ុយអែតដំបូង ខ្ញុំមិនបានដឹងថាតើខ្ញុំជាអ្នកណានោះទេ។ ខ្ញុំមកពីពិភពមួយ ដែលយើងមិនត្រូវបានគេរាប់បញ្ចូលថាជាមនុស្ស។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺភាពងាយស្រួលក្នុងការមើលខ្លួនឯងតាមរយៈខ្សែភ្នែករបស់អ្នកដទៃ។ ប្រសិនបើអ្នកដទៃគិតថាខ្ញុំល្អ ខ្ញុំមានអារម្មណ៍ល្អ ប្រសិនបើអ្នកដទៃគិតថាខ្ញុំមិនល្អ ខ្ញុំមានអារម្មណ៍មិនល្អ។ ដូចជាអ្នកដទៃដែរ ខ្ញុំត្រូវការឃើញភាពអះអាងតាមរយៈខ្សែភ្នែករបស់ជនជាតិស៊ុយអែតជាមុនសិន មុននឹងខ្ញុំ

អាចឆ្លើយតបបានថាតើខ្ញុំជាអ្នកណា។ ខ្ញុំមកពីត្រង់ស៊ីលវ៉ានី ដែលពេលនោះ គឺជាផ្នែកមួយរបស់ប្រទេសហុងគ្រី។ ដូច្នេះហើយបានជាខ្ញុំត្រូវបានចាត់ទុកថា ជាជនជាតិហុងគ្រី-ជ្វីហ្វ ។ ប៉ុន្តែ ប្រទេសហុងគ្រីនោះហើយគឺជាពេជ្ឈឃាតរបស់យើងទៅវិញទេ។ ប្រទេសហុងគ្រីបានបញ្ជូនយើងទៅឲ្យប្រទេសអាល្លឺម៉ង់។ ដូច្នេះ ហើយបានជាខ្ញុំមិនចង់ប្រកាសថាខ្លួនឯងគឺជាជន ជាតិហុងគ្រី-ជ្វីហ្វនោះទេ។

កាលពីក្មេងខ្ញុំចង់ចាត់ទុកខ្លួនឯងថាគឺជាជនជាតិរូម៉ានី។ ប៉ុន្តែអ្វីដែលខ្ញុំទទួលបាន គឺមានតែការបដិសេធតាមរយៈខ្សែភ្នែករបស់អ្នកជិតខាងយើង ដែលជាជនជាតិរូម៉ានី ។ ខ្ញុំក៏មិនបានក្លាយទៅជាជនជាតិហុងគ្រីនៅពេលដែលខ្ញុំមកដល់ប្រទេសហុងគ្រីដែរ។ ខ្ញុំបានជួបការបដិសេធនោះដដែលទោះបីជាខ្ញុំប៉ងប្រាថ្នាយ៉ាងណាក៏ដោយ។ នៅពេលដែលខ្ញុំបានមកដល់ប្រទេសស៊ុយអែតខ្ញុំមិនមែនជាអ្វីទាំងអស់។ តើខ្ញុំនឹងអាចក្លាយទៅជាជនជាតិស៊ុយអែតដែរឬទេ? ខ្ញុំសង្ឃឹមថាដូច្នេះ។ ដរាបណាខ្ញុំរៀនភាសាហើយរកការងារបានធ្វើ ខ្ញុំគិតថាខ្ញុំប្រហែលជាអាចក្លាយទៅជនជនជាតិស៊ុយអែតបាន។

អារម្មណ៍នៃការទទួលស្គាល់កើតមានឡើងដោយសារតែទំនាក់ទំនងរវាងការទទួលស្គាល់យ៉ាងបើកចំហរពីសហគមន៍ និងឆន្ទៈក្នុងការសម្របខ្លួន។ ឆន្ទៈក្នុងការសម្របខ្លួនមាននៅក្នុងខ្លួនរបស់ខ្ញុំតាំងពីដំបូង។ វាគឺពិតជាអស្ចារ្យណាស់ដែលបានទទួលស្វាគមន៍ពីសង្គមស៊ុយអែតនៅពេលយើងទៅដល់ទីក្រុងម៉ាលម៉ូ ប៉ុន្តែគួរឲ្យសោកស្តាយដែលអារម្មណ៍បែបនេះមិនមានរយៈពេលយូរ។ ពេលវេលាកន្លងផុតទៅទើបខ្ញុំដឹងថាខ្ញុំបានយល់ច្រឡំសេចក្តីអាណិតពីបុគ្គលម្នាក់ៗថា គឺជាការស្វាគមន៍ទៅវិញ។ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនឆ្នាំទើបខ្ញុំបានយល់ដឹងច្បាស់។ មកដល់ពេលនោះ ខ្ញុំមានការងារធ្វើ និងបានចាប់ផ្តើមរៀនភាសាស៊ុយអែត ប៉ុន្តែខ្ញុំនៅតែត្រូវបានគេចាត់ទុកថាជាជនបរទេស និងនៅតែជាប់ឈ្មោះបែបនេះរហូតទាល់តែខ្ញុំទទួលបានសញ្ជាតិពេញលេញ។ ខ្ញុំដឹងថាខ្ញុំមិនមែនជាជនជាតិស៊ុយអែតនោះទេប្រសិនបើមិនមានសញ្ជាតិពេញលេញ។ ខ្ញុំត្រូវរង់ចាំរយៈពេល៧ឆ្នាំជាមុនសិនមុននឹងទទួលបានសញ្ជាតិជាជនជាតិស៊ុយអែត។

ជាច្រើនឆ្នាំបានកន្លងផុតទៅ ខ្ញុំរៀបការហើយមានកូន៣នាក់។ មកដល់ពេលនេះខ្ញុំមានកន្លែងជាក់លាក់ និងមានផ្ទះជារបស់ខ្លួននៅក្នុងប្រទេសស៊ុយអែត ហើយក៏បានចាប់ផ្តើមចាត់ទុកថាខ្លួនឯងគឺជាជនជាតិស៊ុយអែតម្នាក់។ ប៉ុន្តែសង្គមស៊ុយអែត នៅតែមានគំនិតផ្សេង ខ្ញុំនៅតែជាជនអន្តោប្រវេសន៍ម្នាក់។ ខ្ញុំនិងប្តីរបស់ខ្ញុំដែលមកពីតំបន់ផ្សេងពីគ្នាបានខិតខំប្រឹងប្រែងធ្វើការ និងចូលរួមអភិវឌ្ឍន៍សង្គមរបស់ប្រទេសស៊ុយអែត។

មកដល់សព្វថ្ងៃនេះ ខ្ញុំបានចាត់ទុកខ្លួនឯងថាជាជនជាតិស៊ុយអែត ប៉ុន្តែខ្ញុំមិនហ៊ាននិយាយឲ្យឮខ្លាំងនៅចំពោះមុខអ្នកដែលខ្ញុំមិនស្គាល់នោះទេ។ ដោយសារតែភាពឈឺចាប់យ៉ាងខ្លាំង ប្រសិនបើគេបដិសេធជាមួយនឹងទឹកមុខដែលបង្ហាញថា «អ្នកមិនមែនជាជនជាតិរបស់យើងនោះទេ អ្នកគឺជាជនអន្តប្រវេសន៍ ហើយយើងអាចទទួលអ្នកថា ជាជនអន្តោប្រវេសន៍នៅក្នុងប្រទេសស៊ុយអែតបាន»។

ទោះបីជាយ៉ាងណាក៏ដោយ អ្វីៗបានប្រែប្រួលបន្តិចបន្តួចតាំងពីពេលដែលយើងមកដល់ប្រទេសស៊ុយអែតលើកដំបូង។ ឥឡូវនេះមនុស្សកាន់តែច្រើនបានមករកខ្ញុំដោយមិនមានទឹកមុខសង្ស័យដែលបង្ហាញថា «តើអ្នកជាអ្នកណា អ្នកមិនមែនជាជនជាតិរបស់យើងទេ?» មនុស្សជាច្រើនបានចាប់ផ្តើមបោះបង់ចោលបុរេវិនិច្ឆ័យរបស់ខ្លួន ហើយខ្ញុំសង្ឃឹមថា នឹងមិនមានបន្តទៀតនោះទេ។ បែបនេះអាចធ្វើឲ្យប្រទេសស៊ុយអែត ក្លាយទៅជាប្រទេសមួយដែលបានបោះបង់ចោលនូវការប្រកាន់ពូជសាសន៍ដែលរារាំងការទទួលស្គាល់ដោយស្មោះត្រង់ចំពោះអ្នកដទៃ។ ប្រទេសស៊ុយអែត នឹងឱបក្រសោបអ្នកដែលរួចផុតពីការលិចលង់នាវា ព្រមទាំងរាប់បញ្ចូលអ្នកទាំងអស់នោះទៅក្នុងសង្គមរបស់ខ្លួន។ ប្រសិនបើជនអន្តោប្រវេសន៍ និងជនជាតិស៊ុយអែតសហការគ្នាទៅវិញទៅមក យើងនឹងរីកចម្រើនទាំងអស់គ្នា។

**(តនៅលេខក្រោយ)**

# មានជីវិតរស់នៅតែម្នាក់ឯងប៉ុណ្ណោះ

**ដារ៉ាវរដ្ឋ មេត្តា**



*ម៉ៅ គឹមស្រ៊ុន អង្គុយនៅផ្ទះរបស់គាត់ នៅស្រុកកំពង់លាវ ខេត្តព្រៃវែង។ (ដារ៉ាវរដ្ឋ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនទាំងអស់ប្រាំបីនាក់។ នៅក្នុងចំណោមបងប្អូនរបស់ខ្ញុំទាំងអស់ នៅរស់ជីវិតតែខ្ញុំម្នាក់ប៉ុណ្ណោះ ចំណែកប្រាំពីរនាក់ទៀតបានស្លាប់។ បងប្អូនខ្លះស្លាប់នៅក្នុងសមរភូមិ ក្នុងរបបខ្មែរក្រហម, ខ្លះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ និងខ្លះទៀតបានស្លាប់ដោយសារជំងឺ។

ខ្ញុំឈ្មោះ ម៉ៅ គឹមស្រ៊ុន កើតនៅឃុំកោះសូទិន គឺជាទីកន្លែងដែលគ្រួសារខ្ញុំរស់នៅ និងប្រកបរបរធ្វើចម្ការ។ គ្រួសារខ្ញុំដាំពោត សណ្តែក និងថ្នាំជក់។ ឪពុករបស់ខ្ញុំបានខិតខំដាំដុះ ដើម្បីយកប្រាក់ជួយខ្ញុំ និងប្អូនខ្ញុំម្នាក់ទៀតឲ្យបានចូលរៀន ទោះបីសាលារៀននៅឆ្ងាយ និងជីវភាពគ្រួសារមិនសូវធូរធាក៏ដោយ។ ខ្ញុំបានមកស្នាក់នៅវត្តអង្គរក្នុងក្រុងកំពង់ចាមដើម្បីរៀនសូត្រ ព្រោះខ្ញុំចង់ធ្វើការងាររាជការ។ ខ្ញុំរៀនបានដល់ថ្នាក់ទី៣ នៅវិទ្យាល័យព្រះសីហនុរាជ ក្នុងក្រុងកំពង់ចាម។ រៀងរាល់ថ្ងៃឈប់សម្រាកថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ខ្ញុំបានមកលេងឪពុកម្តាយនៅស្រុកកោះសូទិន និងបានឆ្លៀតពេលជួយបេះស្លឹកថ្នាំជក់ ហាន់ថ្នាំជក់ ហាលថ្នាំជក់ និងតម្រៀបថ្នាំជក់ទុក។ មានឈ្មួញមកទិញថ្នាំជក់ដល់ផ្ទះរបស់ខ្ញុំ ប៉ុន្តែមុខរបរដាំថ្នាំជក់មិនសូវចំណេញប្រាក់ប៉ុន្មានទេ។

ខ្ញុំមិនដែលបោះបង់ការសិក្សាម្តងណាឡើយ រហូតដល់ខ្ញុំបានប្រឡងជាប់ឌីប្លូមនៅក្នុងឆ្នាំ១៩៦០។ នៅពេលនោះខ្ញុំមានអាយុប្រហែល២៣ឆ្នាំ។ ខ្ញុំបានប្រឡងជាប់ និងចូលរៀនបន្តនៅសាលាគរុកោសល្យ នៅចន្លោះពីឆ្នាំ១៩៦០ ដល់ ឆ្នាំ១៩៦១។

នៅក្នុងឆ្នាំ១៩៦២ ខ្ញុំបានចេញបង្រៀនសិស្ស។ សាលាបឋមសិក្សាត្បែងខ្ពស់គឺជាសាលាដែលខ្ញុំបានបង្រៀនដំបូង។ សាលានេះស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។ ខ្ញុំបានបង្រៀននៅសាលាត្បែងខ្ពស់បាន៣ឆ្នាំ ក៏សុំផ្លាស់ទៅបង្រៀននៅសាលាបន្ទាយលង្វែក។ ពីរឆ្នាំក្រោយមក ខ្ញុំបានដូរមកបង្រៀននៅស្រុកកំណើតក្នុងខេត្តកំពង់ចាមវិញ។ គ្រូបង្រៀនសម័យនោះត្រូវតែមានវិន័យ ទើបសិស្សគោរពនិងខ្លាច។ សិស្សត្រូវស្លៀកពាក់ស្អាតបាត និងត្រូវចូលអង្គុយនៅក្នុងថ្នាក់មុនគ្រូ។

ធ្វើការងារជាគ្រូបង្រៀនសម័យនេះ អាចឲ្យខ្ញុំសន្សំលុយបានខ្លះ និងអាចទិញម៉ូតូម៉ូបីឡែតបានមួយគ្រឿង ដើម្បីជិះទៅបង្រៀន។ កាលនោះម៉ូតូម៉ូបីឡែតមួយគ្រឿង មានតម្លៃប្រហែលជាមួយម៉ឺនប្រាំពាន់រៀល។ ម៉ូតូនេះ ផលិតនៅប្រទេសបារាំង។ ខ្ញុំស្រឡាញ់ម៉ូតូដែលខ្ញុំទើបតែទិញនេះខ្លាំងណាស់។ នៅក្នុងឆ្នាំ១៩៧០ មានព្រឹត្តិការណ៍មួយកើតឡើង គឺខ្មែរក្រហមចាប់គ្រូៗនៅក្នុងឃុំកំពង់រាប ស្រុកកោះសូទិន។ ដូច្នេះ ខ្ញុំមិនអាចចេញក្រៅស្រុកបានទេ។ មានគ្រូបង្រៀនខ្លះបានចេញពីភូមិ ប៉ុន្តែត្រូវបានខ្មែរក្រហមស្ទាក់ចាប់បាន។ អំឡុងពេលនោះ ខ្ញុំក៏បានឃើញកងទ័ពធៀវគី (វៀតណាមខាងត្បូង)ចូលមកដល់ភូមិរបស់ខ្ញុំដែរ។ ខ្ញុំបានរៀបចំគម្រោងនាំប្រពន្ធកូនរបស់ខ្ញុំទៅរស់នៅផ្ទះម្ដាយខ្ញុំបណ្ដោះអាសន្ន ព្រោះខ្មែរក្រហមមិនទាន់ចូលទៅដល់ផ្ទះម្ដាយរបស់ខ្ញុំទេ។ នៅម៉ោង១០យប់ យើងបានលួចចេញពីភូមិ។ មានអ្នកភូមិម្នាក់បានជួយជូនខ្ញុំ និងប្រពន្ធកូនចេញពីភូមិ។ ខ្ញុំបានឌុបប្រពន្ធខ្ញុំ ចំណែកអ្នកភូមិម្នាក់នោះបានឌុបកូនរបស់ខ្ញុំ។ បន្ទាប់យើងបានចុះបណ្ដើរម៉ូតូក្នុងចម្ងាយផ្លូវប្រមាណជា ៧គីឡូម៉ែត្រទើបបានដល់ផ្ទះម្ដាយរបស់ខ្ញុំ។

នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានវាយចូលដល់ក្រុងកំពង់ចាម និងជម្លៀសប្រជាជនចេញពីផ្ទះ។ ចំណែកក្រុមគ្រួសាររបស់ខ្ញុំក៏ត្រូវបានជម្លៀសនៅពេលនោះដែរ។ ពីរខែក្រោយមក ខ្មែរក្រហមបានចាប់ខ្ញុំយកទៅដាក់គុកកោះញ៉ែក ដោយចោទថា ខ្ញុំគឺជាក្រុមសក្តិភូមិ ប៉ុន្តែមិនបានសម្លាប់ខ្ញុំទេ។ មានបុរសចំណាស់ម្នាក់នៅទីនោះបានដឹងថាខ្ញុំធ្វើជាគ្រូបង្រៀន។ នៅក្នុងគុកនោះមិនប្រវាក់ដាក់អ្នកទោសទេ គឺឆ្មាំគុកកំណត់ទីតាំង និងចម្ងាយឲ្យអ្នកទោសដើរ។ រយៈពេលពីរទៅបីថ្ងៃ ឆ្មាំគុកមកសួរចម្លើយខ្ញុំម្ដង។ សំណួរដែលឆ្មាំគុកសួរគឺ តើឯងធ្វើអីខ្លះពីដើម? ឯងនៅឯណា? តើឯងបានធ្វើអ្វីទៀត? បន្ទាប់មកឆ្មាំគុកនិយាយលួងលោមឲ្យខ្ញុំឈប់នឹកនាការងារដែលធ្លាប់ធ្វើពីមុនមក។ ខ្ញុំមិនហ៊ានប្រកែកទេ។ នៅទីនោះ ឆ្មាំគុកចាត់តាំងឲ្យខ្ញុំរែកទឹកមួយថ្ងៃ១០០អំរែក គឺព្រឹក ៥០អំរែក និងល្ងាច៥០អំរែក។

ពេលខ្មែរក្រហមទទួលជ័យជម្នះឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅរស់នៅកោះរកា ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាមវិញ។ ខ្ញុំត្រូវបានចាត់តាំងឲ្យឃ្វាលក្របី ៣០ក្បាល ជាមួយនឹងសមាជិកក្រុមពីរនាក់ទៀត។ យើងបែងចែកគ្នាឃាមតាមជ្រុងស្រែដែលមានស្រូវ ដើម្បីកុំឲ្យក្របីស៊ី។ នៅវេលាម៉ោង៦ព្រឹក ខ្ញុំនិងសមាជិកក្នុងក្រុមត្រូវដេញក្របីចេញពីក្រោល។ ពេលថ្ងៃត្រង់ យើងត្រឡប់មកហូបបាយនៅសហករណ៍ ហើយពេលល្ងាចយើងត្រូវដុះលាងសម្អាតក្របីឲ្យឡើងពណ៌ខ្មៅរលោង រួចដុតភ្លើងកុំឲ្យមូសខាំក្របី។ ខ្ញុំរស់នៅជាមួយភាពភ័យខ្លាចរាល់ថ្ងៃ។ ថ្ងៃមួយខ្ញុំអស់កម្លាំងយ៉ាងខ្លាំង ហើយដៃរបស់ខ្ញុំចាប់ផ្ដើមញ័រ។ ខ្ញុំបានធ្វើឲ្យធ្លាក់ចានបបរពីដៃពេលទៅទទួលរបបអាហារប្រចាំថ្ងៃ បណ្ដាលឲ្យខ្ចាយបបរអស់ ប៉ុន្តែសំណាងល្អមិនបែកចាន។ ខ្មែរក្រហមបានចោទខ្ញុំថា មានបំណងចង់ចាក់បបរចោល ដូច្នេះខ្ញុំគ្មានអាហារហូបទេក្នុងថ្ងៃនោះ។ នៅឆ្នាំ១៩៧៧ អ្នកភូមិម្នាក់ដែលរស់នៅជិតផ្ទះរបស់ខ្ញុំ ដែលមានប្ដីជាជនជាតិវៀតណាម ត្រូវបានកងឈ្លបខ្មែរក្រហមមកយកប្ដីរបស់គាត់ទៅបាត់ ចំណែកគាត់កងឈ្លបមិនមកទៅជាមួយទេ។

ខ្ញុំបានចូលធ្វើជាគ្រូបង្រៀនវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ក្រោយមកខ្ញុំផ្លាស់ធ្វើជាទាហាន។ នៅឆ្នាំ១៩៨៤ ខ្ញុំបានមករស់នៅស្រុកកំពង់លាវ ខេត្តព្រៃវែង ដែលជាស្រុកកំណើតប្រពន្ធរបស់ខ្ញុំ។ ខ្ញុំមានកូន៧នាក់ ក្នុងនោះស្រី៤នាក់។ សព្វថ្ងៃខ្ញុំមានអាយុ៨៣ឆ្នាំហើយ។ កូនរបស់ខ្ញុំបានផ្ដល់ប្រាក់ឲ្យខ្ញុំខ្លះដើម្បីដោះស្រាយជីវភាព ព្រោះខ្ញុំនិងប្រពន្ធអាចរកប្រាក់បានតិចតួចប៉ុណ្ណោះពីរបរធ្វើស្រែ។

# សម្រេចបួសជាសង្ឃព្រោះគេចពីកំណែនកងទ័ព

**ហូ ថុនា**



តាអ៊ូច កំពុងពរចៅ។ សព្វថ្ងៃ តាអ៊ូច រស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

តាអ៊ូច អាយុ៧៣ឆ្នាំ រស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា «បន្ទាប់ពីរបប លន់ នល់ ឡើងគ្រប់គ្រងប្រទេសនៅឆ្នាំ១៩៧០ ប្រជាជនក្នុងស្រុកភូមិរបស់ខ្ញុំចាប់ផ្តើមមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបង្ខិតបង្ខំឲ្យយុវជនដែលមានកម្លាំងមាំមួនឲ្យចូលធ្វើជាទាហាន។ ពាក្យចរចាមអារាមបានឮសុះសាយនៅទូទាំងភូមិថាមានឡានទាហានរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ បានបើកមកដឹកយុវជននៅតាមភូមិឲ្យចូលធ្វើជាទាហាន។ បន្ទាប់ពីប្រមែប្រមូលបានច្រើន យុវជនទាំងនោះនឹងត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅខេត្តកំពង់ធំ ដើម្បីប្រយុទ្ធតទល់នឹងទាហានយៀកកុង ឬ វៀតណាមខាងជើង។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង និងបានសម្រេចចិត្តបួសធ្វើជាព្រះសង្ឃនៅវត្តពោធិ៍កែវព្រះនេត្រព្រះក្នុងឃុំព្រះនេត្រព្រះ នៅឆ្នាំ១៩៧២។ ប៉ុន្តែខ្ញុំបួសបានរយៈពេល១ឆ្នាំតែប៉ុណ្ណោះ ក៏សឹកមកជួយមើលថែឪពុកម្តាយរបស់ខ្ញុំដែលចាស់ជរា និងធ្វើការងាររកប្រាក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដែលខ្វះខាត ព្រោះ ខ្ញុំជាកូនប្រុសច្បងក្នុងគ្រួសារ។ ថ្ងៃមួយខ្ញុំបានទទួលដំណឹងថា មានឡានទាហានរបស់របបសាធារណរដ្ឋខ្មែរបានបើកចូលមកក្នុងភូមិរបស់ខ្ញុំ ដូច្នេះខ្ញុំនិងយុវជនជាច្រើននាក់ទៀតបានរត់គេចចេញពីភូមិ ទៅរស់នៅវាលគុម្ពដែលមានចម្ងាយឆ្ងាយពីភូមិ។ នាពេលនោះគឺស្ថិតនៅក្នុងរដូវប្រាំង ដូច្នេះខ្ញុំជួបការលំបាកយ៉ាងខ្លាំងក្នុងការរកទឹកមកប្រើប្រាស់ និងដាំស្លប្រចាំថ្ងៃ។ ខ្ញុំ និងយុវជនទាំងនោះ បានស្នាក់នៅក្រោមរទេះគោចំនួនប្រមាណ៣០ ទៅ៤០រទេះ ដែលក្នុងមួយរទេះមានយុវជនប្រហែល ៣ ទៅ ៤ នាក់។ ខ្ញុំ និងយុវជនទាំងនោះតែងតែទៅនេសាទត្រីពីទន្លេយកមកធ្វើម្ហូបប្រចាំថ្ងៃ។ រយៈពេល២ខែក្រោយមក អ្នកភូមិរបស់ខ្ញុំបាន

ផ្តល់ដំណឹងថា ការប្រមែប្រមូលយុវជនឲ្យចូលធ្វើទាហានបានស្ងត់ស្ងាត់ហើយ។ វាគឺជាដំណឹងល្អសម្រាប់ខ្ញុំ។ ខ្ញុំនិងយុវជនផ្សេងទៀតបានប្រមែប្រមូលរបស់របរទុកដាក់ និងបាននាំគ្នាវិលត្រឡប់ចូលទៅរស់នៅក្នុងភូមិវិញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេសជំនួសរបបសាធារណរដ្ឋខ្មែរ។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំសប្បាយត្រេកអរយ៉ាងខ្លាំង ព្រោះគិតថារបបថ្មីនេះនឹងជួយឲ្យប្រជាជនរស់នៅបានសុខសាន្ត។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំខ្លះបានច្រៀង និងចាក់ភ្លេងរាំរែកយ៉ាងសប្បាយរីករាយ ព្រោះត្រូវចំថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ ពេលនោះក៏មានយោធាខ្មែរក្រហមបានដើរចូលក្នុងភូមិរបស់ខ្ញុំ ដើម្បីត្រួតពិនិត្យសភាពការណ៍។ ទោះបីយ៉ាងណាប្រជាជននៅភូមិរបស់ខ្ញុំនៅតែជឿជាក់ថា យោធាខ្មែរក្រហមទាំងនោះជាមនុស្សស្លូតត្រង់។ មួយរយៈក្រោយមក យោធាខ្មែរក្រហមចាប់ផ្តើមអនុវត្តគោលនយោបាយរបស់ខ្លួន ដោយបានបង្ខិតបង្ខំឲ្យប្រជាជននៅក្នុងភូមិរបស់ខ្ញុំទៅរស់នៅភ្នំកូនដំរីដែលជាភ្នំមួយស្ថិតនៅចំកណ្តាលវាលស្រែល្វឹងល្វើយ។

ព្រះវិហារវត្តព្រះនេត្រព្រះ ស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (អ៊ូច មករា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)





ទិដ្ឋភាពវត្តព្រះនេត្រព្រះ ថតពីលើអាកាស។ (អ៊ូច មករា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

*ចំណែកឯផ្ទះសម្បែងរបស់ប្រជាជនត្រូវបានខ្មែរក្រហមដុតបំផ្លាញស្ទើរតែទាំងស្រុងៗ ខ្ញុំនិងអ្នកភូមិរបស់ខ្ញុំបានសាងសង់ខ្ទមស្បូវតូចៗ ដើម្បីស្នាក់នៅបណ្តោះអាសន្នៗ*

*រយៈពេលកន្លះខែក្រោយមក កម្មាភិបាលខ្មែរក្រហមបានជម្លៀសអ្នកភូមិរបស់ខ្ញុំពីភ្នំកូនដំរីឲ្យទៅរស់នៅភូមិស្រះខាងកើតវិញៗ ប្រធានភូមិបានបែងចែកការងារឲ្យប្រជាជនគ្រប់ៗគ្នាៗ ប្រជាជនខ្លះដាំដំឡូង ដកស្ទូង និងស្ទូងស្រូវ ចំណែកខ្ញុំភ្ជួរស្រែៗ ខ្ញុំ និងប្រុសៗជាច្រើននាក់ត្រូវបានខ្មែរក្រហមបានចាត់តាំងឲ្យទៅភ្ជួរស្រែនៅវាលស្រែនាមរយៈពេលមួយខែៗ ក្រោយមកប្រជាជនក្នុងភូមិរបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិត្រពាំងវែងវិញៗ តាំងពីយូរយារណាស់មកហើយ ភូមិត្រពាំងវែង គឺជាតំបន់ដែលមានព្រៃដុះព័ទ្ធជុំជិត និងគ្មានប្រជាជនរស់នៅទេៗ ភូមិនេះមានទីតាំងស្ថិតនៅជាប់នឹងជើងភ្នំអរិយកន្ត្តបុ្ភភ្នំព្រះនេត្រព្រះៗ នៅពេលខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានសាងសង់ខ្ទមស្បូវចំនួន១៥នៅភូមិត្រពាំងវែង និងឲ្យប្រជាជននៅក្នុងភូមិកណ្តាលចំនួន៣០គ្រួសារទៅស្នាក់នៅក្នុងភូមិដែលទើបតែបង្កើតថ្មីនោះៗ ខ្ទមនីមួយៗមានទទឹងទំហំ៦ម៉ែត្រ ប្រក់ស្បូវ និងសាងសង់ក្នុងចម្ងាយប្រហែល១៥ម៉ែត្រឃ្លាតពីគ្នាៗ ខ្ទមនេះ សង់ជាពីរជួរទល់មុខគ្នាៗ*

*រហូតដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនប្រជាជនថ្មីដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងពីខេត្តនានាកាន់តែច្រើនឲ្យមករស់នៅក្នុងភូមិត្រពាំងវែងៗ ខ្មែរក្រហមបានចាប់ផ្តើមសាងសង់ខ្ទមស្បូវបន្ថែមទៀតសម្រាប់ប្រជាជនថ្មីទាំងនោះរស់នៅៗ ខ្ទមស្បូវទាំងនោះត្រូវបានខ្មែរក្រហមសាងសង់នៅចំកណ្តាលបរិវេណគម្លាតនៃខ្ទមស្បូវរបស់ប្រជាជនមូលដ្ឋានៗ ប្រជាជនថ្មីដែលជម្លៀសមកទាំងនោះមានចំនួនច្រើនជាងប្រជាជនមូលដ្ឋានៗ ប្រជាជនថ្មី និងប្រជាជនមូលដ្ឋានបានរស់នៅ និងធ្វើការលាយឡំគ្នាៗ ខ្ញុំបានរស់នៅ និងធ្វើការងារស្រែចម្ការជាមួយប្រជាជននៅក្នុងភូមិត្រពាំងវែង រហូតដល់ឆ្នាំ១៩៧៩ ទើបខ្ញុំមករស់ភូមិកណ្តាលវិញរហូតមកដល់សព្វថ្ងៃ ៗ*




*ស្លាកសញ្ញាសម្គាល់ផ្លូវទៅភូមិត្រពាំងវែង ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យៗ (សោម ប៊ុនថន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*វាលស្រែនៅជើងភ្នំអរិយកន្ត្តបុ្ភ ភ្នំព្រះនេត្រព្រះ ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យៗ (អន វណ្ណារ៉ា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សំឡេងដែលខ្ញុំនៅតែចងចាំ គឺម្តាយរបស់ខ្ញុំសុំជួបកូនៗ

*សោម ប៊ុនថន*



មាស សាបឿន កំពុងពរចៅ។ សព្វថ្ងៃ មាស សាបឿន រស់នៅភូមិញរ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ (អ៊ុន សុដាវី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សំឡេងដែលខ្ញុំនៅតែចងចាំ គឺសំឡេងម្តាយរបស់ខ្ញុំស្រែកអង្វរសុំជួបកូនៗ មុននឹងឈ្លបសម្លាប់គាត់។ ចំណែកខ្ញុំបានរត់គេចខ្លួនចេញពីកន្លែងឃុំឃាំង បន្ទាប់ពីខ្ញុំដឹងថាខ្មែរក្រហមនឹងមកយកខ្ញុំទៅសម្លាប់បន្តទៀត។ ការសម្រេចចិត្តរត់គេចខ្លួនរបស់ខ្ញុំបានធ្វើឲ្យខ្ញុំនៅរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។ ប៉ុន្តែឪពុកម្តាយ រួមទាំងប្អូនស្រីរបស់ខ្ញុំពីរនាក់ មិនមានសំណាងដូចខ្ញុំឡើយ។ ឪពុកម្តាយ និងប្អូនស្រីរបស់ខ្ញុំទាំងពីរ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ទាំងអស់។

ខ្ញុំឈ្មោះ មាស សាបឿន។ នៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសពីឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ទៅខេត្តពោធិ៍សាត់ ក្នុងភូមិភាគពាយ័ព្យ។ ខ្ញុំមានអាយុ១២ឆ្នាំតែប៉ុណ្ណោះនៅពេលនោះ។ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមបែងចែក

ឲ្យទៅរស់នៅសហករណ៍មួយក្នុងឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវ៉ាញ។ ឪពុករបស់ខ្ញុំបានរស់នៅបែកពីម្តាយរបស់ខ្ញុំ។ យើងបានខិតខំធ្វើការងារផ្សេងៗតាមការចាត់តាំងរបស់ខ្មែរក្រហម។

នៅចុងឆ្នាំ១៩៧៨ គឺមុនពេលកងទ័ពវៀតណាមចូលមកដល់ខេត្តពោធិ៍សាត់ ប្រធានសហករណ៍បានមកហៅឪពុករបស់ខ្ញុំឈ្មោះ មាស សឿនឲ្យចុះពីលើផ្ទះ នៅពេលដែលគាត់កំពុងសាងសង់ផ្ទះសម្រាប់ប្រជាជននៅក្នុងកងចល័តស្នាក់នៅ។ ពេលឪពុករបស់ខ្ញុំចុះមកដល់ដី ប្រធានសហករណ៍បានចាប់ចងគាត់។ ឪពុក របស់ខ្ញុំបានសួរទៅប្រធានសហករណ៍ថា «ខ្ញុំបានធ្វើអ្វីខុសបានជាចាប់ខ្ញុំចង?» នៅពេលដែលប្រធានសហករណ៍នោះបណ្តើរគាត់ចេញទៅ ប៉ុន្តែប្រធានសហករណ៍នោះមិនបានឆ្លើយតបទៅឪពុករបស់ខ្ញុំឡើយ។ រយៈពេល៣ថ្ងៃក្រោយមក ប្រធានកងនារីបានមកហៅម្តាយរបស់ខ្ញុំឈ្មោះ ប៉ែន យឺ និងប្អូនស្រីរបស់ខ្ញុំពីរនាក់ឈ្មោះ មាស សារឿន និង មាស សាវឿន ទៅទៀត។ ពេលនោះម្តាយរបស់ខ្ញុំកំពុងមានជំងឺប្រចាំកាយ។ កងឈ្លបប្រុសៗបានបណ្តើរម្តាយ និងប្អូនៗរបស់ខ្ញុំចេញទៅព្រៃខាងក្រោយផ្ទះ។ មួយសន្ទុះក្រោយមក ខ្ញុំបានឮសំឡេងម្តាយរបស់ខ្ញុំស្រែកអង្វរថា «ហេតុអ្វីបានជាសម្លាប់ខ្ញុំ?» និង «មុនសម្លាប់ខ្ញុំ ខ្ញុំសុំជួបកូនៗសិន!» ហើយបាត់ឈឹងលែងឮសំឡេងរបស់គាត់ទៀត។ នៅពេលកងឈ្លបមកយកម្តាយរបស់ខ្ញុំ ខ្ញុំនៅកងកុមារស្ថិតនៅក្បែរនោះ ប៉ុន្តែម្តាយរបស់ខ្ញុំបានលាក់មិនឲ្យឈ្លបទាំងនោះដឹង។ ខ្ញុំមិនដឹងថា ឈ្លបទាំងនោះបានប្រព្រឹត្តអ្វីខ្លះមកលើម្តាយរបស់ខ្ញុំ និងប្អូនស្រីរបស់ខ្ញុំទាំងពីរនាក់ទេ។ បន្ទាប់មកខ្មែរក្រហមបានមកយកខ្ញុំរួមជាមួយកុមារប្រមាណជាង១០០នាក់ផ្សេងទៀតទៅឃុំទុកនៅទីកន្លែងមួយ ក្នុងស្រុកភ្នំក្រវ៉ាញ។ នៅវេលាម៉ោង៧រសៀលថ្ងៃមួយ ខ្មែរក្រហមបានធ្វើនំបញ្ចុកឲ្យខ្ញុំ និងកុមារនោះហូប។ ខណៈនោះប្រធានកងរបស់ខ្ញុំឈ្មោះ សាវិន មានស្រុកកំណើតនៅខេត្តកំពង់ចាមដែលមានសណ្តានចិត្តល្អ បានមកលួចខ្សឹបប្រាប់ខ្ញុំឲ្យលួចរត់ចេញពីទីកន្លែងនោះ បើមិនដូច្នេះទេខ្ញុំនឹងត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់បន្តទៀត។ ខ្ញុំបានសម្រេចចិត្តលួចរត់គេចខ្លួន និងបានទៅរស់នៅក្នុងព្រៃអស់រយៈពេលជាច្រើនថ្ងៃ។ ក្រោយមក ខ្ញុំបានជួបកងទ័ពស្ម័គ្រចិត្តវៀតណាម និងបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ។ ខ្ញុំបានក្លាយទៅជាក្មេងកំព្រា ក្រោយពេលរបបខ្មែរក្រហមដួលរលំ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ សាម៉ុន និងបានមករស់នៅឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មកដល់សព្វថ្ងៃ។

ខ្ញុំធ្លាប់បានចូលរួមផ្តិតមេដៃដាក់ពាក្យប្តឹងក្រុមខ្មែរក្រហមទៅអង្គការសហប្រជាជាតិ តាមរយៈរដ្ឋាភិបាលនៃរបបសាធារណប្រជាមានិតកម្ពុជា នៅក្នុងឱកាសរំឭកឡើងវិញនូវរាល់ឧក្រិដ្ឋកម្មរបស់ក្រុមខ្មែរក្រហមប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៦ នៅក្នុងភូមិញរ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ប៉ុន្តែពាក្យរបស់ខ្ញុំ និងប្រជាជនចំនួន៣៥៩៦នាក់ទៀតនៅក្នុងភូមិមិនត្រូវបានយកចិត្តទុកដាក់ឡើយនៅពេលនោះ។

នៅពេលសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមបង្កើតឡើង ខ្ញុំបានដាក់ពាក្យបណ្តឹងទៅសាលាក្តីនេះម្តងទៀតនៅក្នុងឆ្នាំ២០០៩ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបានស្ងប់ចិត្តនៅពេលសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ទទួលស្គាល់ពីការបាត់បង់ និងការឈឺចាប់របស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមិនអាចបំភ្លេចអំពីរឿងរ៉ាវដែលបានកើតឡើងចំពោះក្រុមគ្រួសាររបស់ខ្ញុំ។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នូកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

*ហួ ថុនា និង ដារ៉ារដ្ឋ មេគ្គា*

(តពីលេខមុន)



*ទស្សនកិច្ចរបស់គណៈប្រតិភូ ឡាវ នៅកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៨-២០ ខែធ្នូ ឆ្នាំ១៩៧៧។*
*- រូបស្រ្តីខាងឆ្វេងទី១៖ យុន យ៉ាត រដ្ឋមន្រ្តីក្រសួងវប្បធម៌អប់រំ និងសិក្សាធិការ*
*- រូបស្រ្តីខាងឆ្វេងទី២៖ អៀង ធីរិទ្ធ រដ្ឋមន្រ្តីក្រសួងសង្គមកិច្ច*
*- រូបខាងស្តាំទី១៖ សុផានូវង្ស ប្រធានាធិបតីសាធារណរដ្ឋប្រជាមានិត ឡាវ*
*- រូបខាងស្តាំទី២៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ*

**១៣១.** *ចំពោះ «ភ័ស្តុតាងមួយចំនួន» ដែលនៅសេសសល់ដែលមេធាវីការពារក្តី នួន ជា បានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ១ នោះ មេធាវីការពារក្តីមិនបានបង្ហាញទឡ្ហីករណ៍ណាមួយឬបានកំណត់អត្តសញ្ញាណកាលៈទេសៈឬអង្គហេតុថ្មីណាមួយ ដែលតម្រូវឲ្យអង្គជំនុំជម្រះធ្វើការពិចារណាទៅលើសំណើនេះសាជាថ្មីឡើយ។ ហេតុដូច្នេះ សំណើរបស់មេធាវីការពារក្តីត្រូវបដិសេធចោល។*

**១៣២.** ទាក់ទិនសំណើជាជម្រើសមួយផ្សេងទៀតសុំឲ្យបើកកិច្ចដំណើរការនីតិវិធីម្តងទៀត និងសុំឲ្យធ្វើការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចទាំងអស់របស់អង្គជំនុំជម្រះដែលបានបដិសេធសំណើរបស់មេធាវីការពារក្តី នួន ជា សុំបំពេញកិច្ចស៊ើបសួរនៅក្នុងឧបសម្ព័ន្ធ ៣ ព្រមទាំងស្តាប់សាក្សីបន្ថែមដែលពួកគេបានស្នើឡើង ដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ២ នោះអង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំដំណោះស្រាយនេះបានធ្វើឡើងបួនខែក្រោយពីកាលបរិច្ឆេទបិទពិភាក្សាការពារដេញដោលលើភ័ស្តុតាង និងក្នុងករណីខ្លះទៀតធ្វើឡើងរាប់ឆ្នាំ ក្រោយពេលចេញសេចក្តីសម្រេចដែលពាក់ព័ន្ធនោះ។ មេធាវីការពារក្តីមិនបានបង្ហាញកាលៈទេសៈឬអង្គហេតុថ្មីណាមួយដែលតម្រូវឲ្យអង្គជំនុំជម្រះធ្វើការពិចារណាលើសំណើនេះសាជាថ្មីឡើងវិញឡើយ ដូច្នេះសំណើសុំនេះត្រូវបដិសេធចោល។

**២.៥.៤.៣.** ការចោទប្រកាន់ផ្អែកលើការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង និងសំណើសុំធ្វើការពិចារណាឡើងវិញ

**១៣៣.** មេធាវីការពារក្តី នួន ជា បានលើកឡើងថាវាជាការអយុត្តិធម៌ដែលសហចៅក្រមស៊ើបអង្កេតបានហាមឃាត់មិនឲ្យខ្លួនបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង ការអនុវត្តបែបនេះធ្វើឲ្យមេធាវីការពារក្តីចាញ់ប្រៀបក្នុងការអនុវត្តការងាររបស់ខ្លួន ព្រមទាំងបណ្តាលឲ្យមានវិសមភាពនៃគូភាគី។ ផ្អែកលើសាលដីកាសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះតុលាការកំពូល មេធាវីការពារក្តីបានអះអាងថា ខ្លួនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចស៊ើបសួរក្នុងពេលស៊ើបសួរសំណុំរឿង ០០២។ មេធាវីការពារក្តី នួន ជា បានលើកឡើងបន្ថែមទៀតថាវិសមភាពនៃគូភាគីដែលបានកើតឡើងនេះ អាចធ្វើការជួសជុលបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតាមរយៈការអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តីសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណសម្ភារដោះបន្ទុក។ ហេតុដូច្នេះ មេធាវីការពារក្តី នួន ជា ស្នើសុំឲ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី នួន ជា។

**១៣៤.** អង្គជំនុំជម្រះរំឭកថា អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយចំពោះទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នានេះរបស់មេធាវីការពារក្តី នួន ជា នៅក្នុងបរិបទនៃបណ្តឹងសារទុក្ខក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចស្របគ្នាជាមួយនឹងយុត្តិ-សាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងថា «ក្របខណ្ឌនីតិវិធីរបស់ អ.វ.ត.ក. មិនបានប្រមើលឃើញអំពីការស៊ើបអង្កេតពេញលេញដែលដំណើរការដោយភាគី ដូចជាដំណើរការដែលជាលក្ខណៈទូទៅនៃប្រព័ន្ធប្រតិបក្ខនោះឡើយ។ ប៉ុន្តែដោយគោរពតាមទំនៀមទម្លាប់នីតិវិធីដែលអនុវត្តជាទូទៅនៅកម្ពុជា កិច្ចស៊ើបសួរនៅ អ.វ.ត.ក. ត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត»។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា «វិធានជាធរមាននៅ អ.វ.ត.ក. មិនបានប្រគល់សិទ្ធិ [ស៊ើបសួរ] ទាំងអស់នេះទៅឲ្យភាគីណាមួយឡើយ» ហេតុដូច្នេះ «ក្នុងករណីដែល នួន ជា ស្នើសុំអនុវត្តអំណាចស៊ើបសួរដែលបានផ្តល់ជូនទៅអង្គជំនុំជម្រះសាលាដំបូងតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនោះឡើយក្នុងការច្រានចោលសំណើរបស់គាត់។

**១៣៥.** អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យមេធាវីការពារក្តីអាចបំពេញកិច្ច «ដែលមានគោលដៅស្វែងរកភ័ស្តុតាងពាក់ព័ន្ធ បើសិនកិច្ចបែបនេះមិននាំទៅដល់ការរំខានដល់សាក្សីឬការធ្វើឲ្យខូចដល់ភ័ស្តុតាង» ហើយថាមេធាវីការពារក្តីគួរទទួលបានការអនុញ្ញាតឲ្យអនុវត្តសកម្មភាពដោយមានកម្រិត ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលអាចជាសាក្សីឲ្យបានច្បាស់លាស់គ្រប់គ្រាន់។

**១៣៦.** អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនបានពិចារណាទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរនីមួយៗដែលមេធាវីការពារក្តី នួន ជា បានដាក់ ហើយក្នុងករណីសមស្របបានបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ។ អង្គជំនុំជម្រះបានទាក់ទងនឹងលោកសាស្ត្រាចារ្យ Walter HEYNOWSKI និងបានទទួលពីគាត់នូវរូបថតពីមន្ទីរសន្តិសុខ ស-២១ និង

សៀវភៅកំណត់ត្រាពណ៌ទឹកក្រូចដែលមេធាវីការពារក្តី នួន ជា បានស្នើសុំ។ អង្គជំនុំជម្រះក៏បានស្នើសុំព័ត៌មានពីប្រទេសនានា ដូចជា ប្រទេសវៀតណាម និងទទួលបានឯកសារបកប្រែនៃកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍បក្សតាមរយៈការស្នើសុំទៅលោកសាស្ត្រាចារ្យ CHRISTOPHER GOSCHA ដែលមេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យទទួលយកសម្រង់នៃឯកសារនេះធ្វើជាភស្តុតាង។

**១៣៧.** ជាចុងក្រោយ យោងតាមសារណារបស់ពួកគេផ្ទាល់ភស្តុតាងដែលដកស្រង់ដោយមេធាវីការពារក្តី នួន ជា អនុញ្ញាតឲ្យពួកគេ «គាំទ្រដល់សំណុំរឿងស្នូលរបស់ នួន ជា ដោយលម្អិតជាងមុន» ហើយ «ពិតជាបានបង្ហាញភស្តុតាងនៃសំណុំរឿងរបស់ នួន ជា និងព័ត៌មានរបស់គាត់អំពីអ្វីដែលបានកើតឡើងពេលមុននៅក្នុងអំឡុងរបប និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

**១៣៨.** ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាថា មេធាវីការពារក្តី នួន ជា បានទទួលនូវមធ្យោបាយគ្រប់គ្រាន់សម្រាប់បង្កើត និងបង្ហាញសំណុំរឿងរបស់ខ្លួនតាមរយៈការចូលរួមនៅក្នុងដំណាក់កាលមុនអង្គសេចក្តីការអនុញ្ញាតតាមសំណើសុំសាក្សីបន្ថែម និងកិច្ចនានាដែលអង្គជំនុំជម្រះបានអនុវត្តដើម្បីគាំទ្រសំណើរបស់មេធាវីការពារក្តី នួន ជា។ មេធាវីការពារក្តីមិនបានកំណត់អត្តសញ្ញាណនៃកាលៈទេសៈ ឬអង្គហេតុថ្មីណាមួយដែលអាចផ្តល់យុត្តិកម្មសម្រាប់ការពិចារណាជាថ្មីទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ អំពីសំណើសុំរបស់មេធាវីការពារក្តី នួន ជា តាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងឡើយ។ អាស្រ័យហេតុនេះសំណើសុំរបស់មេធាវីការពារក្តី នួន ជា ត្រូវបដិសេធចោល។

**២.៥.៥.** មធ្យោបាយ និងពេលវេលាសម្រាប់ការរៀបចំការពារក្តី

**១៣៩.** មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ មកក្នុងសំណុំរឿង ០០២/០២ ដែលបានចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១៤ បានរំលោភបំពានទៅលើសិទ្ធិរបស់មេធាវីការពារក្តី។ ជាពិសេស ខៀវ សំផនបានជំទាស់ថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងសិទ្ធិទទួលបាននូវសមភាពរវាងភាគីត្រូវបានរំលោភបំពាន ដោយសារតែការដាក់បង្ហាញឯកសារទាំងនេះ ហើយការដាក់បង្ហាញឯកសារទាំងនេះផ្តល់ប្រយោជន៍ដល់សហព្រះរាជអាជ្ញា ហើយវាប៉ះពាល់ដល់ប្រយោជន៍របស់ជនជាប់ចោទ។

**១៤០.** អង្គជំនុំជម្រះរំឭកថា កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ បានធ្វើឡើងស្របគ្នាទៅនឹងកិច្ចស៊ើបសួរដែលកំពុងដំណើរការក្នុងសំណុំរឿង ០០៣ និង ០០៤។ មានអង្គហេតុជាន់គ្នាច្រើនរវាងសំណុំរឿងដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរនឹងសំណុំរឿង ០០២ ដោយសារតែសំណុំរឿងទាំងនេះ មានទីតាំងឧក្រិដ្ឋកម្ម ទីតាំងភូមិសាស្ត្រ និងអំឡុងពេលវេលាដូចគ្នា។

**១៤១.** សហព្រះអាជ្ញា គឺជាភាគីនៃសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងសំណុំរឿង ០០២ ដែលខុសពីក្រុមមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២ សហព្រះអាជ្ញាមានសិទ្ធិចូលពិនិត្យមើលសំណុំរឿងដែលចេញពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤។ ជាលទ្ធផល សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់បង្ហាញឯកសារពាក់ព័ន្ធ និងកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ទៅភាគីនានា និងអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ ការដាក់បង្ហាញទាំងអស់នេះ ជាសំខាន់រួមមាន កំណត់ហេតុនៃការស្តាប់ចម្លើយ និងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងក្របខណ្ឌកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤។ ដោយទទួលស្គាល់ពីតម្រូវការនៃការអនុញ្ញាតឲ្យដាក់បង្ហាញសម្ភារដែលអាចជាសម្ភារដោះបន្ទុក និងភស្តុតាងដទៃទៀតដែលអាចនាំទៅដល់ការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២/០២ ហើយក្នុងពេលជាមួយគ្នានោះព្យាយាមរក្សាភាពស្ងប់ស្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងដំណើរការក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឲ្យដាក់បង្ហាញភស្តុតាងពីសំណុំរឿង ០០៣ និង ០០៤ ដល់ភាគីនានានៃសំណុំរឿង ០០២ ដោយមានលក្ខខណ្ឌថា ភស្តុតាង និងសាក្សី ដែលផ្តល់ភស្តុតាងនោះមិនត្រូវបានបង្ហាញជាសាធារណៈឡើយ។



- រាប់ពីឆ្វេងទី១៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
- រាប់ពីឆ្វេងទី២៖ វ៉ន វេត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
- រាប់ពីឆ្វេងទី៣៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ
- រាប់ពីឆ្វេងទី៤៖ តា ម៉ុក លេខាភូមិភាគនិរតី
- រាប់ពីឆ្វេងទី៥ (អង្គុយពីក្រោយ តាម៉ុក)៖ ចេង អន ប្រធានគណៈកម្មាធិការឧស្សាហកម្ម
- រាប់ពីស្តាំទី១៖ កែ ពក លេខាភូមិភាគឧត្តរ (ភូមិភាគកណ្តាល)
- រាប់ពីស្តាំទី២៖ ជូ ជេត លេខាភូមិភាគបស្ចិម
- រាប់ពីស្តាំទី៣៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**១៤២.** អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ ហើយក្រោយមកអង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រលក្ខខណ្ឌចាំបាច់នៃកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញឯកសារ។ អង្គជំនុំជម្រះបានយល់ឃើញថា វិធាន ៥៣ (៤) នៃវិធានផ្ទៃក្នុង៖

**១៤៣.** ចាប់ពីខែតុលា ឆ្នាំ២០១៤ រហូតដល់ខែសីហា ឆ្នាំ២០១៥ មេធាវីការពារក្តី ខៀវ សំផន មិនបានឆ្លើយតបចំពោះសំណើរបស់សហព្រះរាជអាជ្ញា សុំការអនុញ្ញាតដាក់បង្ហាញឯកសារសំណុំរឿង ០០៣ និង ០០៤ ឡើយ។ ការដាក់បង្ហាញទាំងនោះត្រូវបានទទួលយក ហើយជាញឹកញាប់មានសំណើសុំពេលវេលាបន្ថែម ដើម្បីពិនិត្យមើលសម្ភារដែលបានបង្ហាញថ្មីៗទាំងនោះ។ ប៉ុន្តែនៅក្នុងខែសីហា ឆ្នាំ ២០១៥ ខៀវ សំផនបានដាក់សារណាមួយជំទាស់ទៅនឹងដំណើរការដាក់បង្ហាញឯកសារទាំងអស់ដោយអះអាងថា សហព្រះអាជ្ញាកំពុង «កប់ចោល» នូវភ័ស្តុតាងដោះបន្ទុកសមស្របដែលត្រូវដាក់បង្ហាញនូវក្រោមគំនរសម្ភារដាក់បន្ទុកដ៏ច្រើន ដែលសម្ភារទាំងនេះមិនគួរត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំ ០០២/០២ នោះឡើយ។

**១៤៤.** អង្គជំនុំជម្រះយល់ឃើញថា ការដាក់បង្ហាញសម្ភារថ្មីក្នុងបរិមាណដ៏ច្រើន ពីសំណុំរឿង ០០៣ និង ០០៤ មិនមែនជាការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទឡើយ។ កត្តាសំខាន់បំផុតក្នុងការវាយតម្លៃទៅលើផលប៉ះពាល់ដែលអាចមានទៅលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ គឺការកំណត់ថាតើជនជាប់ចោទទទួលបានឱកាសគ្រប់គ្រាន់ដែរឬទេ ក្នុងការត្រួតពិនិត្យ និងឆ្លើយតបទៅនឹង

សម្ភារដែលបានដាក់បង្ហាញនោះ ដែលការធ្វើបែបនេះ អនុញ្ញាតឲ្យមានការពិភាក្សាអំពីភស្តុតាងដោយយុត្តិធម៌ និងចំពោះមុខៗ

**១៩៥.** អង្គជំនុំជម្រះរំឭកថា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះបានកំណត់នីតិវិធីដែលអង្គជំនុំបានអនុវត្តដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ដែលអាចបណ្តាលមកពីការដាក់បង្ហាញឯកសារនេះទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទៗ អង្គជំនុំជម្រះបានសម្គាល់ថា ខ្លួនបានផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីអនុញ្ញាតឲ្យភាគីនានាអាចពិនិត្យមើលឯកសារដែលបានដាក់បង្ហាញ និងបញ្ជាក់ពីចេតនាក្នុងការផ្អាកសវនាការបន្ថែមទៀតទៅតាមសំណើៗ ក្នុងករណីសមស្របអង្គជំនុំជម្រះបានផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួនហើយជូនដំណឹងទៅភាគីថា សាក្សីអាចត្រូវបានកោះហៅមកវិញ ប្រសិនបើមានការបង្ហាញពីមូលហេតុសមស្របសម្រាប់ការកោះហៅមកវិញនោះៗ អង្គជំនុំជម្រះក៏បានចេញនូវគោលការណ៍ណែនាំកម្រិតទៅលើវិសាលភាពនៃការដាក់បង្ហាញឯកសារក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ និង ០០៤ ទៅដល់ភាគីនានានៅក្នុងសំណុំរឿង០០២/០២ៗ លើសពីនេះទៀត បន្ទាប់ពីបានដឹងថាមេធាវីការពារក្តីត្រូវការធនធានបន្ថែម អង្គជំនុំជម្រះបានទាក់ទងទៅការិយាល័យរដ្ឋបាល ដែលបានសន្យាថានឹងស្វែងរកប្រភពធនធានហិរញ្ញវត្ថុបន្ថែមដែលធានាដល់ដំណើរការដាក់បង្ហាញឯកសារនេះៗ ជាលទ្ធផលចាប់ពីខែមករា ឆ្នាំ២០១៦ រហូតដល់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងខែមិថុនា ឆ្នាំ២០១៧ ខៀវ សំផន និង នួន ជា បានទទួលមូលនិធិសម្រាប់ទីប្រឹក្សាច្បាប់ចំនួន ២នាក់ បន្ថែមក្នុងមួយក្រុមៗដើម្បីត្រួតពិនិត្យលើឯកសារដែលបានដាក់បង្ហាញទាំងនេះៗ

**១៩៦.** ក្រៅពីវិធានការទាំងនេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួននៅខែតុលា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានកម្រិតការដាក់បង្ហាញសម្ភារដែលសហព្រះរាជអាជ្ញាយល់ឃើញជាក់ស្តែងថាមានលក្ខណៈដោះបន្ទុកនឹងចម្លើយពីមុនរបស់សាក្សីដែលត្រូវផ្តល់សក្ខីកម្មប៉ុណ្ណោះ ហេតុដូច្នេះសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ត្រូវបានអនុញ្ញាតមួយផ្នែកៗ ចំពោះសម្ភារដាក់បន្ទុកឬសម្ភារផ្សេងទៀត អង្គជំនុំជម្រះបានណែនាំថា សម្រាប់សំណើនាពេលអនាគតទាំងអស់របស់ព្រះរាជអាជ្ញាដែលសុំ «សម្ភារពីសំណុំរឿង ០០៣ និង ០០៤ មកដាក់ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ទេនោះ ភាគីត្រូវជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីដទៃទៀតតាមរយៈសំណើសុំដែលមានសំអាងហេតុ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងៗ ហេតុនេះ អង្គជំនុំជម្រះបានតម្រូវឲ្យសហព្រះរាជអាជ្ញាបំពេញលក្ខខណ្ឌនីតិវិធីសម្រាប់ការទទួលយកភស្តុតាងថ្មី ដើម្បីដាក់ភស្តុតាងបែបនេះៗ អង្គជំនុំជម្រះបានកម្រិតបន្ថែមទៀតទៅលើលទ្ធភាពរបស់សហព្រះរាជអាជ្ញាក្នុងការដាក់សំណើ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកសម្ភារណាមួយពីសំណុំរឿង ០០៣ និង ០០៤ ដែលត្រូវដាក់បង្ហាញទៅក្នុងសំណុំរឿង ០០២/០២ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលបានចេញនៅក្នុងខែតុលា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះបានកំណត់ត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ សម្រាប់សហព្រះរាជអាជ្ញាក្នុងការដាក់សំណើសុំខាងលើៗ ការអនុវត្តបែបនេះគឺក្នុងគោលបំណងដើម្បីផ្តល់ដល់ជនជាប់ចោទនូវឱកាសដើម្បីឆ្លើយតបចំពោះសំណើបែបនេះ ហើយនឹងដើម្បីដាក់ភស្តុតាងបដិសេធនៅមុនពេលបញ្ចប់សវនាការពិនិត្យភស្តុតាងៗ

**១៩៧.** ចំពោះការលើកឡើងថា ការដាក់បង្ហាញសម្ភារថ្មីៗដែលបានពីកិច្ចស៊ើបសួរប្រឆាំងនឹងជនជាប់ចោទនោះ អង្គជំនុំជម្រះយល់ឃើញថាទឡ្ហីករណ៍នេះមិនមានមូលដ្ឋានត្រឹមត្រូវនោះឡើយៗ អង្គជំនុំជម្រះរំឭកថា ការដែលឯកសារពាក់ព័ន្ធត្រូវបានទទួលយកក្នុងដំណាក់កាលជំនុំជម្រះនោះមិនមានន័យថា កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ នៅខ្វះចន្លោះ ឬមិនបានបំពេញតាមបទដ្ឋានតម្រូវដូចដែលមេធាវីការពារក្តីបានអះអាងនោះទេៗ តាមពិតទៅ អង្គជំនុំជម្រះទទួលស្គាល់ភាពជាក់ស្តែងដែលថា ទោះបីជាមានការចេញដីកាដំណោះស្រាយក៏ដោយ ក៏អាច

មានភស្តុតាងថ្មីដែលអាចជួយដល់ការស្វែងរកការពិតផងដែរ។ សហព្រះរាជអាជ្ញា ក៏ដូចជាក្រុមមេធាវីការពារក្តីទាំងពីរដែរ បានប្រើប្រាស់ឱកាសនេះស្នើសុំឲ្យទទួលយកភស្តុតាងថ្មីនៅក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក្រោយពីពេលបញ្ចប់កិច្ចស៊ើបសួរមក។ មេធាវីការពារក្តី ខៀវ សំផន ខកខានក្នុងការបង្ហាញថា តើការធ្វើបែបនេះនាំឲ្យមានព្យសនកម្មដល់ជនជាប់ចោទតាមរបៀបណានោះទេ។

**១៤៨.** អង្គជំនុំជម្រះយល់ថា ដោយផ្អែកលើពេលវេលា និងធនធានបន្ថែមដែលបានផ្តល់ទៅមេធាវីការពារក្តី ព្រមទាំងការពារកម្រិតផ្នែកអង្គសេចក្តី និងនីតិវិធីដែលបានធ្វើឡើងសម្រាប់ការដាក់ឯកសាររបស់សហព្រះរាជអាជ្ញានេះ ដំណើរការបង្ហាញឯកសារនេះមិនបានរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការការពារក្តីប្រកបដោយប្រសិទ្ធភាពឬបានផ្តល់ប្រយោជន៍ដល់សហព្រះរាជអាជ្ញានោះឡើយ។

**២.៥.៦.** *ការជូនដំណឹងអំពីបទចោទ វិសាលភាពនៃការជំនុំជម្រះ និងភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២*

**១៤៩.** ទាំងមេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា បានលើកឡើងពីបញ្ហាទាក់ទងនឹងការជូនដំណឹងអំពីបទចោទ ព្រមទាំងវិសាលភាពនៃការជំនុំជម្រះ និងភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។

**២.៥.៦.១.** *ការកម្រិតចំពោះវិសាលភាពនៃការជំនុំជម្រះទៅលើអង្គហេតុនៅក្នុងដីកាដំណោះស្រាយដែលមានសារសំខាន់ ហើយដែលត្រូវកំណត់ថាជាការដាក់បន្ទុកទៅលើជនជាប់ចោទ*

**១៥០.** មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា មានតែអង្គហេតុនៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះដែលត្រូវបានកំណត់ថា ជាការដាក់បន្ទុកព្រហ្មទណ្ឌទៅលើជនជាប់ចោទដែលអង្គជំនុំជម្រះអាចយកមកពិចារណានៅក្នុងសាលក្រមរបស់ខ្លួន ដោយមេធាវីការពារក្តីបានដកស្រង់វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រនៃតុលាការប្រទេសបារាំងមកធ្វើជាការគាំទ្រ។ ហេតុដូច្នេះ មេធាវីការពារក្តីបានលើកឡើងថា ការវាយតម្លៃទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ត្រូវតែកម្រិតត្រឹមតែទៅលើអង្គហេតុដែលសំខាន់ ដែលត្រូវបានកំណត់ឡើងដើម្បីគាំទ្រដល់ការកំណត់ប្រភេទនៃបទល្មើសដែលបានចោទប្រកាន់។ អាចនិយាយម្យ៉ាងទៀតបានថា ជនជាប់ចោទមិនអាចត្រូវបានសម្រេចឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដោយផ្អែកលើអង្គហេតុនានាដែលមិនបានលើកឡើងនៅក្នុងដីកាដំណោះស្រាយនោះទេ។

**១៥១.** អង្គជំនុំជម្រះកត់សម្គាល់ថា វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងចែងថា ដីកាដំណោះស្រាយចាំបាច់ត្រូវតែលើកឡើងនូវការពណ៌នាពីអង្គហេតុសំខាន់ និងការកំណត់ប្រភេទបទល្មើសនៃអង្គហេតុទាំងនោះ។ នេះគឺជាកាតព្វកិច្ចដែលចាំបាច់ក្នុងការផ្តល់ការជូនដំណឹងទៅជនជាប់អំពីលក្ខណៈនៃបទចោទប្រឆាំងនឹងពួកគេ។ មេធាវីការពារក្តីបានសំអាងដែរទៅលើយុត្តិសាស្ត្រនៃតុលាការប្រទេសបារាំងដើម្បីគាំទ្រដល់គោលការណ៍គតិយុត្តទូទៅដែលថា អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវតែកម្រិតការសម្រេចរបស់ខ្លួន តែទៅលើអង្គហេតុនានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។ ចំណុចគតិយុត្តទូទៅនេះមិនមានការជំទាស់ឡើយ។ ក្នុងករណីដែលជនជាប់ចោទបញ្ជាក់ថា តើការអនុវត្តគោលការណ៍នេះតម្រូវឲ្យមានការកម្រិតដោយរបៀបណាទៅលើអង្គហេតុឬបទចោទដែលត្រូវបានចោទប្រកាន់ ដែលកំពុងស្ថិតក្នុងការពិចារណានោះ អង្គជំនុំជម្រះនឹងត្រួតពិនិត្យទៅលើទឡ្ហីករណ៍ទាំងនោះ។

**២.៥.៦.២.** *ការកំណត់បទចោទឡើងវិញ*

**១៥២.** មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះទទួលតែអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ មិនមែនទទួលការកំណត់បទចោទនោះទេ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។

**(តនៅលេខក្រោយ)**

# ការផ្លាស់ប្តូរពី «ទិវាចងកំហឹង» ទៅជា «ទិវាជាតិនៃការចងចាំ»

សោម ប៊ុនថន



ព្រះសង្ឃនៅកន្លែងតម្កល់អដ្ឋិធាតុរបស់ជនរងគ្រោះ នៅខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២០ ឧសភា គឺថ្ងៃដែលប្រជាជនកម្ពុជានៅរស់ជីវិតពីរបបខ្មែរក្រហមបានរំឭកឡើងវិញពីការឈឺចាប់ និងទុក្ខវេទនាដែលខ្លួនបានឆ្លងកាត់។ ២០ ឧសភា នេះ ត្រូវបានសភាជាតិនៃរបបសាធារណរដ្ឋនៃ «របបសាធារណរដ្ឋប្រជាមានិតកម្ពុជា» បានអនុម័តសម្រេចក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី១ ថ្ងៃទី១៥ ដល់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ៩៨៣ យកជាថ្ងៃ «ទិវាចងកំហឹង» ចំពោះបនប្រល័យពូជសាសន៍ប៉ុល ពត, អៀង សារី, ខៀវ សំផន និងជាថ្ងៃដែលរបបប្រល័យពូជសាសន៍ បានចាប់ផ្តើមអនុវត្តគោលការណ៍ប្រល័យពូជសាសន៍យ៉ាងចំហ និងយ៉ាងឃោរឃៅព្រៃផ្សៃចំពោះប្រជាជននៅទូទាំងប្រទេស។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចេញសេចក្តីប្រកាសជាផ្លូវការថា ប្រជាជនទូទាំងប្រទេសប្រមាណជាង៣លាននាក់ បានបាត់បង់ជីវិតក្រោមរបបដ៏សាហាវឃោរឃៅជាទីបំផុតក្នុងចុងសតវត្សរ៍ទី២០។ មូលហេតុដែលរបបសារធារណរដ្ឋប្រជាមាននិតកម្ពុជាជ្រើសយកថ្ងៃ ២០ឧសភា ជា «ទិវាចងកំហឹង» ព្រោះថ្ងៃនេះគឺជាថ្ងៃដែលក្រុមកុម្មុយនីស្តខ្មែរក្រហមបានប្រមូលផ្តុំប្រជាជន និងបង្កើតសហករណ៍នៅតាមតំបន់រំដោះក្នុងប្រទេសកម្ពុជា។ ប្រជាជនត្រូវបានប្រមូលឲ្យធ្វើការងាររួម ហូបរួម ហើយការទារុណកម្ម ការប្រព្រឹត្តអំពើឃោរឃៅ និងការកាប់សម្លាប់ក៏ចាប់កើតមានចាប់តាំងពីពេលនោះមកដែរ។ របបកម្ពុជាប្រជាធិបតេយ្យបានសរសេរនៅក្នុងសៀវភៅសិក្សាថ្នាក់ទី២ ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៧៦ ថា «សហករណ៍យើងបានចាប់កំណើតនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ក្នុងភ្លើងសង្គ្រាមបដិវត្តន៍ដ៏សន្ធោសន្ធៅ ប្រជាជនយើងបានវាយឈ្នះចក្រពត្តិអាមេរិក និងពួកអាក្បត់ជាតិ ហើយបានដឹករំលើងបុសគល់វណ្ណៈសក្តិភូមិ ម្ចាស់ដី និងនាយទុនរំដោះទឹកដី និងប្រជាជនទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥»។

នៅក្នុងរបបសាធារដ្ឋប្រជាមានិតកម្ពុជា (ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩) និងរបបរដ្ឋកម្ពុជា (ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩១) ថ្ងៃ ២០ឧសភា គឺជាថ្ងៃបុណ្យជាតិដ៏សំខាន់ និងត្រូវបានរៀបចំនៅតាមបូជនីយដ្ឋាននៅទូទាំងប្រទេស តាមរបៀបសាសនា និងប្រពៃណី។ ក្នុងឱកាសនោះ ព្រះសង្ឃ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរដ្ឋាភិបាល គ្រូបង្រៀន សិស្សានុសិស្ស កម្មករកសិករ និង ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមបានឡើងសម្តែងនូវអារម្មណ៍ឈឺចាប់ ទុក្ខវេទនាដែលក្រុមខ្មែរក្រហមបានប្រព្រឹត្តមកលើខ្លួន និងក្រុមគ្រួសារ និងបានថ្លែងថ្កោលទោសទៅដល់ក្រុមខ្មែរក្រហម។

ប៉ុន្តែក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រវាងភាគីជម្លោះនយោបាយ រួមមាន ១) រដ្ឋកម្ពុជា ២) ចលនាអ្នកតស៊ូខ្មែររាជានិយម ហ៊្វុនស៊ិនប៉ិចរបស់សម្តេចព្រះនរោត្តម សីហនុ, ៣) រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ៤) កម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ការប្រារព្ធទិវា «ចងកំហឹង» ២០ឧសភា លែងក្លាយជាបុណ្យជាតិផ្លូវការហើយ។ «ទិវាចងកំហឹង» ត្រូវបានប្រារព្ធឡើងតិចតួច និងនៅក្នុងគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ។

នៅអំឡុងឆ្នាំ១៩៩៨ ថ្ងៃ ២០ឧសភា ត្រូវបានរំឭកឡើងវិញដោយសាលាក្រុងភ្នំពេញនៅវាលពិឃាដបឹងជើងឯក និងនៅតាមបូជនីយដ្ឋាននានានៅទូទាំងប្រទេសដោយមានព្រះសង្ឃ ដូនជី តាជី មន្ត្រីរាជការ គ្រូបង្រៀន សិស្សានុសិស្ស និងប្រជាជនបានចូលរួមយ៉ាងច្រើនកុះករ ហើយពិធីនេះត្រូវបានស្គាល់ជាទូទៅថា «ទិវាចងចាំ»។ មកដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីទិវាជាតិនៃការចងចាំ មាន៤មាត្រា ដែលក្នុងមាត្រា១បានបញ្ជាក់ថា ត្រូវកំណត់យកថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំជា «ទិវាជាតិនៃការចងចាំ» ជាថ្ងៃបុណ្យជាតិផ្លូវការមួយនៅកម្ពុជាសម្រាប់ជាការរំឭកដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

រាជរដ្ឋាភិបាលកម្ពុជាកំណត់យកថ្ងៃ២០ឧសភា ជាទិវាជាតិនៃការចងចាំ ជាបុណ្យជាតិផ្លូវការ ក្នុងគោលបំណងលើកតម្កើងការរំឭកដល់ជនរងគ្រោះ ការស្តារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនគ្រោះ ទោះជានៅរស់ ឬក៏បានបាត់បង់ជីវិតក៏ដោយ, ប៉ះប៉ូវដល់ការឈឺចាប់ផ្លូវចិត្ត និងផ្នែកសង្គមដល់ជនរងគ្រោះ និងក្រុមគ្រួសារ, ចូលរួមក្នុងការផ្សះផ្សាជាតិ និងជំរុញឲ្យ

មានសុខដុមរមនីយកម្ម ក្នុងសង្គមកម្ពុជា, លើកកម្ពស់ការផ្សព្វផ្សាយ និងយល់ដឹងអំពីអំពើឃោរឃៅដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុំឲ្យកើតមានម្តងទៀត។

នៅក្នុងអនុក្រិត្យនេះក៏បានកំណត់ថាជាថ្ងៃឈប់សម្រាកសាធារណៈ ហើយប្រជាពលរដ្ឋគ្រប់រូបត្រូវបានផ្តល់ឱកាសឲ្យរៀបចំពិធីតាមជំនឿ សាសនា ឬទំនៀមទម្លាប់របស់ខ្លួន។

ចំណែកសាលាក្តីខ្មែរក្រហមក៏បានកំណត់យកទិវាជាតិនៃការចងចាំ ថ្ងៃ២០ឧសភា គឺជាសំណងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះ ដែលជាដើមបណ្តឹងក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីជនរងគ្រោះបានស្នើទៅតុលាការសាលាក្តីខ្មែរក្រហម។ ទិវាជាតិនៃការចងចាំ នេះគឺជាសំណងសមូហភាពមួយក្នុងចំណោមសំណងសមូហភាពផ្សេងទៀត ដែលបានផ្តល់ដោយសាលាក្តីខ្មែរក្រហម។



ព្រះសង្ឃនៅកន្លែងតម្កល់អដ្ឋិធាតុរបស់ជនរងគ្រោះនៅឃុំឈើទាល ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ហ៊ុយ ម៉ាន់ ៖ ពលទាហាន

***ប្រពន្ធរបស់គាត់ ផុន សំអាន បាននិយាយរឿងរ៉ាវប្រាប់ថា ៖***

*ខ្ញុំមិនទាន់មានស្នេហាពិតប្រាកដនៅឡើយនៅពេលដែលខ្ញុំអាយុបាន១៨ឆ្នាំ។ ម៉ាន់ និងខ្ញុំ បានជួបគ្នានាថ្ងៃចូលឆ្នាំខ្មែរ នៅពេលដែលគាត់ឈប់សម្រាករយៈពេលខ្លីពីកងទ័ព។ វាគឺជាស្នេហាលើកដំបូងសម្រាប់គាត់។ នៅពេលដែលគាត់បាននាំប្រធានអង្គភាពរបស់គាត់ស្នើម្តាយខ្ញុំសុំខ្ញុំរៀបការ ខ្ញុំមិនមានអារម្មណ៍ស្រឡាញ់គាត់ទេ។ ប៉ុន្តែខ្ញុំបានយល់ព្រមតាមការរៀបចំរបស់ឪពុកម្តាយខ្ញុំ។ ចៅហ្វាយរបស់គាត់ និងលោក ឡាយ សំ វរសេនីយ៍ឯកនៅអង្គភាព៥៥៤បានចូលរួមពិធីមង្គលការរបស់ខ្ញុំ ប៉ុន្តែមិនមែនជាឪពុកម្តាយរបស់ ម៉ាន់ ទេ។*



*ផុន សំអាន នៅថ្ងៃពិធីមង្គលការរបស់នាង នៅឆ្នាំ១៩៧២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ ប្រជាជនបានភៀសខ្លួនចេញពីភូមិរបស់យើង នៅក្នុងខេត្តកណ្តាល ព្រោះប្រជាជនមិនចង់ចូលរួមជាមួយខ្មែរក្រហម។ គ្រួសាររបស់ខ្ញុំបានផ្លាស់ទៅរស់នៅក្នុងបន្ទាយទាហានរបស់ប្តីខ្ញុំ ជាទីកន្លែងដែលទាហានអាមេរិកបានចែកស្បៀងអាហារឲ្យយើង។*

*ជាភរិយារបស់ទាហានម្នាក់ មានការពិបាកយ៉ាងខ្លាំងនៅពេលនោះ។ ខ្ញុំបានខ្ចប់ស្បៀងអាហារដាក់ក្នុងប្រអប់ស្លឹកត្នោត ហើយយកទៅឲ្យប្តីខ្ញុំនៅលើសមរភូមិប្រយុទ្ធ ទោះជាគាត់បានប្រាប់ខ្ញុំកុំឲ្យប្រថុយប្រថានជីវិតខ្ញុំធ្វើដូច្នេះក៏ដោយ។ យោធាខ្មែរក្រហមបានចូលមកកាន់តែកៀកទាហាន លន់ នល់ បានបាត់បង់ភាពក្លាហានរបស់ខ្លួន និងលើកទង់ជ័យស ដោយដឹងថាខ្លួនមិនអាចឈ្នះខ្មែរក្រហម។ បន្ទាប់មក ម៉ាន់ អាចត្រឡប់មកផ្ទះជួបខ្ញុំ និងកូនៗ។*

*គ្រួសាររបស់ខ្ញុំបានព្យាយាមទៅក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ប៉ុន្តែយើងមិនត្រូវបានអនុញ្ញាតឲ្យចូលទីក្រុងឡើយ ខ្មែរក្រហមបាននិយាយថាកងកម្លាំងអាកាសអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីនោះក្នុងពេលឆាប់ៗនេះ។ ឪពុករបស់ខ្ញុំចង់*

ទៅស្រុកកំណើតរបស់គាត់យ៉ាងខ្លាំង គាត់ជាបុរសម្នាក់មានការអប់រំ និងគិតថាខ្មែរក្រហមនឹងឲ្យឋានៈការងារមួយនៅទីនោះ។ គាត់បានសួរអ្នកភូមិខ្លះ ប្រសិនបើយើងអាចទៅជាមួយគេតាមរថយន្តធំ។ ខ្ញុំបាននិយាយទៅគាត់ថា «ប៉ា វាមិនប្រើពេលយូរទេ បើដើរទៅកាន់ស្រុកកំណើតរបស់យើង។ ប្រសិនបើប៉ាចង់ទៅតាមរថយន្តធំ ទៅតែម្នាក់ឯងទៅ» ឪពុករបស់ខ្ញុំ ខឹងខ្ញុំយ៉ាងខ្លាំង និងអ្នកផ្សេងទៀតនៅក្នុងគ្រួសាររបស់យើង ព្រោះមិនស្តាប់គាត់។ គាត់បានឡើងរថយន្តធំនោះ ប៉ុន្តែវាបានចេញឆ្ពោះទៅខេត្តបាត់ដំបងជំនួសវិញ។ ការប៉ងប្រាថ្នារបស់គាត់មិនបានសម្រេច ហើយឪពុករបស់ខ្ញុំបានបាត់ខ្លួនរហូត។

នៅក្នុងសហករណ៍ កូនស្រីរបស់ខ្ញុំម្នាក់អាយុបានមួយឆ្នាំ បានហូបរបស់រឹង ហើយវាបានរាកមួលមិនឈប់ ខ្ញុំក៏បានយកវាទៅមន្ទីរពេទ្យ។ ម្តាយរបស់ខ្ញុំឈ្មោះ អ៊ិម ប៉ុក បានផ្លាស់វេនគ្នានៅកំដរនាង។ កម្មាភិបាលពេទ្យបានចាក់ថ្នាំឲ្យកូនស្រីខ្ញុំ ម្តាយខ្ញុំនិយាយថា កូនស្រីខ្ញុំបានស្លាប់គួរឲ្យរន្ធត់។ គាត់ចង់កប់សាកសពចៅស្រីរបស់គាត់ ប៉ុន្តែគ្រូពេទ្យក្មេងម្នាក់បានយកសពរបស់នាងចេញទៅ ហើយមិនអនុញ្ញាតឲ្យម្តាយខ្ញុំទៅតាមឡើយ។ នៅពេលដែលខ្ញុំបានដឹងថាកូនស្រីខ្ញុំស្លាប់ ខ្ញុំរត់ទៅមន្ទីរពេទ្យ ប៉ុន្តែពេលខ្ញុំទៅដល់ វាយឺតពេលហើយ។ នៅថ្ងៃនោះរបបរបស់ខ្ញុំបានឲ្យទៅអ្នកផ្សេងទៀត។

ស្រូវរបស់ភូមិយើងបានប្រើប្រាស់អស់មិនដល់មួយឆ្នាំផង ហើយគ្រួសារ



ហ៊ុយ ម៉ាន់
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់យើងបានបែកគ្នា។ នៅពេលខ្លះយើងអាចជួបជុំគ្នា ហើយប្តីរបស់ខ្ញុំតែងតែព្យាយាមទៅរកស្បៀងសម្រាប់គ្រួសារ។

ម៉ាន់ មិនចេះហែលទឹកទេ នាពេលមួយនោះ គាត់បានប្រថុយជីវិតរបស់គាត់ឆ្លងស្ទឹង នៅអំឡុងរដូវវស្សាទៅរកបន្លែខ្លះសម្រាប់យើង។ គាត់ស្ទើរតែលង់ទឹកស្លាប់ ប៉ុន្តែប្អូនប្រុសពៅរបស់គាត់បានជួយគាត់។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានប្រឹងប្រែងអស់ពីសមត្ថភាពរបស់គាត់ ដោយទទួលបានអំបិលមួយក្រឡធំ និងឯកសណ្ឋានយោធាពីរពីអ្នកភូមិដែលមានចិត្តល្អ។ ខ្ញុំតែងតែអះអាងថា ប្តីរបស់ខ្ញុំជាកសិករក្រីក្រម្នាក់នៅពេលដែលខ្មែរក្រហមបានសួរអំពីប្រវត្តិរូបរបស់គាត់។ ប៉ុន្តែការរក្សាការសម្ងាត់មួយមិនអាចលាក់បានឡើយ ចំពោះអង្គការដែលមានបណ្តាញច្រើន ហើយបានស៊ើបសួរអ្នកទាំងនោះអំពីប្តីរបស់ខ្ញុំ។ នៅខែកក្កដា ឆ្នាំ១៩៧៧ គាត់ត្រូវបានបញ្ជូនឲ្យទៅកាប់ឈើ។ នៅពេលដែលគាត់ចេញទៅ គាត់និយាយថា «ប្រសិនបើខ្ញុំមិនត្រឡប់មកវិញក្នុងពីរបីថ្ងៃទៀត ខ្ញុំប្រហែលជាត្រូវបានចាប់ខ្លួន ឬធ្វើទារុណកម្ម ដោយយោធាខ្មែរក្រហមហើយ។ ប្រសិនបើវាកើតឡើង ខ្ញុំនឹងធ្វើអត្តឃាត។ សូមជួយមើលថែរក្សាកូនៗរបស់យើងឲ្យបានល្អផង»។ នៅពេលនោះខ្ញុំបានពរពោះ ៧ ខែ។ មួយអាទិត្យក្រោយមក ខោអាវរបស់គាត់បានយកមកភូមិវិញ ឲ្យអ្នកផ្សេងទៀតស្លៀកពាក់។ ខ្ញុំស្គាល់ខោអាវទាំងនោះ ព្រោះអីខ្ញុំបានដេរដោយផ្ទាល់ដៃរបស់ខ្ញុំ។ ពីរខែនិងប្រាំថ្ងៃបន្ទាប់ពីប្តីរបស់ខ្ញុំបានចាប់យកទៅ ខ្ញុំឆ្លងទន្លេបានកូនប្រុសមួយទៀត។

ខ្មែរក្រហមបិះតែនឹងសម្លាប់ខ្ញុំ ព្រោះខ្ញុំចង់ដឹងរឿងពីប្តីរបស់ខ្ញុំ។ ខ្ញុំបានសួរប្រធានកង «នៅពេលណាប្តីរបស់ខ្ញុំត្រឡប់មកផ្ទះវិញ?»។ អ្នកភូមិបានខ្សឹបប្រាប់ថាសមមិត្ត អាន នឹងបញ្ជូនខ្ញុំឲ្យទៅរស់នៅជាមួយប្តីរបស់នាង ប្រសិនបើនាងបន្តសួរដូច្នេះ។ អ្នកមូលដ្ឋានម្នាក់ ឈ្មោះ លឿង បានប្រាប់ខ្ញុំថា កុំឲ្យសួរអំពីប្តីរបស់ខ្ញុំទៀត ខ្ញុំអាចនឹងត្រូវសម្លាប់ ហើយថា ម៉ាន់ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស្អាង។ បន្ទាប់ពីនោះមក ខ្ញុំមិនហ៊ានសួរទៀតឡើយ។

នៅពេលដែលរបបខ្មែរក្រហមបានដួលរលំទៅ ខ្ញុំមានសំណាងណាស់ខ្ញុំនៅរស់រានមានជីវិត។

**ប៉ាង ពីច័ន្ទ និង ខេនី ខកហ្គៀល**

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# កូវ ជ័រ ៖ ពលទាហាន

**ប្រពន្ធរបស់គាត់ សរិត គិត បាននិយាយរៀបរាប់ប្រាប់ថា៖**

*កូវ ជ័រ បានរៀបការជាមួយខ្ញុំនៅពេលដែលគាត់មានអាយុ២២ឆ្នាំ ចំណែកនាងខ្ញុំអាយុ១៨ឆ្នាំ។ ទោះជាយើងបានរស់នៅក្នុងភូមិជាមួយគ្នាក៏ដោយ យើងមិនដែលធ្លាប់ជួបគ្នា មុនពេលដែលឪពុកម្ដាយរបស់គាត់ចូលមកខាងខ្ញុំ ដើម្បីរៀបចំការភ្ជាប់ពាក្យរបស់យើងទេ។ ឪពុកម្ដាយរបស់ខ្ញុំបានសុំថ្លៃបណ្ណាការចំនួន ១០០រៀល ដែលកាលណោះ ប្រាក់១០០រៀលមានតម្លៃខ្លាំងណាស់។ ឪពុកម្ដាយរបស់គាត់ស្រឡាញ់ខ្ញុំហើយគាត់បានយល់ព្រម។ នៅថ្ងៃមង្គលការរបស់យើង យើងបានសម្លាប់សត្វជ្រូកជាច្រើនក្បាលដើម្បីធ្វើម្ហូបទទួលភ្ញៀវ។*

*បន្ទាប់ពីយើងរៀបការរួច ប្ដីរបស់ខ្ញុំបានចូលមករស់នៅខាងឪពុកម្ដាយរបស់ខ្ញុំ។ យើងជាអ្នកក្រីក្រ ហើយកម្រមានអាហារហូបគ្រប់គ្រាន់ណាស់។ ជ័រ មិនមានចម្ការទេ យើងក៏មិនមានស្រែដែរ ដូច្នេះគាត់បានធ្វើការងារផ្សេងៗ ដូចជា លក់ខស និងលក់នំ។ នៅពេលខ្លះយើងបានចេញពីភូមិរបស់យើងនៅក្នុងខេត្តកណ្ដាល ទៅភ្នំពេញបួនប្រាំថ្ងៃដើម្បីលក់ទំនិញនៅតាមផ្សារ។ ក្រោយមកគាត់បានចូលបម្រើកងទ័ព លន់ នល់។*



*កូវ ជឿន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*កូនប្រុសរបស់ខ្ញុំឈ្មោះ កូវ ជឿន បានបួសជាសង្ឃចំនួនបីវស្សាមុនពេលចូលធ្វើជាទាហាន។ ជឿន ជាក្មេងសុភាពរាបសារ និងមិនដែលប្រើពាក្យគ្រោតគ្រាតទេ។ ជឿន ជាកូនប្រុសតែមួយគត់នៅក្នុងចំណោមកូន១៣នាក់របស់យើង។ កូនស្រីៗរបស់ខ្ញុំបានឈ្លោះប្រកែកគ្នារាល់ពេល ប៉ុន្តែ ជឿន ប្លែកពីគេ។ ប្រសិនបើបងប្អូនស្រីៗ រឺគ្នាដណ្ដើមសាច់ត្រីពេលហូបល្ងាច ជឿន ហូបបាយតែបន្តិចបន្តួចប៉ុណ្ណោះ ហើយក៏ដើរចេញពីផ្ទះទៅ។*

*ជឿន បានសម្រេចចិត្តចូលបម្រើកងទ័ព លន់ នល់ បន្ទាប់ពីបានឮការឃោសនា។ ការចូលធ្វើកងទ័ពនេះ គឺចូលដោយបង្ខំចិត្ត។ ជឿន បានរៀបការជាមួយស្ត្រីម្នាក់ឈ្មោះឈូក រុំ ហើយបានមករស់នៅខាងផ្ទះប្រពន្ធ និងមានកូនប្រុសម្នាក់។*

*ជឿន ត្រូវបានបញ្ជូនទៅសមរភូមិកប់ស្រូវប្រហែល១៥ថ្ងៃមុនពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ។ ជឿន ត្រូវរបួសចំជើង ហើយត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យរុស្ស៊ី*

ប៉ុន្តែបានស្លាប់ព្រោះការព្យាបាលមិនបានដិតដល់។ ខ្ញុំបានយកសពរបស់ជឿន ទៅផ្ទះប្រពន្ធរបស់វានៅស្រុកកំណើត ដើម្បីបូជា។ ប្រពន្ធរបស់ ជឿន បានស្រែកយំយ៉ាងខ្លាំងទាល់តែទឹកភ្នែកនាងលែងហូរ។ កូនប្រុសរបស់ ជឿន មានវ័យអាចអង្គុយបាន នៅពេលដែល ជឿន ស្លាប់។

ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ពីការបាត់បង់កូនប្រុសតែមួយរបស់ខ្ញុំ។ ខ្ញុំស្រឡាញ់វាស្មើជីវិតរបស់ខ្ញុំ។ ប្រសិនបើប្រទេសកម្ពុជាមិនមានសង្គ្រាមទេ ជឿន មិនស្លាប់ទេ។ មុនពេលខ្មែរក្រហមឡើងកាន់អំណាចបន្តិច គ្រួសារយើងបានចាកចេញពីភូមិដើម្បីគេចពីគ្រាប់បែក រួចបានទៅភូមិក្រាំងទ្រា នៅខេត្តកណ្តាល។ យើងមិនបានយករបស់មានតម្លៃទៅតាមខ្លួនទេ ព្រោះយើងមិនមានអ្វីឡើយ។ យើងយកបានខោអាវដែលយើងកំពុងស្លៀកពាក់។ យើងបានត្រឡប់ទៅភូមិវិញ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់អំណាចទាំងស្រុង។ លើកនេះខ្ញុំមានឯកសណ្ឋានរបស់ប្តីខ្ញុំ និងរូបថតរបស់ គាត់ជាទាហានមួយចំនួន ប៉ុន្តែខ្ញុំបានដុតចោលអស់ហើយ។

ទោះបីជាយើងមកពីភូមិមួយក៏ដោយ ក៏ខ្មែរក្រហមបាននិយាយថា យើងគឺជាប្រជាជនថ្មី។ យើងមិនបានរស់នៅជាមួយប្រជាជនមូលដ្ឋានទេ យើងក៏មិនមានអាហារគ្រប់គ្រាន់ដែរ គឺមានតែបបរលាយជាមួយពោត។ ក្រោយមក អង្គការបានប្រមូលយករបស់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់យើងមាន អង្ករ ចាន ឆ្នាំង និងអ្វីៗទាំងអស់ដាក់បញ្ចូលទៅក្នុងសហករណ៍



កូវ ជីវ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លើកលែងតែខោអាវដែលយើងកំពុងស្លៀកពាក់។ ការងាររបស់ខ្ញុំ ជាអ្នកប្រមូលសំរាមតាមផ្ទះជាច្រើន ហើយយកទៅកន្លែងមួយដែលខ្ញុំលាយធ្វើជាជី។ ដូច្នេះខ្មែរក្រហមបានឲ្យបបរខ្ញុំបីវែក ចំនួនពីរពេលក្នុងមួយថ្ងៃ ដែលវាមិនគ្រប់គ្រាន់ឡើយសម្រាប់ការងារដែលខ្ញុំធ្វើ។ ក្រពះរបស់ខ្ញុំមិនដែលពេញឡើយ បន្ទាប់ពីយើងចាប់ផ្តើមរស់នៅក្នុងសហករណ៍។

អង្គការសង្ស័យលើប្រជាជនដែលកោរសក់ក្បាលដើម្បីបំបាត់ចៃ ដោយគិតថាអ្នកកោរសក់ទាំងនោះប្រារព្ធធ្វើបុណ្យ និងបន់ស្រន់នៅក្នុងព្រះវិហារ។ ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រឡើងវិញ និងសួរសំណួរដេញដោលជាច្រើន។

ជីវ បានទៅសម្រាកនៅមន្ទីរពេទ្យចំនួនពីរខែ ដើម្បីព្យាបាលជំងឺរាកមួល។ គាត់មិនចង់លេបថ្នាំគ្រាប់អាចម៍ទន្សាយដែលផលិតដោយអង្គការទេ។ ខ្ញុំចាប់បានអន្ទង់មួយចំនួនរួចលាក់យកទៅឲ្យគាត់ហូប ប៉ុន្តែអង្គការបានឆែកឃើញរួចក៏ដកហូតយកទាំងអស់។ បន្ទាប់មកប្តីរបស់ខ្ញុំក៏បានស្លាប់ ប្រជាជនថ្មីមួយចំនួនបានជួយសែងសាកសពប្តីខ្ញុំយកទៅកប់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំបានត្រឡប់ទៅផ្នូររបស់ ជីវ។ ខ្ញុំបានជីកកកាយដីរកឃើញលលាដ៍ក្បាល និងធ្មេញរបស់គាត់។ ខ្ញុំបានយកឆ្អឹងរបស់គាត់ទៅវត្ត ដើម្បីប្រារព្ធពិធីបុណ្យបង្សុកូលឧទ្ទិសជូនគាត់។ ខ្ញុំមិនមានអារម្មណ៍ល្អឡើយ ដោយសារខ្ញុំមិនមានឱកាសនិយាយជាមួយ ជីវ ព្រោះអង្គការមិនអនុញ្ញាតឲ្យខ្ញុំស្នាក់នៅថែទាំគាត់នៅក្នុងមន្ទីរពេទ្យទេ។

ខ្ញុំបានរក្សាទុករូបថតពីរសន្លឹកនេះយ៉ាងប្រយ័ត្នប្រយែងនៅក្នុងរបបនោះ។ ខ្ញុំបានទុកដាក់រូបថតនោះនៅក្នុងថង់ប្លាស្ទិកមួយ រួចដាក់នៅក្នុងថង់មួយទៀតនៅខាងក្នុងហោប៉ៅអាវរបស់ខ្ញុំទោះជាដើរទៅទីណាក៏ដោយ ព្រោះអីខ្ញុំខ្លាចអង្គការរកឃើញរូបថតនោះនៅផ្ទះរបស់ខ្ញុំ។ យប់មួយនោះ នៅពេលដែលខ្ញុំដើរតាមប្រឡាយ ខ្ញុំបានដើរទាក់នឹងខ្សែដែលភ្ជាប់នឹងអំពូលភ្លើងសម្រាប់បំភ្លឺដល់អ្នកធ្វើការនាពេលយប់។ ខ្ញុំភ័យតក់ស្លុតជាខ្លាំងធ្វើឲ្យខ្ញុំធ្លាក់ចូលទៅក្នុងប្រឡាយទឹក ទទឹកសើមជោគ។ នៅពេលដែលខ្ញុំមកដល់ផ្ទះវិញ ខ្ញុំបានយករូបថតនោះចេញមកហាលឲ្យស្ងួតដោយលាក់លៀម។ ហេតុដូច្នេះបានជារូបថតនោះមានស្នាមប្រេតកប្រតាកមកដល់ថ្ងៃនេះ។

**ប៉ាង ពីច័ន្ទ និង ទេរី ខករហ្គៀល**

### «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# គង ណាន ៖ ពលទាហាន



រូបទីពីរាប់ពីខាងឆ្វេង៖ កង ណាន នៅឆ្នាំ១៩៧០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតនេះបានថតនៅក្នុងទីក្រុងភ្នំពេញ នៅក្នុងអំឡុងរបប លន់ នល់។ ខ្ញុំបានផ្លាស់ទីលំនៅទៅភ្នំពេញដើម្បីរស់នៅជាមួយប្អូនៗជីដូនមួយរបស់ខ្ញុំ ព្រោះខ្ញុំមិនចង់ចូលរួមជាមួយខ្មែរក្រហមទេ។ ខ្ញុំមិនប្រាកដថាហេតុអ្វីមិត្តភក្តិរបស់ខ្ញុំ និងខ្ញុំបានសម្រេចចិត្តថតរូបទាំងមិនបានស្លៀកពាក់ស្អាតបាតអ៊ុចឹងទេ។ ខ្ញុំបានស្លៀកខោសាកកន្ត្រាក និងពាក់ស្បែកជើងផ្ទាត់។

ប្រពន្ធរបស់ខ្ញុំឈ្មោះ វ៉ៃន សំ លក់នំ ផ្លែឈើ និងបង្អែមនៅភ្នំពេញនៅពេលដែលយើងបានជួបគ្នា។ ខ្ញុំបានទិញបង្អែមរបស់នាងញឹកញាប់ ប៉ុន្តែមិនបានចាប់អារម្មណ៍ពីនាងខ្លាំងក្លាឡើយ។ ថ្ងៃមួយនោះ ម្តាយធម៌របស់ខ្ញុំបានយករូបថតនាងមកឲ្យខ្ញុំមើល។ ខ្ញុំស្គាល់នាងជាស្ត្រីដែលខ្ញុំបានទិញនំរបស់នាងនៅផ្សារដូច្នេះខ្ញុំបានទៅសុំនាងរៀបការ។ យើងបានរៀបការនៅចុងឆ្នាំ១៩៧០។ សំ មិនបានរៀនសូត្រច្រើនទេ ព្រោះគ្រួសាររបស់នាងក្រីក្រ។ នៅសម័យនោះ កូនប្រុសៗត្រូវបានឲ្យឱកាសចូលសាលារៀនមុន។

ខ្ញុំមិនបានស្ម័គ្រចិត្តចូលធ្វើជាទាហាន លន់ នល់ ទេ។ ប្រជាជនត្រូវបានចាប់ និងបង្ខំឲ្យចូលរួម ហើយខ្ញុំមិនអាចគេចវេះបានឡើយ។ នៅពេលដែលខ្ញុំក្លាយទៅជាសមាជិកម្នាក់នៃកងទ័ពនៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានបញ្ជូនទៅរៀនក្បួនយុទ្ធសាស្ត្រយោធា។ ខ្ញុំបានរត់ចេញពីការិយាល័យយោធា ប៉ុន្តែគេបានចាប់ខ្ញុំ និងបង្ខំឲ្យខ្ញុំចូលរួមជាថ្មីម្តងទៀត។

បន្ទាប់ពីខ្ញុំបានបញ្ចប់វគ្គបណ្តុះបណ្តាលមក ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅខេត្តកណ្តាលជាជំនួយការទាហានម្នាក់។ គេបាននិយាយថា គេនឹងបញ្ជូនខ្ញុំទៅខ្សែត្រៀមខាងមុខ ប្រសិនបើអង្គភាពផ្សេងទៀតត្រូវការជំនួយ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ គេបានបញ្ជូនខ្ញុំទៅសមរភូមិទួលក្រសាំង។



*វ៉ែន សំ នៅឆ្នាំ១៩៧០។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បន្ទាប់មក ឪពុកមាររបស់ប្រពន្ធខ្ញុំបានសុំយើងឲ្យទៅរស់នៅជាមួយគាត់ យើងបានយល់ព្រម។ គាត់ជាវរសេនីយ៍ឯកម្នាក់។ បន្ទាប់ពីយើងផ្លាស់មករស់នៅក្នុងផ្ទះគាត់ ខ្ញុំមិនបានចេញទៅសមរភូមិទៀតឡើយ។ ប្រពន្ធរបស់ខ្ញុំ និងខ្ញុំមើលថែទាំកូនរបស់គាត់។

ខ្ញុំបានយកខោអាវដដែល ដែលខ្ញុំបានស្លៀកពាក់នៅក្នុងរូបថត ទៅតាមខ្លួននៅពេលដែលខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។ បន្ទាប់មកខ្ញុំបានដូរខោអាវនោះយកជាស្បៀងអាហារជាមួយប្រជាជនមូលដ្ឋាន។ ប្រជាជនមូលដ្ឋានពិតជាចូលចិត្តអាវយឺតរបស់ខ្ញុំ។

នៅក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំបានរស់នៅជាមួយប្រពន្ធរបស់ខ្ញុំ ឪពុកម្តាយរបស់ខ្ញុំ បងប្អូនប្រុសស្រី និងសាច់ញាតិច្រើននាក់ ទោះបីយ៉ាងណាយើងស្ទើរតែបែកគ្នាម្តងៗ។ ខ្មែរក្រហមបានចូលមករុករកផ្ទះរបស់យើងច្រើនដង ប៉ុន្តែមិនបានរកអ្វីឃើញឡើយ និងមិនបានចោទប្រកាន់ខ្ញុំថាបានធ្វើអ្វីខុសដែរ។ ក្នុងចំណោមកូនៗ៧នាក់ នៅក្នុងគ្រួសាររបស់យើងមានតែកូនពីរនាក់ប៉ុណ្ណោះដែលនៅមានជីវិតនៅក្នុងរបបនោះ។

**ប៉ាង ពីច័ន្ទ និង ទេនី ខកហ្គៀល**

# ព្រឹត្តិការណ៍ ថ្ងៃ១៧មេសា
## ឧក្រិដ្ឋកម្មមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
## កៅ សំរិទ្ធ

***ផែនការ «១ហិកតា ៣តោន» ក្រោមមាគ៌ាមហាលោតផ្លោះមហាអស្ចារ្យ***

ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាជនត្រូវបានបែងចែកជា២ប្រភេទ គឺ ប្រជាជនមូលដ្ឋានចាស់ដែលជាអ្នករស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីឆ្នាំ ១៩៧០ និងប្រជាជន ១៧មេសា (ឬប្រជាជនថ្មី) ដែលជាអ្នកធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលលន់ នល់។ ប្រជាជន ១៧មេសាត្រូវអ្នកមូលដ្ឋានចាស់រើសអើង និងប្រមាថមាក់ងាយយ៉ាងខ្លាំង ហើយទទួលរងការកាប់សម្លាប់យ៉ាងរង្គាលជាពិសេសអតីតទាហាន និងប៉ូលីស។ ប៉ុល ពត នួន ជា ដែលជាមេខ្លោងរបស់ខ្មែរក្រហមបានដាក់ចេញនូវគោលនយោបាយ៨ចំណុច ដែលចំណុចទី៥ គឺកម្ទេចទាំងអស់នូវមន្ត្រីរដ្ឋការរបប លន់ នល់។ ការអនុវត្តចំណុចនេះមានកំរិតតឹងតែងខុសគ្នាទៅតាមការចាត់ចែងដឹកនាំរបស់កម្មាភិបាលនៅតាមមូលដ្ឋាន។



កៅ សំរិទ្ធ

នៅស្រុកជីក្រែងជាទីដែលគ្រួសារខ្ញុំជម្លៀសទៅក្នុង២ឆ្នាំដំបូង (មុនការមកដល់របស់ភូមិភាគនិរតី) មិនមានការសម្លាប់ពេទ្យ គ្រូបង្រៀន និងបណ្ដាបញ្ញវន្តទេ គឺសម្លាប់តែទាហានប៉ូលិសនិងអ្នករដ្ឋការថ្នាក់ខ្ពស់។ ក្នុងជួរមន្ត្រីប្រដាប់អាវុធ អ្នកដែលមានឋានៈចាប់ពីស័ក្តិមួយ(អនុសេនីយ៍ត្រី) ឡើងទៅត្រូវបានសម្លាប់ទាំងគ្រួសារ ចាប់ពីឋានៈព្រិន្ទបាលឯកចុះក្រោមត្រូវលើកលែងមិនសម្លាប់ប្រពន្ធកូន។ ឯស្រុកស្វាយលើជាប់គ្នានឹងស្រុកជីក្រែងឯណោះវិញ គ្រូបង្រៀនរួមទាំងប្រពន្ធកូន និងអ្នករស់នៅជាមួយត្រូវអន្តរធានស្ទើរទាំងអស់។ ដោយឡែកស្រុកបារាយណ៍ខេត្តកំពង់ធំដែលជាស្រុកកំណើតរបស់ប្រពន្ធខ្ញុំ បណ្ដាមនុស្សដែលជម្លៀសចេញពីទីក្រុងត្រូវគេសម្លាប់ផ្ដាច់ពូជចាប់តាំងពីទារករហូតដល់មនុស្សជរាដើរមិនរួច។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្រោមការដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជាបានកំណត់យកកសិកម្មជាមូលដ្ឋានគ្រឹះក្នុងការកសាងសេដ្ឋកិច្ចជាតិក្រោមពាក្យស្លោក «មានស្រូវគឺមានអ្វីៗទាំងអស់» ដូច្នេះហើយបានជាទាំងប្រជាជនមូលដ្ឋានចាស់ទាំងប្រជាជនថ្មី១៧មេសា ត្រូវអង្គការបក្ស

ជំរុញឲ្យបង្កបង្កើនផលស្រូវយ៉ាងពេញទំហឹង។ កម្មសិទ្ធិដីធ្លីត្រូវបានលុបបំបាត់ចោលទាំងស្រុង ហើយអ្វីៗគ្រប់យ៉ាងគឺជាទ្រព្យសម្បត្តិរបស់សមូហភាព។ រដ្ឋបាលសាធារណៈ ទីផ្សារ សាលារៀន សូម្បីតែមន្ទីរពេទ្យក៏ត្រូវបំបិទចោល ហើយគ្រប់ៗគ្នាត្រូវចូលរួមក្នុងការបង្កបង្កើនផលស្រូវ។ គណៈដឹកនាំមូលដ្ឋានចាប់ពីថ្នាក់សង្កាត់ឡើងទៅសុទ្ធសឹងជាកម្មាភិបាលក្នុងជួរដែលចេះអានចេះសរសេរបានតិចតួចតែចេះទ្រឹស្តីបដិវត្តន៍ច្រើន ហើយរាល់សម្តីរបស់ពួកគេគឺជាបញ្ជាដែលមិនអាចប្រកែក ឬតវ៉ាបានឡើយ។ នាខែវិច្ឆិកា១៩៧៥ អង្គការបក្សបានរៀបចំធ្វើមហាសន្និបាតសេដ្ឋកិច្ចដោយកំណត់ផែនការបង្កើតទិន្នផលស្រូវឲ្យកើនជាលំដាប់ដូចតទៅ៖

- ១៩៧៦: សម្រេចទិន្នផល៣តោនក្នុង១ហិកតា
- ១៩៧៧: ៤-៥តោន
- ១៩៧៨ :៦-៧ តោន

ផែនការខាងលើនេះជាផែនការធំហួសមាឌ គឺដោយសារតែមហិច្ឆតារបស់ ប៉ុល ពត ដែលមិនគិតគូរទាល់តែសោះដល់លទ្ធភាពនៃការអនុវត្តក្នុងស្ថានភាពដ៏លំបាក គឺប្រទេសជាតិទើបតែចប់សង្គ្រាមដ៏មហន្តរាយ និងពោរពេញទៅដោយការកាប់សម្លាប់ធនធានមនុស្សដែលប្រកបដោយសក្តានុពល។ ដោយដើរតាមមនោគមន៍វិជ្ជាបដិវត្តន៍វប្បធម៌របស់ចិន អង្គការបក្សក៏ដាក់ចេញនូវផែនការនយោបាយប្រកបដោយគ្រោះថ្នាក់មួយ គឺបន្តតស៊ូប្រឆាំងពួកចក្រពត្តិនិយម តស៊ូវណ្ណៈឲ្យកាន់តែខ្លាំងក្លា និងពង្រឹងនយោបាយខ្លួនទីពឹងខ្លួនឯករាជ្យម្ចាស់ការ ដែលក្នុងការអនុវត្តជាក់ស្តែងគឺជាការបង្ហូរឈាមប្រជាជនឯងរាប់លាននាក់។ អង្គការបក្សទាត់ចោលស្ទើរតែទាំងស្រុងនូវអ្វីដែលគេហៅថាកម្អែលពីរបបចាស់ ដោយមិនបានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងពលករជំនាញដែលមានស្រាប់ទេ តែជឿជាក់ថាជំនឿស៊ប់លើបក្ស និងការចូលរួមបង្កបង្កើនផលយ៉ាងសស្រាក់សស្រាំដោយកម្លាំងពលកម្មសរុបអាចនឹងសម្រេចផែនការបក្សបានដោយងាយ។ ជាលទ្ធផលនៃការគិតបែបនេះប្រជាជនទូទៅធ្វើការធ្ងន់ធ្ងរបាក់កម្លាំង ខ្លះឈឺស្លាប់ អត់បាយក្រហាយទឹកស្គមស្គាំងរីងរៃ ហើយនៅតែមិនសម្រេចបានតាមផែនការដែលដាក់ចុះទៀតផង។ ដើម្បីជៀសវាងពីការចោទប្រកាន់ថា «ក្បត់» ឬ «ខ្មាំង» គណៈដឹកនាំគ្រប់ថ្នាក់តែងតែរាយការណ៍យកល្អ មិនដែលឲ្យថ្នាក់លើដឹងថាខ្លួនមិនបានសម្រេចទៅតាមផែនការនោះទេ ដូច្នេះហើយទើបមានការនាំចេញស្រូវច្រើនពេក ដែលធ្វើឲ្យប្រជាជនក្នុងស្រុកខ្វះស្រូវអង្ករហូប ត្រូវហូបដំឡូងឬក្តួច ដាំបាយលាយស្លឹកដំឡូង ឬស្លឹកបន្លែព្រៃដើម្បីបំពេញការខ្វះខាត។ លើសពីនោះ អំបិលក៏ខ្វះខាតណាស់ដែរដោយសារតែអភិបាលកិច្ចដ៏ទន់ខ្សោយ និងប្រព័ន្ធគមនាគមន៍ត្រូវបំផ្លិចបំផ្លាញស្ទើរទាំងស្រុង។

ក្នុងឆ្នាំ១៩៧៥នោះ សហករណ៍កំម្រិតខ្ពស់នៅមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយប្រជាជនភាគច្រើននៅដាំបាយតាមផ្ទះ។ ដើម្បីកុំឲ្យដាច់បាយស្លាប់ ប្រជាជន ១៧មេសាខ្លះដែលមានគ្រឿងអលង្ការជាប់នឹងខ្លួន បានធ្វើការដោះដូរជាមួយប្រជាជនមូលដ្ឋានចាស់យកអង្ករនិងអំបិលមកហូប។ ខ្សែ.កមាសមួយខ្សែទម្ងន់ប្រហែល ៥ជី ដូរបានអំបិលប្រមាណមួយកំប៉ុងទឹកដោះគោប៉ុណ្ណោះ។ ខ្ញុំឃើញមានប្រជាជនជាច្រើនហើមខ្លួនឈឺស្លាប់ដោយសារតែខ្វះជាតិអំបិល។

ទីបំផុត អង្គការបក្សថ្នាក់កំពូលបានដឹងពីការខ្វះខាតស្បៀងនៅតាមបណ្តាមូលដ្ឋាន តែមិនទទួលស្គាល់ថាបណ្តាលមកពីការដឹកនាំដ៏ឆ្កួតលេលារបស់ខ្លួនទេ បែរជាចោទប្រកាន់ការដឹកនាំរបស់ថ្នាក់ក្រោមទៅវិញ។ គួបផ្សំនឹងជំនឿថាខ្មាំងសត្រូវបរទេសនៅតែមានផែនការប្រឆាំងនឹងបដិវត្តន៍របស់ខ្លួន ប៉ុល ពត នួន ជា ក៏ធ្វើការសន្និដ្ឋានដោយទុទិដ្ឋិនិយមថា ការមិនសំរេចតាមផែនការកន្លងមក គឺជាស្នាដៃរបស់ខ្មាំងបង្កប់ក្នុងជួរថ្នាក់ដឹកនាំ ទើបបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលថ្នាក់ភូមិភាគ ហើយរាលដាលដល់ថ្នាក់ក្រោមជាបន្តបន្ទាប់រហូតដល់ថ្នាក់ស្រុក និងសង្កាត់។ កម្មាភិបាលភូមិភាគឧត្តរត្រូវជាប់ចោទថាក្បត់ ត្រូវចាប់ខ្លួនបញ្ជូនទៅថ្នាក់លើ ហើយកម្មាភិបាលមកពីភូមិភាគនិរតីដែល ប៉ុល ពត នួន ជា ទុកចិត្តត្រូវបានបញ្ជូនឲ្យទៅក្តាប់វិញម្តង ។

## ការមកដល់របស់ពួកភូមិភាគនិរតី

នៅស្រុកជីក្រែង ខេត្តសៀមរាបជាទីដែលខ្ញុំរស់នៅក្នុងសម័យនោះ នាដើមឆ្នាំ១៩៧៧ ឃើញការមកដល់នៃកម្មាភិបាលមកពីភូមិភាគនិរតី ដែលមានជំនួយដោយយោធាមកពីភូមិភាគបូព៌ា។ ពួកទាំងនោះមាន តាសុក ជាគណៈស្រុក តាសន ជាអនុប្រធាន សមមិត្ត បើន ជាប្រធានយោធាស្រុក គ្រាន់តែមកដល់ភ្លាម ពួកនេះប្រើល្បិចហៅតាស៊ិន (គណៈស្រុកចាស់) និងតាសឿន (ប្រធានយោធាស្រុក ទៅប្រជុំ ហើយចាប់បញ្ជូនទៅថ្នាក់តំបន់ (សៀមរាប)។ តាកត់ ដែលជាអនុប្រធាន និងសមមិត្ត ស៊ឹម ដែលជាសមាជិកស្រុកត្រូវបានគេសម្រួលសតិអារម្មណ៍ឲ្យធ្វើការបន្តទៀត តែតាមពិត គឺជាការបោកប្រើសិនមុននឹងចាប់ខ្លួននៅពេលដែលលែងមានប្រយោជន៍។ កងយោធាស្រុកជីក្រែង ដែលធ្លាប់នៅក្រោមការគ្រប់គ្រងរបស់តាស៊ិនត្រូវបានដកអាវុធចេញទាំងអស់។ ភារកិច្ចបន្ទាប់របស់ពួកនេះគឺ «បំផុសដើម្បីរកខ្មាំង»ដោយប្រើល្បិចមួយដ៏ថោកទាប គឺញុះញង់ប្រជាជនឲ្យស្អប់ និងបះបោរប្រឆាំងនឹងពួកកម្មាភិបាលក្រោមការដឹកនាំរបស់តាស៊ិន ដើម្បីធ្វើជាលេសក្នុងការបង្ក្រាប។ អស់រយៈពេលប្រមាណ ២-៣ខែ ដែលពួកតាសុក-តាសន ជិះឡានទៅប្រជុំតាមភូមិសង្កាត់ ធ្វើបុកពាដូចជាអ្នកស្លូតបូត ចេះដឹង និយាយថ្កោលទោសគណៈស្រុកចាស់ថាក្បត់មាគ៌ាបក្ស បានធ្វើការកាប់សម្លាប់ បង្អត់បាយប្រជាជន បង្ខំឲ្យធ្វើការផាវហួសកម្លាំង គ្មានផ្សារ/សាលារៀន/វត្តអារាម។ល។ នៅឯភូមិត្រពាំងវែងក្នុងសង្កាត់កំពង់ក្តី មានការអនុញ្ញាតឲ្យធ្វើបុណ្យភូមិដោយមានការរាំរែក និងច្រៀងបទចម្រៀងពីសង្គមចាស់ផងដែរ។ ថ្ងៃមួយនាដើមខែមេសា ឆ្នាំ១៩៧៧ តាសុក បានជិះឡានទៅប្រជុំពលករនៅឯភូមិទ័ពសៀម សង្កាត់គោកធ្លកក្រោម នាការដ្ឋានកាយដីបាតត្រពាំងយកទៅធ្វើជាដីដាក់ស្រែ។ មានអាយុជាង៥០ឆ្នាំ ជក់ថ្នាំតាំងមូរស្លឹកសង្កែ ពាក់អាវពណ៌ស បត់ក្រមាជាពីរដាក់ពាក់លើស្មាម្ខាង មើលទៅគាត់ទំនងដូចជាអាចារ្យម្នាក់យ៉ាងដូច្នោះ។ នៅក្នុងពេលប្រជុំ គាត់ស្រក់ទឹកភ្នែកយំយែកនិយាយអាណិតអាសូរប្រជាជននៅទីនោះដែលធ្វើការពលកម្មពីព្រលឹមទល់ព្រលប់ មិនដែលបានហូបគ្រប់គ្រាន់ បែកកូន បែកឪពុកម្តាយ ហើយត្អូញត្អែរថាគ្មានវត្តគ្មានលោកសង្ឃធ្វើបុណ្យ គ្មានសាលាឲ្យក្មេងរៀន។ល។ នៅពេលនោះគ្មានអ្នកណាម្នាក់ដែលមិនជឿការសម្តែងដ៏សមឥតខ្ចោះនោះទេ ចាប់ផ្តើមមានកំហឹងនឹងគណៈស្រុកចាស់ ហើយមានការជឿទុកចិត្តយ៉ាងខ្លាំងលើគណៈស្រុកថ្មី។

នៅភូមិព្រៃធំឃុំគោកធ្លកលើមានព្រឹទ្ធាចារ្យម្នាក់ឈ្មោះយានដែលមានស្រុកកំណើតនៅខេត្តតាកែវ។ ប្រជាជនបាននិយាយតៗគ្នាថា គាត់ធ្លាប់បានបួសរៀនជាមួយតាសុក ដែលធ្វើឲ្យអ្នកភូមិព្រៃធំ និងក្រោយមកឃុំគោកធ្លកលើទាំងមូលកាន់តែជឿទុកចិត្តលើគណៈស្រុកថ្មី។ ភូមិនីមួយៗមានការជ្រើសរើសចាត់តាំងកងនីរសារដើម្បីធ្វើការទាក់ទងគ្នាជាមួយថ្នាក់សង្កាត់ និងស្រុក។ មានចាស់ៗ អ្នកភូមិខ្លះនៅចាំបានថា ឃើញពួកនិរសារបង្ហាញសំបុត្រមកពីថ្នាក់ស្រុកដែលមានបោះត្រាពណ៌ក្រហមទៀតផង។

ជារៀងរាល់ថ្ងៃ បណ្តាបុរសៗទាំងជាអ្នកមូលដ្ឋានចាស់ និងអ្នក១៧មេសាផងដែរ ប្រដាប់ដោយផ្គាក់ពូថៅ ប្រមូលផ្តុំគ្នាជាក្រុមៗដើរពីភូមិមួយទៅភូមិមួយ ដើម្បីកែនកម្លាំងអោយបានកាន់តែច្រើន។ ពួកគាត់ទៅដល់ភូមិណា ភូមិនោះត្រូវដាំបាយកាប់ជ្រូកធ្វើម្ហូបទទួលដោយពុំបាច់មានការសម្រេចពីប្រធានភូមិ ឬប្រធានសហករណ៍ទេ។ ថ្ងៃមួយអំពើហឹង្សាក៏បានផ្ទុះឡើងនៅសង្កាត់គោកធ្លកលើ គឺក្រុមបាតុករបានដេញកាប់សម្លាប់កម្មាភិបាលថ្នាក់សង្កាត់។ សមមិត្ត ឈឿង ត្រូវបានក្រុមបាតុកររកឃើញនៅវាលស្រែខាងលិចភូមិទ័ពសៀម ហើយកាប់គាត់ស្លាប់ដោយមានកាន់គ្រាប់បែកនៅនឹងដៃមិនទាន់ហូតកន្ទាស់។ នៅខាងត្បូងភូមិបន្ទិច សមមិត្តហេង ក៏ត្រូវបានសម្លាប់ផងដែរ។ សមមិត្ត ហ៊ា ត្រូវបានសម្លាប់នៅខាងកើតភូមិគោកធ្លក។ សមមិត្តសា ដែលជាគណៈសង្កាត់ជាមេកើយរបស់អ្នកទាំង៣ ខាងលើបានរត់ពួនគេចខ្លួនផុតពីការប្រមាញ់របស់ក្រុមបាតុករនាពេលនោះ។ នៅសង្កាត់ជីក្រែងឯណោះវិញ ក្រុមបាតុករបានលើកគ្នាដេញកាប់ពួកកម្មាភិបាលថ្នាក់សង្កាត់ស្លាប់ជាច្រើននាក់។ ព្រឹត្តិការណ៍បះបោរប្រឆាំងនឹង

កម្មាភិបាលខ្មែរក្រហមបានឆ្លងពីសង្កាត់មួយទៅសង្កាត់មួយទៀតយ៉ាងឆាប់រហ័ស ហើយទីបំផុតក៏រាលដាលដល់ការដ្ឋានការងារដីធំមួយនៅរហាលព្រួល ក្នុងភូមិសាស្ត្រឃុំល្វែងឫស្សីស្រុកជីក្រែង ជាប់ព្រំប្រទល់គ្នានឹងឃុំប្រឡាយស្រុកស្ទោងខេត្តកំពង់ធំ។ នៅទីនោះ អង្គការបានបញ្ជូនកងចល័តរាប់ពាន់នាក់ពីតាមសង្កាត់នានាទៅធ្វើទំនប់យ៉ាងវែងតាមបណ្តោយទន្លេសាប ដើម្បីស្ទាក់យកទឹកនារដូវវស្សាទុកធ្វើស្រែប្រាំង។

នៅថ្ងៃទី១២ ខែមេសាឆ្នាំ១៩៧៧ មានអ្នកជិះសេះម្នាក់កាន់កាំភ្លើង និងមនុស្សមួយចំនួនទៀតប្រដាប់ដោយផ្គាក់ និងពូថៅមកពីសង្កាត់ជីក្រែង បានបំផុសអ្នកនៅការដ្ឋានឲ្យងើបបោះបោរឡើង ហើយបានកាប់សម្លាប់សមមិត្តខេង ដែលជាកម្មាភិបាលថ្នាក់ស្រុកទទួលបន្ទុកសិក្សាធិការ និងកម្មាភិបាលដែលជាសមមិត្តក្នុងជួរមួយចំនួន។ ការដ្ឋានទាំងមូលច្របូកច្របល់ក្រឡាប់ចាក់ បណ្តាពលករក្នុងកងចល័តក៏រត់ចេញវិលត្រឡប់ទៅជួបជុំគ្រួសារនៅតាមភូមិរៀងៗខ្លួនវិញ។ លោកពូ ហ៊ុត ជាអ្នកភូមិតាភ្វា ឃុំគោកធ្លកលើ កាលនោះធ្វើជាប្រធានកងដឹកជញ្ជូនប្រចាំការដ្ឋានមានរទេះគោ ២០០គ្រឿងជាសមាជិក បររទេះរត់ចេញពីការដ្ឋានទៅផ្ទះនៅគោកធ្លកលើ បានប្រទះឃើញសពកម្មាភិបាល២នាក់ (ប្រុសម្នាក់ស្រីម្នាក់)នៅតាមផ្លូវ។ ហេតុការណ៍បះបោរនៅការដ្ឋានរហាលព្រួលបានធ្វើឲ្យកំសួលបាតុកម្មនៅតាមបណ្តាសង្កាត់នានាកាន់តែពុះពោរឡើង។ នៅសង្កាត់គោកធ្លកលើ ក្រុមបាតុករបានបង្កើនការស្វែងរកមុខសមមិត្តសាដែលជាគណៈសង្កាត់ និងព្យាយាមចូលទៅកាន់កាប់មូលដ្ឋានទ័ពនៅទំនប់ម្កាក់ តែមិនទាន់បានសម្រេច។

តាមរយៈការទាក់ទងគ្នាចុះឡើងជាប្រចាំរបស់ក្រុមនីសារ ក្រុមបាតុករបានទទួលដំណឹងថានឹងមានការធ្វើបាតុកម្មធំនៅថ្ងៃទី១៥ មេសា ១៩៧៧ ហើយថ្នាក់លើនឹងបញ្ជូនទ័ពមកជាជំនួយផងដែរ។

## ប្រផ្នូលមរណៈ

នាខែមីនាឆ្នាំ១៩៧៧ ដើមស្វាយព្រៃធំៗទាំង៥៦ដើមនៅតាមរបងវត្តគោកធ្លកមានរឿងចម្លែកមួយដែលធ្វើប្រជាជនមានការងឿងឆ្ងល់យ៉ាងខ្លាំង គឺមានស្នាមម្យ៉ាងរាងដូចបាតជើងមនុស្សតាំងពីគល់ដល់ចុងស្វាយគ្រប់ដើម។ ស្នាមនីមួយៗជិតជ្រៅទៅក្នុងសំបក ទក់ដូចគេជំនឹងញញួរ ហើយមានប្រវែងពី ៣ទៅ៥តឹកឯណោះ។ ប្រជាជនមានជំនឿថានឹងមានហេតុការណ៍សំខាន់មួយកើតឡើងក្នុងពេលឆាប់ៗជាមិនខាន។

លោកឪពុកខ្ញុំជាកូនទោលក្នុងគ្រួសារ ដូច្នេះគាត់គ្មានបងប្អូនបង្កើតទេ មានតែប្អូនជីដូនមួយចំនួន៦នាក់។ ម្នាក់ក្នុងចំណោមនោះ គឺជាសមមិត្តអ៊ុន ដែលជាកម្មាភិបាលថ្នាក់សង្កាត់ក្រោមការគ្រប់គ្រងរបស់សមមិត្តសា។ គាត់ជាមនុស្សនិយមកណ្តាល ចូលចិត្តនិយាយបែបកំប្លែង មិនដែលយកទោសអូសដំណើរអ្នកណាទេ ទើបបានជានៅក្នុងអំឡុងពេលបាតុកម្មពួកបាតុករមិនសម្លាប់គាត់ គ្រាន់តែដាក់កំហិតឲ្យនៅតែផ្ទះប៉ុណ្ណោះ។ ជាញឹកញាប់សមមិត្តអ៊ុន តែងតែទៅសម្រាកពេលយប់ជាមួយលោកឪពុក ព្រោះពួកគាត់ស្រឡាញ់គ្នាណាស់។ មានយប់មួយនោះ ពួកគាត់និយាយគ្នាពីរឿងសភាពការណ៍ស្រុកទេសដូចសព្វដង ហើយក៏ប្រឡែងលេងធ្វើដូចជាអាវ.ក សម្លាប់គ្នាដោយយកម្រាមដៃធ្វើជាកាំបិត។ គ្មានអ្នកណានឹកស្មានសោះថាល្បែងហ្នឹង គឺជាប្រផ្នូលមរណៈរបស់ពួកគាត់ទាំងពីរនាក់ឡើយ។

ប្អូនស្រីខ្ញុំម្នាក់ឈ្មោះខឹម ដែលម្តងនោះដើងកើតជំងឺជោះដើរដើរទៅណាឆ្ងាយមិនបាន តែងទៅអង្គុយមើលលោកឪពុកពូនរងដំឡូងជ្វានៅខាងក្រោយផ្ទះ។ ថ្ងៃមួយគាត់និយាយប្រាប់ខឹមថា «សភាពការណ៍ស្រុកទេសសព្វថ្ងៃពិបាកណាស់។ មើលទៅប៉ាបែបជាមិនអាចរស់បានយូរទៀតទេ តែក៏នឹងមិនរត់ទៅណាដែរ សុខចិត្តស្លាប់នៅទីនេះឲ្យកូនៗ បានឃើញឆ្អឹង។ ពេលអត់ពីប៉ាទៅ កូនត្រូវមើលថែយាយផង»។

## ថ្ងៃមហាសោកនាដកម្ម

តាំងពីព្រលឹមអុរនាថ្ងៃទី១៥ ខែមេសាឆ្នាំ១៩៧៧ គ្រប់ភូមិទូទាំងសង្កាត់គោកធ្លកលើមានសភាពអ៊ូអរ ស្រីៗក្រោកដាំបាយខ្ចប់ ប្រុសៗប្រដាប់ដោយផ្គាក់ពូថៅជួបជុំពិភាក្សាពីរឿងសំខាន់ដែលនឹងត្រូវធ្វើនាថ្ងៃនោះ។ លោកមាទៀង អួន នៅភូមិខ្វាឃុំ

ដឹងច្បាស់ថានឹងមានការបង្ក្រាបក្រុមបាតុករ ព្រោះកាលពីមួយថ្ងៃមុននោះមានយោធាម្នាក់ឈ្មោះសមមិត្តហឿនបានជិះកង់ពីកំពង់ក្តីមកពឹងគាត់ឲ្យទៅប្រាប់ឪពុកគេនៅភូមិសង្កែផងថាកុំចូលរួមធ្វើបាតុកម្មឲ្យសោះព្រោះអង្គការនឹងចុះមកបង្ក្រាបហើយ។ ហឿនបញ្ជាក់ថាខ្លួនគេផ្ទាល់ត្រូវបញ្ជូនចេញពីមូលដ្ឋានទ័ពនៅកំពង់ចាមដើម្បីទៅបង្ក្រាបការបោះបោរនៅតាយ៉ែក (កាលនោះតាយ៉ែកស្ថិតក្នុងស្រុកជីក្រែង)។ លោកមាទៀង អួនបានប្រាប់រឿងនេះដល់អ្នកភូមិជាមួយគ្នា ខ្លះក៏ជឿគាត់ អ្នកខ្លះក៏មិនជឿ។

នាព្រឹកនោះ លោកឪពុកខ្ញុំបានរៀបចំខ្លួនចេញដំណើរទៅក្រៅ ដោយស្លៀកពាក់ខោអាវឈុតក្រណាត់កាណាដាពណ៌បៃតងក្រមៅ បង់កនឹងក្រណាត់ទេសឯកពណ៌សលាយផ្កាពណ៌ស្វាយដែលប្រធានភូមិទើបនឹងចែកអោយ។ គាត់និយាយប្រាប់ម្តាយខ្ញុំថាព្រឹកនោះគាត់នឹងទៅជួបកម្លាំងទ័ពដែលចុះមកជួយ ពេលរួចរាល់ហើយនឹងបង្ហួសទៅយកខ្ញុំមកផ្ទះផង។ នៅពេលនោះរូបខ្ញុំកំពុងនេសាទត្រីនៅឯស្ទឹងកំបុតនាមាត់ទន្លេសាបក្នុងភូមិសាស្ត្រស្រុកជីក្រែង។ លោកឪពុកបានបី និងថើបកូនស្រីពៅឈ្មោះម៉ាលីដែលទើបនឹងមានអាយុ៧/៨ខែ ហើយនៅពេលដែលលោកមាវន មកដល់ពួកគាត់ទាំងពីរក៏ដើរបណ្តើរគ្នាចេញទៅបាត់ទៅ។ លោកយាយហួត អ្នកម្តាយ និងប្អូនៗខ្ញុំមាន មង់ ខឹម គីង និងអួនបានសម្លឹងមើលលោកឪពុកចាកចេញពីផ្ទះ ហើយមិនបានដឹងថាថ្ងៃនោះគាត់ចាកចេញពីពួកយើងជារៀងរហូតសោះឡើយ។

ប្រមាណជាម៉ោងជាង៧ព្រឹក រថយន្តយោធា៣គ្រឿងដែលដឹកនាំដោយតាសុក ជាគណៈស្រុកថ្មី បានមកដល់ដើមភូមិ ខ្វាឃុំ(ផ្នែកខាងត្បូង)។ ពួកយោធាក្មេងៗប្រមាណ២០នាក់ស្លៀកខោកៅស៊ូខ្មៅមូរជើងដល់ជង្គង់ អាវខ្មៅមានក្រមាបង់ក ប្រដាប់ដោយកាំភ្លើងអាកា៤៧ និងអិម៧៩ ចុះពីឡានកាត់.កាត់(ចិន) ដើររាយគ្នាព័ទ្ធភូមិជា២ខ្សែ ៖ មួយខ្សែដឹកនាំដោយសមមិត្តបើនដែលជាប្រធានយោធាស្រុកថ្មីរបស់តាសុក និងមួយខ្សែទៀតដឹកនាំដោយសមមិត្តស៊ឹម (ដែលជាសមាជិកស្រុករបស់គណៈស្រុកចាស់)។ ឯតាសុកដែលជាមេដឹកនាំប្រតិបត្តិការពាក់អាវពណ៌ពងក្រសារខុសគេ បត់ក្រមាជាពីរពាក់លើស្មាម្ខាងដូចសព្វដង មាត់បៀមបារីមូរស្លឹកសង្កែ ជិះឡានហ្ស៊ីបមួយគ្រឿងនិងមានកងការពារបួនប្រាំនាក់ជិះឡានហ្ស៊ីបមួយគ្រឿងទៀតតាមពីក្រោយ។ គាត់ឈប់ឡាននៅកន្លែងមួយដែលមានមនុស្សជុំគ្នា ហើយស្រែកសួរថា «មានផ្កាក់ពូថៅ បាយកញ្ចប់ព្រោងព្រាតហ្នឹងបម្រុងទៅធ្វើអ្វីនៅឯណា?» ពេលនោះលោកមាទៀងអួន និងគ្នីគ្នាគាត់ប៉ុន្មាននាក់ប្រញាប់ឆ្លើយឲ្យបានមុនគេថា «ទៅកាប់ចម្ការ»។ តាសុក ក៏តបវិញថា «បើអញ្ចឹងប្រញាប់ទៅកាប់ទៅ» ហើយក៏បញ្ជាអ្នកនៅក្បែរឲ្យហៅពួកទ័ពដែលកំពុងព័ទ្ធភូមិឲ្យធ្វើដំណើរទៅមុខទៀត។ នៅពេល ឡានតាសុក ទៅដល់ដើមភូមិត្រពាំងវែង មុំស្ពានទី១ បុរសម្នាក់ឈ្មោះអេតបានក្រឡេកឃើញហើយស្មានថាជាកម្លាំងទ័ពដែលមកជួយក្រុមបាតុករក៏ដើរសំដៅទៅក្បែរឡានហើយនិយាយស្វាគមន៍។

ភ្លាមៗក្រោយពីដឹងថាគាត់ជាបាតុករ យោធាម្នាក់បានបាញ់គាត់ដួលស្លាប់ ហើយបានស្រែកសួរអ្នកភូមិដែលនៅជិតនោះថា «តើម្នាក់នេះជាអ្នកមូលដ្ឋានចាស់ ឬ១៧ មេសា?» អ្នកភូមិឆ្លើយថា «ជាអ្នក១៧មេសា»។ តាសុក ក៏បញ្ជាឲ្យកងយោធាហ៊ុំព័ទ្ធភូមិ និងហៅមនុស្សឲ្យទៅប្រជុំនៅស្ពានទី២ ស្ថិតនៅចុងខាងជើងភូមិចម្ងាយប្រមាណ៣០០ម៉ែត្រពីស្ពានទី១។ បុរសស្ត្រីដែលនៅតាមផ្ទះក្តី អ្នកឃ្វាលគោ អ្នកឡើងត្នោត អ្នកដំណើរធ្វើរជើងកង់ រទេះគោក្តី ត្រូវពួកយោធាបង្ខំឲ្យទៅប្រជុំទាំងអស់។

នៅចុងខាងជើងភូមិ ពួកយោធាបានឃាត់ខ្លួនអ្នកភូមិម្នាក់ឈ្មោះព្រឿនដែលកន្ទងមកត្រូវបានគេចាត់តាំងអោយធ្វើជានីរសាររបស់ក្រុមបាតុករប្រចាំភូមិ។ នៅពេលនោះគាត់ទើបនឹងវិលត្រឡប់មកពីមើលស្ថានការណ៍បាតុកម្មនៅភូមិគោកធ្លកៗ ដោយយល់ច្រឡំដែរថាពួកនោះជាកងទ័ពដែលមកជួយ ទើបបានជាគាត់ឆ្លើយប្រាប់ពួកនោះថា «ប្រជាជនកំពុងធ្វើបាតុកម្ម ហើយគណៈភូមិជាអ្នកឲ្យធ្វើ»។ ភ្លាមនោះ ពួកយោធាក៏ចាប់គាត់ចងហើយបញ្ជាឲ្យទៅហៅគណៈភូមិទាំង៣នាក់។ លោកអាចារ្យនល់ និងលោកមាខាន់ ត្រូវពួកយោធាអាវខ្មៅទៅហៅឲ្យចេញពីផ្ទះ។

លោកមាឃីដែលទើបមកពីឡើងត្នោត នៅខាងលិចភូមិ មកដល់ផ្ទះដូនពេល នឹងពួកយោធាមកដល់ដែរ។ គាត់ព្យួរបំពង់ទឹកត្នោតនឹងកាំជណ្ដើរ ដើរចេញទៅប្រជុំដោយស្លៀកក្រមាពីលើខោខ្លីមួយប៉ុណ្ណោះ។

លោកមាព្រំ រី ជាប្រជាជនធម្មតាដែលពេលនោះកំពុងឡើងត្នោត ក៏ត្រូវគេហៅដែរ។ មុននោះគាត់បានដឹងពីការបាញ់សម្លាប់ឈ្មោះអេត នៅដើមភូមិ គាត់សង្ស័យថា មានរឿងមិនស្រួល ក៏ឆៀងចូលផ្ទះទៅយកគ្រាប់បែកដៃ ២គ្រាប់ដែលសល់ពីសម័យសង្គ្រាម លាក់ក្នុងខោខ្លី រួចដើរទៅប្រជុំទាំងមានកាំបិតត្នោតក្នុងស្រោមសៀតនឹងខ្សែក្រវាត់ (ជាខ្សែក្រវាត់ទាហានលន់ នល់) នឹងចង្កេះផងដែរ ដែលកាំបិតនោះត្រូវសមមិត្តស៊ឹម ដកហូត និងប្រគល់ទៅឲ្យតាសុក។ តាសុកដកកាំបិតចេញពីស្រោម ពិនិត្យមើល ហើយក៏សរសើរថាកាំបិតនោះល្អ ហើយមុតទៀត។ ដៃកាន់កាំបិត ភ្នែកសម្លឹងសកម្មភាពចាប់មនុស្សមកប្រជុំ ហើយមួយសន្ទុះក្រោយមកគាត់ក៏និយាយបន្ថែមថា «មើលទៅត្រូវតែចាត់ការមនុស្សមួយភូមិនេះទាំងអស់ហើយ»។

អ្នកដែលសកម្មក្នុងការហៅមនុស្សចំៗឈ្មោះឲ្យទៅប្រជុំនោះគឺយោធាម្នាក់ឈ្មោះសមមិត្តធា ជាអ្នកភូមិព្រៃធំនៅក្បែរនោះ ដែលជាកងយោធាស្រុកពីសម័យគណៈស្រុកចាស់គឺតាស៊ិន និងប្រចាំការនៅមូលដ្ឋានទ័ពទំនប់ម្កាក់។ មានប្រជាជនមួយចំនួនបានឃើញថាកាលពីល្ងាចថ្ងៃ១៨មេសា គាត់នៅឯទំនប់ម្កាក់ឯណោះទេ ស្រាប់តែព្រឹកថ្ងៃបន្ទាប់ ឃើញគាត់មកជាមួយក្បួនទ័ពដែលចេញពីកំពង់ក្ដីទៅវិញ។ នេះប្រហែលជាមកពីដោយសារតែគាត់ជាពេជ្ឈឃាតដ៏ចំណានម្នាក់នៅទំនប់ម្កាក់ ហើយក៏ជាអ្នកមូលដ្ឋានឃុំគោកធ្លកលើ ស្គាល់មនុស្សច្រើន ទើបគេហៅឲ្យទៅកំពង់ក្ដីទាំងយប់ដើម្បីចូលរួមយុទ្ធនាការថ្ងៃ១៩មេសា។ កម្មាភិបាលម្នាក់ថ្លែងក្នុងការប្រជុំដែលមានខ្លឹមសារលើកឡើងអំពីពលិកម្មសាច់ស្រស់ឈាមស្រស់របស់យុទ្ធមិត្តរហូតដល់បដិវត្តន៍ជណ្ដើមរដ្ឋអំណាចមកកាន់កាប់ តែសត្រូវបដិវត្តន៍នៅតែមានបំណងប្រឆាំងជានិច្ច ជាក់ស្ដែងពេលនេះគឺនាំគ្នាបះបោរធ្វើបាតុកម្មសម្លាប់កម្មាភិបាលបដិវត្តន៍។ បដិវត្តន៍ត្រូវតែកម្ទេចខ្មាំងទាំងអស់នោះជាដាច់ខាត។ បន្ទាប់ពីការថ្លែងនោះ ស្ត្រីៗដែលមួយចំនួនមានបីកូនតូចផងនោះត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ហើយប្រាប់ប្រុសៗ អ្នកមូលដ្ឋានចាស់ក្រោកទៅអង្គុយបែកពីអ្នក១៧មេសា លើកលែងតែអ្នកណាដែលពួកវាដឹងថាជាបាតុករដែលត្រូវអង្គុយកន្លែងដដែល។ អ្នក១៧មេសាខ្លះដឹងខ្លួនថាមានរឿងមិនស្រួលក៏បន្លំខ្លួនចូលទៅអង្គុយជាមួយអ្នកមូលដ្ឋានចាស់ តែឈ្មោះរៀម ដែលជាអ្នកមូលដ្ឋានចាស់ដេញចេញមិនឲ្យអង្គុយជាមួយ។ ពួកយោធាអាវខ្មៅបញ្ជាឲ្យបណ្ដាអ្នកដែលស្ថិតក្នុងមុខសញ្ញាត្រូវសម្លាប់ ឈរតម្រង់ជួរ ហើយពួកវាចាប់ផ្ដើមចងស្លាបសេកដោយប្រើខ្សែគោដែលរឹបយកពីអ្នកឃ្វាលគោ និងអ្នកបររទេះ ឬយកក្រមារបស់ជនរងគ្រោះមកចង។

នៅពេលកំពុងចង វាក៏ឆៀតសម្លុតសួរជនរងគ្រោះឲ្យរាប់រាវថាអ្នកណាខ្លះទៀតដែលបានចូលរួមធ្វើបាតុកម្ម។ អ្នកទាំងឡាយណាដែលត្រូវគេឆ្លើយដាក់ត្រូវពួកវា ចងភ្លាមៗដោយគ្មានការសួរបញ្ជាក់ឡើយ។ ក្នុងខណៈនោះដែរ លោកមាម៉ៅ ស៊ន់ កំពុងនាំឆ្កែដេញសត្វព្រៃនៅវាលស្រែខាងលិចភូមិ។ គាត់បានដេញទន្សាយមួយក្បាលដែលរត់ទៅចំកន្លែងដែលពួកយោធាអាវខ្មៅកំពុងដាក់ខ្សែត្រៀម។ យោធាម្នាក់បានបោយដៃហៅគាត់ឲ្យទៅជួប តែលោកម៉ៅ ស៊ន់ សង្ស័យថាមានរឿងមិនស្រួលក៏រត់បកក្រោយវិញ។ ពួកយោធាក៏បាញ់ តែមិនត្រូវ។ គាត់រត់ឆ្ពៀលទៅទិសខាងត្បូង និងឆ្លងផ្លូវនៅចន្លោះភូមិត្រពាំងវែង និងប៉ាតតសំដៅទៅផ្ទះដែលនៅប៉ែកខាងកើតភូមិ។ ដោយមិនអស់ចិត្តពីរឿងដែលទើបនឹងកើតឡើងអំបាញ់មិញ ក៏ឡើងដើមក្រឡាញ់មួយដើមធំខ្ពស់ដើម្បីសង្កេតមើលហេតុការណ៍ ឃើញយោធាអាវខ្មៅម្នាក់ទាញយកកាំបិតចេញពីឡានហ្ស៊ីប ស្រាយក្រណាត់រុំចេញ ហើយកាន់ដើរសំដៅទៅរកហ្វូងមនុស្សដែលអង្គុយនៅវាលស្រែខាងលិចស្ពាន។ គាត់ជឿថាកាំបិតនោះនឹងត្រូវគេយកទៅសម្លាប់មនុស្សក៏ប្រញាប់ចុះមកដី ហើយរត់ទៅប្រាប់ចាស់ៗ ដែលនៅក្បែរនោះឲ្យបានដឹង។

(តនៅលេខក្រោយ)

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់

## នៅក្នុងរបបខ្មែរក្រហម ចារទុកក្នុងសៀវភៅរំឭក វិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*ផាន់ថាន់ ពៅដារ៉ា និង ធ្យុង ដានី*

(តពីលេខមុន)

**ថង ឡៃ** អាយុ ២០ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅសេរីសោភ័ណ ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) ជាកូនរបស់ពូ ថង និងមីង ឡៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបាត់ដំបង ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ៣ បន្ទប់តូច ១០។ ខ្មែរក្រហមចាប់បញ្ជូន ថង ឡៃ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៦៤ ថ្ងៃ។

**ថន** មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រែអំបិលរដ្ឋ ថ្ងៃទី២៨ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ១ បន្ទប់តូច ៥។

**ថាច់ គឹម** មានអាយុ៣៧ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅមោងឫស្សី ខេត្តបាត់ដំបង ជាកូនរបស់អ៊ំប្រាច និងអ៊ំស្រី ពិន សារុន មានប្រពន្ធឈ្មោះ ពៅ សារុន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបាត់ដំបង ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ០៥ បន្ទប់តូច ១៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថាច់ គឿង** មានអាយុ៥៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពោធិ៍រៀង ខេត្តព្រៃវែង ជាកូនរបស់លោកតា ថាច់ សួន និងលោកយាយ ធី ធាវ មានប្រពន្ធឈ្មោះ ស្រី វៀន មានកូនប្រុស ៣នាក់ និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គិសនីជ្រោយចង្វារតូច ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៨ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ ថាច់ គឿង នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៦។

**ថាច់ ឃាម** ហៅ ស្រី ឃៀម មានអាយុ៤៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ អតីតពេទ្យទាហាន មានស្រុកកំណើតនៅកំពង់ស្ពាន ខេត្តព្រះត្រពាំង ឪពុកម្តាយឈ្មោះ ថាច់ ខៀវ និង នាង សាន មានប្រពន្ធឈ្មោះ ឌិ ទន់សៀប មានកូនប្រុស ៣នាក់និងស្រី ៦នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០២ បន្ទប់ធំ ១១។ ខ្មែរក្រហមសម្លាប់ ថាច់ ឃាម នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៦។

**ថាច់ គូណៃត** ហៅ យុទ្ធ មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅវិញចូវ ខេត្តបាក់លីវ ឪពុកម្តាយឈ្មោះ ថាច់ គូវ និង សុន ធីវ៉ាន់ មានប្រពន្ធឈ្មោះ ទី គីមយាន មានកូនប្រុស១នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរសន្តិសុខក្រុងភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៣ បន្ទប់តូច ១១។

ខ្មែរក្រហមសម្លាប់ ថាច់ តូណែត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩៥ ថ្ងៃ។

**ថាច់ ថម** មានអាយុ៤០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកូវផ្សាំង ខេត្តត្រាវិញ ឪពុកម្តាយឈ្មោះ ថាច់ អ៊ុយ និង ថាច់ ឆៀក មានប្រពន្ធឈ្មោះ អ៊ំ ជា ហៅ អូន មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅជ្រោយអំពិល ថ្ងៃទី៩ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ១០។ (គ្មានក្នុងបញ្ជី)។

**ថាច់ នួន** មានអាយុ៤០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអន្លង់ ខេត្តត្រាវិញ កម្ពុជាក្រោម ឪពុកម្តាយឈ្មោះ ថាច់ ចឹង និង ថាច់ ធី មើង មានប្រពន្ធឈ្មោះ កែវ សុណារី ហៅ ហ៊ិន មានកូនប្រុស៤នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុក ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់ធំ ៩។ ខ្មែរក្រហមចាប់បញ្ជូន ថាច់ នួន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១០០ថ្ងៃ។ ថាច់ ពេជ គឺជាសង្ឃរាជ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ថាច់ ពេជ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៧២ថ្ងៃ។

**ថាច់ សួង** ហៅ ទី មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ អតីតទូតរណសិរ្សរួបរួមជាតិកម្ពុជារហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រះត្រពាំង ឪពុកម្តាយឈ្មោះ ថាច់ គិត និង ម៉ក់ មឿង មានប្រពន្ធឈ្មោះ លូឌីឡាស្មៀណូវ៉ា (នៅមូស្គូ) មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ថាច់ សួង នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។

**ថាច់ ហ៊ីយ៉េន** ឬ ប៉ាអារស្មី មានអាយុ៤២ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅខ្សាច់ ខេត្តឃ្លាំង ឪពុកម្តាយឈ្មោះ ថាច់ យ៉ែម និង លី អាយឃឹម មានប្រពន្ធឈ្មោះ លី អាយឃឹម ហៅ អាស្មី មានកូនប្រុស ៤នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅខាងលើវត្តបបុល ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ០៦ បន្ទប់តូច ៣។ ខ្មែរក្រហមចាប់បញ្ជូន ថាច់ ហ៊ីយ៉េន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៩ ថ្ងៃ។

**ថាន ហ្វាស** ហៅ នី មានអាយុ៣០ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ ឡេង មានប្ដីឈ្មោះ សាមាសការេម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ថាន ហ្វាស ឬ ថានី ហ្វាស នៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៧៦។

**ថាន់ សំអុន** ហៅ មួនមានអាយុ៣០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ ឌុល ផាន់ និងមីង ម៉ៅ វេត មានប្ដីឈ្មោះ ហែម ស្រៀង ហៅ កេង មានកូនប្រុស២នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសន្តមកិច្ចរោងចក្រ ជ-៦ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថាយ សូវាណ៍ថា** ឬ ថាយ ស៊ុវ៉ាន់ថា មានអាយុ៣៤ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំ ថាយ សែម និងអ៊ំស្រី ឈឹន ឡេង មានប្រពន្ធឈ្មោះ អរ៉ាំង ឆេងហ៊ុ ហៅ យឹញ មានកូនប្រុស ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គិសនីផ្សារតូច ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថាវ ប៊ុនថាវី** មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅប៉ាកសេ ខេត្តប៉ាកសេ ឪពុកម្តាយឈ្មោះ ថាវ ហាង និង ណាង លុយ មានប្រពន្ធឈ្មោះ អ៊ឹង ឡានី មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនត្រាំកក់ ខេត្តតាកែវ ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៥ បន្ទប់ធំ ៥។ ខ្មែរក្រហមចាប់បញ្ជូន ថាវ ប៊ុនថាវី ទៅដល់គុកទួលស្លែងនៅថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៩ខែមេសា ឆ្នាំ១៩៧៦ ឬ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦។

**ថាំង ខេងប៊ូ** ហៅ អូន មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបាកាន ខេត្តពោធិ៍សាត់ ជាកូនរបស់ពូ ថាំង ហ៊ុយ និងមីង ឆឹង ណៃគាវ មានប្រពន្ធឈ្មោះ អ៊ឹង អេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុករលាប្អៀរ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ថាំង ខេងប៊ូ ឬ ខេង ប៊ូ ឬ ថ្វាំង ខេងប៊ូ ទៅដល់គុកទួលស្លែងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឬ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឬ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦។ ថេង ស៊ី ហៅ ង៉ែត មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃកប្បាស ខេត្តតាកែវ ជាកូនរបស់អ៊ំ ថេង ស៊ីត និងអ៊ំស្រី នាង នី មានប្រពន្ធឈ្មោះ កួយ នៅ មានកូនប្រុស១នាក់និងស្រី៥នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុកថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់លេខ១។ ខ្មែរក្រហមចាប់បញ្ជូន ថេង ស៊ី ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១២៥ ថ្ងៃ។

**ថៃ ត្រុស** ហៅ មែន មានអាយុ២៤ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ ថៃ យាន និងមីង កេត ស៊ាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ (គ្មានក្នុងបញ្ជី)។

**ថៃ សុផល់** មានអាយុ២៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ថៃ សៅ និងមីង ឡាំ ជី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ឡានទឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៤ បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ ថៃ សុផល់ ឬ ថៃ សុផល នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឬ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧។

**ថោង គីមស៊ី** មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅមង្គលបូរី ខេត្តបន្ទាយមានជ័យ ជាកូនរបស់ពូ ថោង គ្រុយង៉ និងមីង ស្រ៊ាង ផួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ១៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថោង ផៃ** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ១៧០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ថោង ផៃ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៧២ថ្ងៃ។

**ថោង ម៉ារឌី** មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅដង្កោ ខេត្តកណ្តាល ជាកូនរបស់ពូ ថោង ម៉ាត់ និងមីង ស្រី យឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួនរទេះភ្លើងភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ២ បន្ទប់តូច ៩។ ខ្មែរក្រហមចាប់បញ្ជូន ថោង ម៉ារឌី ឬ ថោង ម៉ាឌី ទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ឬ ២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

**ថោង យ៉ាន់** មានអាយុ៣៣ឆ្នាំ ក្នុងឆ្នាំ១៩៧៦ ភិក្ខុសង្ឃ មានស្រុកកំណើតនៅស្រុក៥២ ( ស្រុក

សំរោងទង) ខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ំ ថោង យស់ និងអ៊ំស្រី យន សឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក៥២ ថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៥ បន្ទប់តូច ៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថោង សារ៉ាត** ហៅ ពៅ មានអាយុ៣៧ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបន្ទាយមាស ខេត្តកំពត ជាកូនរបស់អ៊ំ មុំ ស៊ុន និងអ៊ំស្រី នាង ង៉ក់ មានប្រពន្ធឈ្មោះ កុយ គីម ឡុង ហៅ ម៉ុង មានកូនប្រុស ១នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅជប់ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៨ បន្ទប់លេខ ២១។ ខ្មែរក្រហមចាប់បញ្ជូន ថោង សារ៉ាត ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩២ ថ្ងៃ។

**ថោង សំអុន** មានអាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ថោង អួច និងមីង ប៉ែន ហៀន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ព-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ថៅ គីម ស្រួង** មានអាយុ៤៩ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្វាយទង ខេត្តចូវដុក ឪពុកម្តាយឈ្មោះ ចូវ ចិន និង នាង សុង មានប្រពន្ធឈ្មោះ លេ វ៉ា មានកូនប្រុស ៣នាក់និងស្រី ៧នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៥ នៅ ឡុងប៊ិន ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៨ បន្ទប់ធំ ២៥។ (គ្មានក្នុងបញ្ជី)។

**ធក ភាន** ហៅ ខេង មានអាយុ៣៣ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអង្គរជ័យ ខេត្តកំពត ជាកូនរបស់អ៊ំ ម៉ីញ វេត និងអ៊ំស្រី គង់ ញឹម មានប្រពន្ធឈ្មោះ ចន្ទ័មុំ សោភា មានកូនប្រុស ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅសាលាបដិវត្តន៍ស្រុកជប់ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ១០។ ខ្មែរក្រហមចាប់បញ្ជូន ទក កាន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៦ ថ្ងៃ។

**ធក ប៉ោ ហួរះ** ហៅ ពីង មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ជាកូនរបស់ពូ ទក ខាន់ និងមីង ថ្វាង យី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់២២ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ១៨។ (គ្មានក្នុងបញ្ជី)។

**ធត យៀង** ហៅ យឹម មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ ទត និងមីង រិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ធត លី** មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក៥៥ (ស្រុកព្រៃកប្បាស) ខេត្តតាកែវ ជាកូនរបស់ពូ យិន នៅ និងមីង ឡុង លឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទត លី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

**ធន ហ៊ាង** មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៨ (ស្រុកកោះធំ) ខេត្តកណ្តាល ជាកូនរបស់ពូ អ៊ុំ ទន និងមីង បេ ចេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ព-៩៨ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ។ ខ្មែរក្រហមសម្លាប់ ទន ហ៊ាង ឬ ទន ហៀង នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ ឬ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧។

**ធា ខេង** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រ តម្បាញ ត-៥ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទា ខេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទ នៃការសម្លាប់នៅឡើយ។

**ធា គឹមស្រ៊ុន** មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូន របស់អ៊ំ ទា ឃី ចេង និងអ៊ំស្រី នាង ឃឹម ហ៊ាង មានប្តី ឈ្មោះ ជាម វេង ស៊ាន មានកូនប្រុស ៣នាក់ និងស្រី១ នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅ គុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ០៥ បន្ទប់តូច ៨។ ខ្មែរក្រហមសម្លាប់ ទាំ គឹមស្រ៊ុន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។ រីឯប្តីឈ្មោះ ជាម វ៉េងស៊ាន ត្រូវបានខ្មែរក្រហម ចាប់ខ្លួនមកជាមួយប្រពន្ធដែរ តែនៅពុំទាន់មានឯកសារ បញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ធា ចិន្តា** មានអាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មាន ស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ ទា សេង និងមីង សាន គីម ស៊ី ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅស្រុកសេរីសោភ័ណ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ៥។ ខ្មែរក្រហមចាប់បញ្ជូន ទា ចិន្តា ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ ពីជាប់ឃុំឃាំងអស់រយៈពេល ១០០ ថ្ងៃ។

**ធា បេងតេក** មានអាយុ៤៦ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មាន ស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំ ទា ឈួន និងអ៊ំស្រី ឡាំង ចេង មានប្រពន្ធឈ្មោះ ចេង ម៉ាក់ឡែន មានកូនប្រុស ៣នាក់និងស្រី ៤នាក់ ត្រូវ បានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦។ (គ្មានក្នុងបញ្ជី)។

**ធា ម៉េងថៃ** ហៅ ថៃ ជា មានអាយុ៣៨ឆ្នាំ ក្នុង ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ជាកូនរបស់អ៊ំ ទា ង៉េញ វ៉េង និងអ៊ំស្រី អ៊ី ណេង មានប្រពន្ធឈ្មោះ ធីជា ហៅ ថៃជា មានកូនប្រុស២នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនបាត់ដំបង ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ២១។ ខ្មែរក្រហមចាប់បញ្ជូន ទា វ៉េងថៃ ទៅដល់គុកទួលស្លែង នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់ រយៈពេល៩៧ថ្ងៃ។

**ធា ហាចតិក** មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពត ខេត្តកំពត ជាកូនរបស់អ៊ំ ទា លី និងអ៊ំស្រី វួច ម៉េង មានប្រពន្ធឈ្មោះ ឈិន ណាវី មានកូនប្រុស ១នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅឃុំកោះខែល ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ៥។ (គ្មានក្នុងបញ្ជី)។

**ធា ឈុនកេង** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ខ្មែរក្រហម ចាប់បញ្ជូន ទា ឈុនកេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃបន្ទាប់។ រីឯ ប្តីឈ្មោះ ម៉ៅ សុផានី ត្រូវបានខ្មែរក្រហមចាប់បញ្ជូន ទៅដល់គុកទួលស្លែងនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៦ តែនៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការ សម្លាប់នៅឡើយ។

**ធាច ពឺន** ហៅ ទាវ សាវិន មានអាយុ៣៦ឆ្នាំក្នុង ឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តកណ្ដាល ជាកូន របស់អ៊ំ ទាវ កេច និងអ៊ំស្រី ប៊ុង ពិន មានប្រពន្ធឈ្មោះ អ៊ុនយ៉ន មានកូនប្រុស ២នាក់និងស្រី នាពក់ ត្រូវបានខ្មែរ ក្រហមចាប់ខ្លួននៅរោងចក្ររទេះភ្លើង ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង

ក្នុងផ្ទះ ក០៥ បន្ទប់លេខ ៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ទិត កាន** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទិត កាន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១៥ថ្ងៃ។

**ទិត គង់** មានអាយុ៣៦ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅខេត្តស្វាយរៀង ជាកូនរបស់អ៊ំ ទិត សួរ និងអ៊ំស្រី ម៉ម ហុង មានប្រពន្ធឈ្មោះ កៅ សូភី មានកូនប្រុស១នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនអគ្គិសនីចាក់អង្រែ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ៣។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ទិត ដួន** មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៦ (ស្រុកស្អាង) ខេត្តកណ្ដាល ជាកូនរបស់ពូ នេត ទិត និងមីង ខឹម មុិច ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទិត ដួន នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

**ទិត ឈឿន** ហៅ ខឿន មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ ទិត ចែត្រ និងមីង ដួង វែង ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល៣១០ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ៤ បន្ទប់តូច ៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ទិត ធឿង** ហៅ ទិត វីរៈ មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកំពង់ត្របែក ខេត្តព្រៃវែង ជាកូនរបស់ពូ ទិត សួង និងមីង លោប ស៊ិន ត្រូវបានខ្មែរក្រហមចាប់ខ្លួនភូមិបំណាក់ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ ទិត ធឿង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

**ទិត ផៃ** មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ជាកូនរបស់អ៊ំ ទិត ង៉ែត និងអ៊ំស្រី ណាញ់ គាំ មានប្រពន្ធឈ្មោះ កាន់ សេង មានកូនប្រុស៦នាក់ និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរក-១៥ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៤ បន្ទប់តូច ៧។ ខ្មែរក្រហមសម្លាប់ ទិត ផៃ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ ឬ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៦។

**ទិត វ៉ាន់** មានអាយុ២១ឆ្នាំ ក្នុងឆ្នាំ១៩៧៧ ស្រុកកំណើតនៅស្រុក១០៨ តំបន់១៣ (ស្រុកកោះអណ្ដែត ខេត្តតាកែវ) ជាកូនរបស់ពូ ទិត ខាត់ និងមីង ដែញ ញ៉ែត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទិត វ៉ាន់ ឬ ទិត វ៉ាន នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥៣ ថ្ងៃ។

**ទិត ឡៃ** ហៅ សាមីន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទិត ឡៃ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៨ ថ្ងៃ។

**ទី ផុំ** ហៅ ឆន មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកណ្ដាលស្ទឹង ខេត្តកណ្ដាល ជាកូនរបស់អ៊ំ ទី ប៉ក់ និងអ៊ំស្រី ព្រុំ ម៉ាន់ មានប្រពន្ធឈ្មោះ សុង សៀងគង់ មានកូនប្រុស ១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុកតំបន់៥ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់លេខ ២។ ខ្មែរក្រហមចាប់បញ្ជូន ទី ផុំ ឬ ទី ឈុំ ហៅ ឈន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ធី ប៊ុន** ហៅ ភឹម មានអាយុ៣៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ំ ដុក ទី និងអ៊ំស្រី យិន រឿង មានប្រពន្ធឈ្មោះ ប៉ុន ឃឹម មានកូនប្រុស ៣នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិភាគបស្ចិម ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**ធី រិត** ហៅ សាម មានអាយុ៣១ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅក្រឡាញ់ ខេត្តសៀមរាប ជាកូនរបស់អ៊ំ ទី រឿម និងអ៊ំស្រី អ៊ិន ឡៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ វត្តសង្កែបត់ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ៧។ ខ្មែរក្រហមចាប់បញ្ជូន ទី រិត ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១១៤ថ្ងៃ។

**ធី សាវ៉ាន់** ហៅ ទី រុន មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្នួល ខេត្តក្រចេះ ជាកូនរបស់ពូ ទិ ឈឹម និងមីង ទើប រ៉ឹក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ពានត ភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ២ បន្ទប់តូច ១៣។ (គ្មានក្នុងបញ្ជី)។

**ធី សុវត្ថា** មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅថ្ពង ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ទី គឹម ហ៊ាង និងមីង អេង សេង មានប្រពន្ធឈ្មោះ ជា ប៊ុនលី ហៅ ជា អន មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រត-៤ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ២។ ខ្មែរក្រហមសម្លាប់ ទី សុវត្ថា នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦។

(តទៅលេខក្រោយ)


**ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ**

ទស្សនាវដ្ដីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្ដីស្វែងរកការពិតតាមអាសយដ្ឋាន ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ៩៩៦ ៧៥០

អ៊ីម៉ែល៖ truthbunthorn.s@dccam.org - គេហទំព័រ៖ www.dccam.org



រូបក្របមុខ៖
អដ្ឋិធាតុជនរងគ្រោះ នៅខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
កង ណារ៉ន នៅឆ្នាំ១៩៧១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥
DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 245, May 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.